# កម្ពុជសុរិយា

ទស្សនាវដ្តី ផ្សាយដំណឹងខាងសាសនា និងអក្សរសាស្ត្រ

ឆ្នាំទី ៣១ លេខ ៩ ខែកញ្ញា

ព.ស. ២៥០២ គ.ស. ១៩៥៩

ភ្នំពេញ

# កម្ពុជសុរិយា

ទស្សនាវដ្តី ផ្សាយដំណឹងខាងសាសនា និងអក្សរសាស្ត្រ

បោះពុម្ពផ្សាយអំពីពុទ្ធសាសនបណ្ឌិត្យ

| ផ្នែកសាសនា | ជំពូករឿង | ទំព័រ |
|---|---|---|


- ធារកថា របស់ព្រះមហា ចក់-សុវណ្ណ . . . . . . ៩៦៥
- មេត្តាវិហារកថា របស់ព្រះបាទឡុកគុសម្ព័ន្ធ មួល-ប៊ុន . . . ៩៧៨
- សុរកជាតក (តមក) លោក ជិង-វែង ចម្លងពីសាស្ត្រាស្លឹករឹត . ៩៨៥

ផ្នែកអក្សរសាស្ត្រ

- រឿងហង្សយន្ត (តមក) លោក អ៊ឹម-គន ចម្លងពីសាស្ត្រាស្លឹករឹត . ៩៩៤
- រឿងព្រេងនិងរឿងបុកណ៍ប្រទេសជប៉ុន (តមក) លោក ភិយ-ប៊ុក រៀបរៀង . ១០០០
- រឿងស្រីគ្រប់ល័ក្ខណ៍ (តមក) ឃុក-គើវរៀបរៀង លោក ផេង-ត្រី ពិនិត្យ. ១០២៦
- បន្ទាមុតយកបន្លាចោះ លោក ប៊ូ-ប៊ូ រៀបរៀង . . . . . ១០៣៧
- ទៅលេងឋានសួគ៌ចំនួនដប់ថ្ងៃ លោក ញូក-រឿង រៀបរៀង . . . ១០៤៥
- រឿងមរណមាតា (តមក) លោក ប៊ី-សុវណ្ណ ចម្លងពីសាស្ត្រាស្លឹករឹត . . ១០៥០
- រឿងសាមកុក (តមក) ឧកញ៉ា នូ-កន ប្រែ . . . . . ១០៦១

ផ្នែកកំណត់ទិនប្បវត្តិការណ៍

- បុណ្យផ្កា ជួយឧបត្ថម្ភសមណនិស្សិត នៅពុទ្ធិកមហាវិទ្យាល័យព្រះសីហនុរាជ គណៈកម្មការបុណ្យរៀបរៀង . . . . . . . ១០៧០
- វចនានុក្រមសំស្ក្រឹត-ខ្មែរ (តមក) ព្រះមហា ប៉ាង-ខាត់ រៀបរៀង . . ១០៧៦


ថ្លៃឆ្នាំ មាន ១២ សៀវភៅ ជារៀល ២៣០:០០

# KAMBUJASURIYA

Revue religieuse et littéraire
éditée par l'Institut Bouddhique

sommaire

## Partie religieuse :


— Garavakatha par Preah Maha CHAK-SUVADH . . . 965
— Metta Viharakatha par Preah Balat Sangreak MOUL-HIN . 978
— Sarabajataka (suite) relevé du manuscrit sur feuilles de latanier par M. THANG-VONG . . . . . 985


## Partie littéraire :


— Histoire de Hang-Yon (suite) relevée du manuscrit sur feuilles de latanier par M. IM-PHON . . . . . . . . . 994
— Contes et Légendes du Japon traduits par M. RAY-BUC . 1010
— La femme vertueuse par Yok Vochir revue et corrigée par M. PHENG-CHRIV . . . . . . . . . . . 1026
— Tirer une épine du pied par M. BOU-PO . . . . . . . . 1037
— "Se promener au paradis pour quelques jours" histoire racontée par M. NHOUNG-SOEUNG . . . . . . . . 1045
— Histoire de Marana Mâtâ relevée du manuscrit sur feuilles de latanier par M. By-Sovann . . . . . . . . . 1050
— Histoire de Sam-Kok (suite) traduite par l'Oknha NOU-KAN. 1061


## Notes et Chroniques :


— Bon Phka à l'Université Bouddhique Preah SIHANOUKRAJ 1070
—Dictionnaire Sanskrit-Khmer (suite) par Vén. PANG-KHAT . 1076



Prix d'abonnement annuel (comprenant 12 numéros): 230$00 .

## ផ្នែកសាសនា

# គារវកថា

របស់ព្រះមហា ចក់-សុវណ្ណ វត្តមហាមន្ត្រី

## នមោ ៣ ដង

សូមថ្វាយបង្គំចំពោះព្រះរតនត្រ័យ មានព្រះពុទ្ធជាដើម ដោយទ្វារទាំង ៣ គឺ: កាយទ្វារ ១, វចីទ្វារ ១, មនោទ្វារ ១ ៗ

សូមពណ៌នាអំពីគារវៈ ដែលមានមកក្នុងគម្ពីរអង្គុត្តរនិកាយ ដូចសេចក្តីតទៅនេះ ៖

គារវៈនោះមាន ៦ យ៉ាងគឺ:

១. ពុទ្ធគារវតា គោរពក្នុងព្រះពុទ្ធ,

២. ធម្មគារវតា គោរពក្នុងព្រះធម៌,

៣. សង្ឃគារវតា គោរពក្នុងព្រះសង្ឃ,

៤. សិក្ខាគារវតា គោរពក្នុងសិក្ខា គឺការសិក្សារៀនសូត្រ,

៥. អប្បមាទគារវតា គោរពក្នុងសេចក្តីមិនប្រមាទ,

៦. បដិសណ្ឋារគារវតា គោរពក្នុងបដិសណ្ឋារៈ ៗ

សេចក្តីអធិប្បាយៈ ទី១-ពុទ្ធគារវតា សេចក្តីគោរពចំពោះព្រះពុទ្ធនោះ គឺការញុំាងសទ្ធាសេចក្តីជឿ នឹងសាទរៈសេចក្តីជ្រះថ្លាឲ្យកើតឡើង

ក្នុងព្រះពុទ្ធយ៉ាងដាក់ច្បាស់ ហើយសំដែងខ្លួនជាពុទ្ធមាមកៈ ជាអ្នកកប់ការនូវព្រះពុទ្ធជាម្ចាស់ គឺទទួលយកព្រះពុទ្ធអង្គជាទីពឹងរបស់ខ្លួនដោយត្រៃទ្វារគឺ កាយ វាចា ចិត្ត, ហើយប្រតិបត្តិតាមសាសនា ដែលជាពាក្យប្រៀនប្រដៅរបស់ព្រះអង្គ ដោយសេចក្តីគោរព, តាំងចិត្តខ្ជាប់ថាៈ ព្រះពុទ្ធជាអគ្គបុគ្គលប្រសើរលើសលុបក្នុងត្រៃភពគឺៈ កាមភព, រូបភព, អរូបភព, ព្រះអង្គជាសាស្តាចារ្យនៃពពួកមនុស្ស ទេវតា មារ ព្រហ្មទាំងអស់, មិនតែមនុស្សប៉ុណ្ណោះទេ សូម្បីទេវតានៅឆកាមាវចរសួគ៌ និងទេវតា នៅឯព្រហ្មលោក ក៏តែងគោរពព្រះពុទ្ធទាំងអស់ដែរ ។ ការគោរពយ៉ាងនេះ ចាត់ជាគោរពក្នុងព្រះពុទ្ធម្យ៉ាង, មួយយ៉ាងទៀត ការរឭកដល់គុណព្រះពុទ្ធអង្គមានបទថា អរហំជាដើម និងពុទ្ធបរិយាយឃើញច្បាស់ដោយបញ្ញារបស់ខ្លួនដើម្បីបំរុងសទ្ធា និងសេចក្តីជ្រះថ្លាចំរើនច្រើនឡើងដោយលំដាប់ ហើយកាន់យកជាបែបផែនដើម្បីអនុវត្តន៍តាម ដូច្នេះក៏ចាត់ជាគោរពក្នុងព្រះពុទ្ធ ។ មួយទៀត ការមិនយកព្រះនាមព្រះពុទ្ធមកប្រារព្ធលេង ដោយវោហារត្លុកកំប្លែង ដើម្បីសើចលេងសប្បាយ ដូច្នេះក៏ចាត់ជាគោរពក្នុងព្រះពុទ្ធអង្គដែរ ។

ម្យ៉ាងទៀត ការចូលទៅកាន់បូជនីយដ្ឋាន ដែលជាទីប្រតិស្ឋានបូជនីយវត្ថុផ្សេង ៗ ដូចព្រះស្តូប, ព្រះបដិមាករ, ព្រះចេតិយ, ដែលដំកល់ព្រះសារីរិកធាតុ ហើយសំដែងសេចក្តីគោរពកោតក្រែង

បើពាក់មួកគប្បីដោះចេញ , បើបាំងឆ័ត្រគប្បីដំឡោះចេញ , បើពាក់ស្បែកជើងគប្បីដោះចេញ , ធ្វើសក្ការៈបូជាដោយផ្កាឈើ, ទៀន, ធូប, ឬ គ្រាប់សំពះថ្វាយបង្គំ ដូច្នេះក៏ចាត់ជាគោរពក្នុងព្រះពុទ្ធអង្គដែរ ។ មួយវិញទៀត ដោយហេតុដែលព្រះបរមសាស្ដាចារ្យ កាលជិតនឹងបរិនិព្វានបានត្រាស់ថា ម្នាលអានន្ទ! ធម៌វិន័យដែលតថាគតសំដែងទុកហើយបានបញ្ញត្តទុកហើយ ដល់អ្នកទាំងឡាយ លុះតថាគតបរិនិព្វានទៅហើយ ធម៌វិន័យនោះនឹងជាសាស្ដាចារ្យនៃអ្នកទាំងឡាយ ។ ព្រោះហេតុនេះ ទើបឃើញថា ការគោរពក្នុងព្រះពុទ្ធអង្គក៏ជាប់ទាក់ទងដល់ការគោរពក្នុងព្រះធម៌នោះឯង ។

ទី២-ធម្មគារវតា គោរពក្នុងព្រះធម៌នោះ បានដល់ការសិក្សារៀនសូត្រប្រតិបត្តិចំរើនភាវនា ដោយមិនមានសេចក្ដីប្រមាទប្រហែសធ្វេសក្នុងការសិក្សា ប្រតិបត្តិចំរើនភាវនានោះ ឈ្មោះថាសិក្សាប្រតិបត្តិចំរើនភាវនាដោយគោរព ។

ឯពាក្យថា ធម៌នោះតាមន័យព្រះបរមត្ថសំដែងថាមាន ១០ ប្រការគឺៈ សោតាបត្តិមគ្គ ១, សោតាបត្តិផល ១ ។ល។ ព្រះនិព្វាន១ ថែមព្រះបរិយត្តិ ១ ទៀតជាគំរប់ ១០ ។

ចំណែកធម៌ ៩ ខាងដើមហៅថាលោកុត្តរធម៌ ឯលោកុត្តរធម៌នេះយោគាវចរអាចនឹងឈោងចាប់ស្រង់យកដោយការសិក្សា ដោយគោរព

មិនមែនប្រតិបត្តិស្មើ ៗ ចំរើនភាវនាដោយស្មើៗ នោះទេ លុះណាតែមានឧបនិស្ស័យចាស់ក្លា ថែមទៀតផង ទាំងចំរើនភាវនាដោយគោរពក្រៃលែងណាស់ ទើបអាចឈានចាប់ស្រវាយកនូវបណ្ដាមគ្គផលទាំងឡាយ មានសោតាបត្តិមគ្គជាដើម មានព្រះនិព្វានជាទីបំផុតបានដោយងាយ ៗ ឯព្រះបរិយត្តិធម៌ជាធម៌ដែលព្រះបរមសាស្ដាទ្រង់ត្រាស់សំដែងទុកមកដើម្បីប្រយោជន៍ដល់ពួកវេនេយ្យសត្វរៀនយកដោយគោរព គឺយកចិត្តទុកដាក់ ៗ បរិយត្តិធម៌នេះ ចែកជាខន្ធមាន ៨៤.០០០ ព្រះធម្មក្ខន្ធ បណ្ដាធម៌ទាំងនេះ បើបុគ្គលមិនបានសិក្សារៀនសូត្រដោយគោរពទេ ក៏មិនអាចនឹងបើកយានជូនបុគ្គលនោះ ឲ្យជាអ្នកចេះដឹងឬឲ្យរួចចាកទុក្ខបានទេ ៗ លុះណាតែបុគ្គលព្យាយាមប្រឹងប្រែងសិក្សារៀនសូត្រដោយសេចក្ដីគោរពផង ទើបអាចយកយានបុគ្គលនោះឲ្យរួចចាកទុក្ខទាំងពួងបាន ៗ ឯធម៌ទាំង១០យ៉ាងហៅថាពុទ្ធសាសនា ព្រោះសុទ្ធតែជាពាក្យប្រៀនប្រដៅរបស់ព្រះពុទ្ធ ឯសាសនានេះនឹងរុងរឿងថ្កុំថ្កាឡើង ក៏អាស្រ័យនូវបរិស័ទទាំង៤ គឺ ភិក្ខុ, សាមណេរ, ឧបាសក, ឧបាសិកា រៀនធម៌ដោយគោរព, ទ្រទ្រង់ដោយគោរព, ពិចារណានូវធម៌ដោយគោរព, បើមិនបានប្រតិបត្តិតាមធម៌ ៤ ស្ថាននោះដោយគោរពទេ សាសនាមិនរុងរឿងបាន មានតែសាបសូន្យទៅវិញមិនខាន ៗ មួយទៀត កិរិយាស្ដាប់ធម៌ដោយគោរពនេះឯង រមែងជាឧបនិស្ស័យ

ដល់មនុស្សទេវតា, ជាទីបំផុតចុះមកដល់សត្វតិរច្ឆាន ក៏មានទំនុបនិស្ស័យដែរ (ដូចមាននិទានមេមាន់១ នៅក្នុងគម្ពីរមង្គលសូត្រឯណោះស្រាប់) ។

ម្យ៉ាងទៀត ធម្ម: សព្ទនេះ តាមន័យអដ្ឋកថា ព្រមទាំងដីកាលោកប្រែថា ទ្រទ្រង់ ថា ស្ទួយឡើង ។

អធិប្បាយថា: សភាវៈណាធ្វើនូវសត្វទាំងឡាយដែលទ្រទ្រង់នូវទុក ហើយទ្រទ្រង់នូវសត្វទាំងឡាយនោះ មិនឲ្យលិចធ្លាក់ចុះក្នុងអបាយទាំងឡាយ៤ផង ក្នុងវដ្តទុក្ខទាំងឡាយផង, សភាវៈនោះបានឈ្មោះថា ធម្ម: ពិត, គឺបុគ្គលណាបានទ្រទ្រង់ធម៌ល្អ រក្សាធម៌ឲ្យល្អហើយ វិបាកធម៌ដែលល្អនោះឯងរមែងទ្រទ្រង់រក្សាបុគ្គលនោះឲ្យល្អវិញ មិនឲ្យធ្លាក់ចុះទៅក្នុងអបាយភូមិទាំង ៤ នោះឡើយ ម្យ៉ាងទៀតបុគ្គលណាបានទ្រទ្រង់នូវធម៌ដ៏ខ្ពង់ខ្ពស់វិសេសបំផុតក្នុងសន្តានខ្លួនល្អហើយ ធម៌ដ៏ខ្ពង់ខ្ពស់នោះនឹងទ្រទ្រង់បុគ្គលនោះឲ្យស្ថិតនៅក្នុងឋានៈដ៏ខ្ពង់ខ្ពស់វិសេសបំផុត គឺព្រះនិព្វានជាសុខក្សេមក្សាន្តពុំបានឲ្យធ្លាក់ចុះទៅក្នុងវដ្តទុក្ខទាំងឡាយនោះឡើយ ។

ទី៣- សង្ឃគារវតា គោរពក្នុងព្រះសង្ឃ ។ ព្រះសង្ឃនោះសំដៅយកពួកសាវក លោកបានធម៌វិសេសផ្សេងគ្នាដោយប្រភេទជាព្រះសោតាបន្ន ព្រះសកទាគាមី ព្រះអនាគាមីនឹងព្រះអរហន្ត ពោលដោយបរិយាយយ៉ាងទាប អនុលោមតាមន័យនេះសូម្បីសម្មតិសង្ឃដែលលោកមានសីលបរិសុទ្ធិ មានមារយាទស្ងប់ស្ងៀម មានឥន្ទ្រិយស្រគត់ស្រគំ

មានគុណធម៌គួរគោរព ដែលមានសភាពបែបនេះក៏ឈ្មោះថាសង្ឃ ។ ឯការគោរពក្នុងព្រះសង្ឃគឺការក្រាបសំពះ ការក្រោកទទួល ការធ្វើអញ្ជលិកម្ម ការធ្វើសាមីចិកម្ម រហូតដល់ការអើពើផ្សេងៗ ដូចជឿតាមពាក្យប្រៀនប្រដៅរបស់លោក, ប្រតិបត្តិតាមឱវាទរបស់លោក មិនសំដែងអាការមើលងាយដូច្នេះជាដើម ចាត់ជាគោរពក្នុងព្រះសង្ឃ ។

ទី ៤- សិក្ខាគារវតា គោរពក្នុងសេចក្តីសិក្សា ។ ការតាំងចិត្តសូត្ររៀនទាំងពីរផ្លូវ គឺផ្លូវធម៌នឹងផ្លូវលោក មិនខ្ជិលច្រអូស ខំប្យាហ៍ស្តាប់ច្រើន មើលច្រើន បើមិនចូលចិត្តសេចក្តីកក់ជ្រៅត្រង់ណា គប្បីសួរដណ្តឹងលោកអ្នកប្រាជ្ញដែលចេះដឹងត្រង់ណោះ បើចូលចិត្តជាក់ច្បាស់គួរកំណត់ទុកក្នុងចិត្ត ឬសរសេរកត់ទុកក្រែងភ្លេចភ្លាំងមានច្បាប់ស្រាប់ ដូច្នេះចាត់ជាគោរពក្នុងការសិក្សា ។ បើពោលដល់ប្រយោជន៍ការសិក្សាជារបស់សំខាន់បំផុតទាំងក្នុងគតិលោក ទាំងក្នុងគតិធម៌ ការសិក្សានេះជាគុណសម្បត្តិមួយ ដែលគេនិយមរាប់អានទូទៅទាំងស្រុក-ប្រទេស សូម្បីជាតិ សាសន៍ណាក៏ដោយ គេតែងតែរាប់អានការសិក្សានេះដែរ, ហើយខំសិក្សាសូត្រ-រៀនឲ្យបានចេះដឹងជ្រៅជ្រះឡើង ឲ្យបានជាអ្នកគង់អាចសីហនាទក្លាហាន ក្នុងទីប្រជុំជនធំៗ អាចនឹងជួយស្រោចស្រង់សង្គ្រោះដល់ប្រជាជាតិមាតុភូមិរបស់ខ្លួន ឲ្យបានរួចអំពីគ្រោះថ្នាក់យ៉ាងធ្ងន់គឺសេចក្តីល្ងង់ខ្លៅ ឲ្យឡើងកាន់ភាពជាអ្នកចេះដឹង ឲ្យជាអ្នកមានប្រាជ្ញាហៅហាន ចរចារគ្នាគាំពារសេចក្តីសាមគ្គីឲ្យល្អ អាចនឹងញុំាងជាតិ

សាសនា ព្រះមហាក្សត្រិយ៍របស់ខ្លួន ឲ្យបានរុងរឿងថ្លៃថ្លាប្រសើរ ឈានទៅកេអារ្យធម៌ទំនើបឡើងធម៌ជាន់ខ្ពស់ទំនឹងគេ ទៅតាមកាលសម័យថ្មីនេះឯង ។ ការសិក្សាយ៉ាងនេះ ហៅថាសិក្សាដើម្បីប្រយោជន៍ដល់ប្រទេសជាតិចាត់ជាការគោរពដ៏ឧត្តម ម្យ៉ាងទៀតបុគ្គលដែលខំសិក្សាដើម្បីការៈនៃខ្លួនថាពហុស្សុត បេះចាំនូវពាក្យពេចន៍របស់ព្រះសម្ពុទ្ធជាម្ចាស់ បុគ្គលនោះ ទោះបើមិនបរិបូណ៌ដោយគោតសម្ប័ទ ក៏បានហៅថាជាអ្នកមិនក្រលំបាកដោយការចិញ្ចឹមជីវិត មិនប្រាសចាកប្រយោជន៍ដ៏ល្អទេ ទោះទីដ៏ចូលទៅសមាគមណា រមែងជាទីកប់អាននៃជនទាំងឡាយ ព្រោះមានសេចក្តីក្លៀវក្លាតអង់អាចក្លាហានក្នុងការនិយាយស្តី មានបញ្ញាដឹងអត្ថដឹងធម៌ នាំខ្លួនឲ្យតាំងនៅក្នុងសម្មាបដិបត្តិជាសប្បុរស ហើយប្រកបក្នុងសារប្រយោជន៍ ។ ហេតុដូច្នេះ សម្តេចព្រះបរមសាស្តា ទ្រង់សរសើរគុណធម៌គឺៈ ពហុបច្ចៈនេះជាច្រើនប្រការ ។ បុគ្គលជាពហុស្សុត មានធម៌បានស្តាប់បានរៀនហើយដោយច្រើន ទ្រទ្រង់ធម៌ដែលបានស្តាប់បានរៀននោះ មានធម៌ដែលស្តាប់ដែលរៀនហើយសន្សំទុក, ធម៌ណាដែលពីរោះក្នុងខាងដើម ពីរោះក្នុងកណ្តាល ពីរោះក្នុងទីបំផុត ប្រកាសព្រហ្មចរិយៈ ព្រមទាំងអត្ថទាំងព្យញ្ជនៈ បរិសុទ្ធបរិបូណ៌អស់ដើង ធម៌ទាំងអម្បាលនោះ បុគ្គលបានស្តាប់បានរៀនហើយដោយច្រើន បានសំឡឹងពិចារណា ហើយចិត្តក៏បានចាក់ធ្លុះចំពោះធម៌ ជាគុណប្រយោជន៍

ធ្វើបុគ្គលនោះឲ្យជាទីពឹងអាស្រ័យនៃសព្រហ្មចារីទាំងឡាយ ការសិក្សាមានគុណានុភាពបែបនេះ ទើបលោកប្រដៅឲ្យគោរពក្នុងសិក្ខា ។

ទី ៥. អប្បមាទគារវតា គោរពក្នុងសេចក្តីមិនប្រមាទ ។ សេចក្តីមិនប្រមាទនេះ គឺធម៌ជាសត្រូវដល់សេចក្តីប្រមាទ ដោយអត្ថថា បានដល់កិរិយាដែលមិនទៅប្រាសចាកសតិ គឺកិរិយាដែលមិនវង្វេង ឈ្មោះថាសេចក្តីមិនប្រមាទ គោរពក្នុងសេចក្តីមិនប្រមាទនោះ គឺបំពេញសេចក្តីមិនប្រមាទឲ្យបរិបូណ៌ក្នុងសន្តាន ដោយអធិប្បាយថា មិនស្រវឹងក្នុងលាភ យស សរសើរ សុខ ក្នុងវ័យ ក្នុងសេចក្តីមិនមានរោគ ក្នុងជីវិតជាដើម ចាត់ជាគោរពក្នុងសេចក្តីមិនប្រមាទ ។

ម្យ៉ាងទៀត ធ្វើសេចក្តីមិនប្រមាទក្នុងការលះសេចក្តីអាក្រក់ មិនប្រមាទក្នុងការបំពេញសេចក្តីល្អ ទាំងពីរនេះមានសេចក្តីអធិប្បាយថា ការមិនប្រមាទក្នុងការលះនោះ សេចក្តីថា អំពើណា ៗ ប្រព្រឹត្តទៅដើម្បីខូចប្រយោជន៍ខ្លួនទីងអ្នកដទៃ អំពើនោះ ៗ ជាអំពើគួរលះ; ពោះបីបន្តិចបន្តួចក៏មិនត្រូវប្រមាទឡើយ ។

សមដូចសុភាសិតដែលព្រះមានព្រះភាគទ្រង់ត្រាស់សំដែងថា :

មាវមញ្ញេថ បាបស្ស ន មន្តំ អាគមិស្សតិ
ឧទពិន្ទុនិបាតេន ឧទកុម្ភោបិ បូរតិ
បូរតិ ពាលោ បាបស្ស ថោកំ ថោកំបិ អាចិនំ ។

សេចក្តីថា: បុគ្គលមិនគួរមើលងាយបាបថា បាបមានប្រមាណតិចនឹងមិនឲ្យផលឡើយ, ស្ដូវក្ដមទឹកដែលគេបើកមាត់ចំហទុកក្នុងទីវាល ក៏រមែងពេញដោយដំណក់ទឹកភ្លៀងដែលធ្លាក់ពីលើអាកាសចុះមកបន្តិចម្តង ៗ ពេញបានយ៉ាងណាមិញ, មនុស្សពាលកាលបើសន្សំបាបសូម្បីបន្តិចម្តង ៗ ក៏ពេញដោយបាបបាន យ៉ាងនោះដែរ ។

ចំណែកខាងអ្នកមិនប្រមាទក្នុងការបំពេញសេចក្តីល្អនោះ អធិប្បាយថា អំពើណា ៗ ដែលប្រព្រឹត្តទៅដើម្បីប្រយោជន៍ខ្លួននឹងអ្នកដទៃ អំពើនោះ ៗ ជាអំពើគួរបំពេញគួរចំរើន ទោះបីបន្តិចបន្តួចក៏មិនត្រូវប្រមាទឡើយ, ដ្បិតមានសុភាសិតនៃព្រះមានព្រះភាគទ្រង់ប្រដៅថា:

មាវមញ្ញេថ បុញ្ញស្ស ន មន្តំ អាគមិស្សតិ
ឧទពិន្ទុនិបាតេន ឧទកុម្ភោបិ បូរតិ
បូរតិ ធីរោ បុញ្ញស្ស ថោកំ ថោកំបិ អាចិនំ ។

សេចក្តីថា: បុគ្គលមិនគួរមើលងាយបុណ្យថា បុណ្យមានប្រមាណតិចនឹងមិនឲ្យផលឡើយ ប្រៀបដូចក្អមទឹករមែងពេញបានដោយដំណក់ទឹកដែលធ្លាក់ចុះយ៉ាងណា, អ្នកមានប្រាជ្ញាកាលសន្សំនូវបុណ្យបន្តិចម្តង ៗ គង់ពេញបានដោយបុណ្យនោះដែរ ។

ការប្រើនិយោគគ្រប់យ៉ាងខាងជាសេចក្តីគោរពក្នុងសេចក្តីមិនប្រមាទ ម្យ៉ាង ។

មួយវិញទៀត ព្រះសយម្ភូញាណជាម្ចាស់ទ្រង់ត្រាស់ឲ្យលះកាយទុច្ចរិត, វចីទុច្ចរិត, មនោទុច្ចរិត, កុំឲ្យប្រមាទក្នុងការលះទុច្ចរិតទាំងនោះ ឲ្យធ្វើកាយសុចរិត, វចីសុចរិត, មនោសុចរិត ឲ្យកើតមានឡើង កុំឲ្យប្រមាទក្នុងការចំរើនសុចរិតទាំងនោះ ។ សេចក្តីមិនប្រមាទនេះ បើពោលតាមសេចក្តី ក៏គឺមានសតិបរិបូណ៌មិនប្រាសចាកសតិសម្បជញ្ញៈ សមដូចព្រះពុទ្ធដីកានៃព្រះមានព្រះភាគជាម្ចាស់ត្រាស់ថា ចតូសុ ភិក្ខវេ ឋានេសុ អត្តរូបេន អប្បមាទោ សតិ ចេតសោ អារក្ខា ករណីយោ ម្នាលភិក្ខុទាំងឡាយ! សេចក្តីមិនប្រមាទគឺសតិ, ជាធម៌រក្សាទុកនូវចិត្តជាធម្មជាតដែលអ្នកទាំងឡាយត្រូវធ្វើ ក្នុងទី ៤ ស្ថាន តាមសមគួរដល់ខ្លួន សេចក្តីមិនប្រមាទដែលអ្នកទាំងឡាយត្រូវធ្វើក្នុងទី៤ស្ថាននោះ គឺ ១– ចិត្តរបស់អាត្មាអញកុំត្រេកត្រអាលក្នុងធម៌ដែលជាហេតុឲ្យកើតសេចក្តីត្រេកត្រអាល ; ២– ចិត្តរបស់អាត្មាអញកុំប្រទូស្តក្នុងធម៌ដែលជាហេតុឲ្យកើតសេចក្តីប្រទូស្ត; ៣– ចិត្តរបស់អាត្មាអញកុំវង្វេងក្នុងធម៌ដែលជាហេតុឲ្យកើតសេចក្តីវង្វេង; ៤ ចិត្តរបស់អាត្មាអញកុំស្រវឹងក្នុងធម៌ដែលជាហេតុឲ្យកើតសេចក្តីស្រវឹង ។ កាលបើពោលដោយសេចក្តីប្រតិបត្តិជាឧបការៈដល់សេចក្តីមិនប្រមាទនោះក៏គឺមនសិការៈ (ធ្វើទុកក្នុងចិត្ត) ដល់ខយវយធម៌ ។ បុគ្គលនឹករំពឹងដល់សេចក្តីសូន្យនៃសង្ខារដោយអំណាចចាស់ ឈឺ ស្លាប់ក្តី, នឹករំពឹងថា ឱ! សេចក្តីចាស់ ឈឺ ស្លាប់

ជាភ័យក្រៃពេកទ្រាំទ្រចូលកាន់តែជិតមកហើយ ដូច្នេះគួរ តអំពីនោះទៅ ទើបមិនប្រមាទទំនុកឃ្លាតបំពេញកុសលឲ្យកើតឡើងក្នុងសន្តាន ។ ព្រោះហេតុនោះបានជាព្រះបរមសាស្តាជាម្ចាស់ កាលទ្រង់ត្រាស់ដាស់តឿនពុទ្ធបរិសទ័មិនឲ្យប្រមាទក្នុងកាលដែលព្រះអង្គទៀបបរិនិព្វានថា ហន្ទទានិ ភិក្ខវេ អាមន្តយាមិ វោ ម្នាលភិក្ខុទាំងឡាយ ! តថាគតដាស់តឿនអ្នកទាំងអស់គ្នា វយធម្មា សង្ខារា សង្ខារទាំងឡាយមានសេចក្តីសូន្យជាធម្មតា, អប្បមាទេន សម្បាទេថ អ្នកទាំងឡាយចូរញុំាងប្រយោជន៍ឲ្យសម្រេចដោយសេចក្តីមិនប្រមាទចុះ ។ មួយវិញទៀត ពោលដោយអត្ថ កាលទ្រង់ប្រកបកិច្ចការណាមួយទាំងផ្លូវលោកទាំងផ្លូវធម៌ មិនប្រាសចាកសតិឡើយ គឺនៅសព្វកាលវេលា នេះចាត់ជាគោរពក្នុងសេចក្តីមិនប្រមាទ ។

ទី ៦- បដិសន្ថារគារវតា គោរពក្នុងបដិសណ្ឋារៈ ។ បដិសណ្ឋារៈនោះបានដល់ការទទួលដោយមេត្រី, ចែកចេញជាពីរប្រការ គឺៈអាមិសប្បដិសណ្ឋារៈ១, ធម្មប្បដិសណ្ឋារៈ១ ។ ការទទួលភ្ញៀវដោយទ្រព្យរបស់ជាការសមគួរដល់ភ្ញៀវដែលមកដល់លំនៅខ្លួន ដូចឲ្យភោជនា-ហារ ទីសំណាក់អាស្រ័យជាដើម ហៅថាអាមិសប្បដិសណ្ឋារៈ ។ ការដែលធ្វើអាមិសប្បដិសណ្ឋារៈនោះ គួរតែឲ្យប្រព្រឹត្តទៅដោយធម៌ ដូចសំដែងខ្លួនតាមគួរសម យ៉ាងដូច្នេះហើយ លើកមុខមាត់ភ្ញៀវដែល

មកនោះដោយសេចក្ដីអើពើដល់ភ្ញៀវក្ដី, ការទូន្មានណា នាំទៅក្នុងផ្លូវល្អក្ដី ហៅថាធម្មប្បដិសណ្ឋារៈ ។ ការគោរពអើពើក្នុងបដិសណ្ឋារៈដល់ភ្ញៀវ ដែលមកទីកន្លែងរបស់ខ្លួន ដោយអាមិសវត្ថុ ដោយធម៌ដូចពោលមក ហើយនោះ ឬគ្រាន់តែប្រាស្រ័យ ដោយពាក្យដែលហៅថា សម្មោ-ទនា គឺនិយាយប្រាស្រ័យឲ្យកើតសេចក្ដីត្រេកអរមានសួរដល់សុខ-ទុក្ខ ជាដើមនេះ ចាត់ជាគោរពក្នុងបដិសណ្ឋារៈ ។ កាលបើពោលដោយអាការៈដែលប្រព្រឹត្តទៅហើយ ការធ្វើបដិសណ្ឋារៈនេះជាប្រពៃណីនិយមតមករបស់បុរាណកបណ្ឌិត សូម្បីក្រៅពុទ្ធសម័យ ពោះបើភ្ញៀវនោះមក ល្អក៏ដោយ អាក្រក់ក៏ដោយ ក៏ឲ្យសំគាល់ឃើញថា ជាកិច្ចដែលត្រូវធ្វើតាមនាទី សេចក្ដីនេះគប្បីឃើញក្នុងរឿងព្រះវេស្សន្តរ ទ្រង់ធ្វើបដិ-សណ្ឋារៈ ដល់ជូជកព្រាហ្មណ៍ដែលមកទូលសូមព្រះរាជកុមារទាំងពីរនៃ សម្ដេចសហស្សនេត្រ ដែលកាឡាកាយ ជាព្រាហ្មណ៍មកទូលសូមនាងមទ្រី ព្រះអង្គក៏ត្រាស់ប្រាស្រ័យឲ្យកើតសេចក្ដីត្រេកអរ ហើយអញ្ជើញឲ្យលាងជើងឲ្យចូលទៅក្នុងអាស្រមបទ ឲ្យបរិភោគផលាផល មធុរសជារបស់ព្រៃបរិភោគ, ឲ្យផឹកវារីថ្លាត្រជាក់ដែលដងមកអំពីជ្រោះភ្នំតាមសេចក្ដីគាប់ចិត្ត ។ លុះដល់មកក្នុងពុទ្ធសម័យ សម្ដេចព្រះសម្មាសម្ពុទ្ធជាម្ចាស់ត្រាស់ប្រដៅឲ្យគោរពក្នុងបដិសណ្ឋារៈដូចគ្នា សូម្បីបព្វជិតក៏ត្រូវធ្វើដែរ

ដូចយ៉ាងអាគន្តុកៈមកដល់ទីសំណាក់ជាទាំងនៃចៅអាវាស ទើងត្រូវទទួលដោយកិច្ចវត្ត ។

បើពោលដោយខ្លីៗ សេចក្ដីគោរពនេះ ជាគុណធម៌មួយដ៏ល្អ ព្រះសម្មាសម្ពុទ្ធជាម្ចាស់ បានត្រាស់ទុកថាជាធម៌ជាគ្រឿងទ្រទ្រង់សាសនាឲ្យរុងរឿងអស់កាលជាអង្វែងទៅបាន គឺថាព្រះពុទ្ធសាសនានឹងគង់ទាប់ឬចំរើនរុងរឿងឡើងក៏ព្រោះសេចក្ដីគោរព នឹងសេចក្ដីមិនគោរពនេះឯងជាហេតុ, សេចក្ដីនេះគប្បីដឹងដោយទេសនាន័យដែលព្រះអង្គទ្រង់ត្រាស់ដល់មហាកស្សបៈប្រារព្ធសេចក្ដីអន្តរធាននៃព្រះសទ្ធម្ម ដែលនឹងមានឡើងក៏ព្រោះភិក្ខុ-ភិក្ខុនី-ឧបាសក-ឧបាសិកា មិនមានសេចក្ដីគោរពកោតក្រែងក្នុងព្រះសាស្ដា ក្នុងព្រះសង្ឃ, ក្នុងការសិក្សា, មិនមានអ្វីដទៃដែលអាចលុបលាងព្រះសទ្ធម្មឲ្យសាបសូន្យទៅបាន ក្រៅអំពីហេតុ គឺសេចក្ដីគោរពនឹងសេចក្ដីមិនគោរពកោតក្រែងនោះឡើយ ព្រោះហេតុដូច្នេះ សាធុជនអ្នកប្រាថ្នាសេចក្ដីចំរើនដល់ជាតិ-សាសនា- ព្រះមហាក្សត្រ ប្រាថ្នាសេចក្ដីចំរើនដល់ខ្លួន គប្បីធ្វើសេចក្ដីគោរព ៦ ប្រការនេះចុះ ។

ការពណ៌នាអំពីគារវៈ ចប់ដោយសេចក្ដីសង្ខេបតែប៉ុណ្ណេះ ។

# មេត្តាវិហារកថា

របស់ព្រះបាឡាត់សង្ឃរ័ក្ស ម៉ូល ហ៊ុន វត្តឧណ្ណាលោម

## នមោ ៣ ដង

សូមនមស្ការ ចំពោះព្រះអរហន្តសម្មាសម្ពុទ្ធព្រះអង្គនោះ (ព្រមទាំងព្រះធម៌ និងព្រះអរិយសង្ឃដោយគោរព) ។

មេត្តាវិហារី យោ ភិក្ខុ បសន្នោ ពុទ្ធសាសនេ
អធិគច្ឆេ បទំ សន្តំ សង្ខារូបសមំ សុខំ ។

សេចក្តីថា ភិក្ខុណាមួយមានមេត្តាធម៌ ជឿស៊ប់ក្នុងព្រះពុទ្ធសាសនា ភិក្ខុនោះ គប្បីបាននូវផ្លូវស្ងប់ជាសុខ ជាឧបាយ ជាទីរម្ងាប់បង់នូវសង្ខារ ។

សូមពណ៌នាតាមបាលីពុទ្ធភាសិត ដែលមានក្នុងគម្ពីរខុទ្ទកនិកាយ អដ្ឋកថាធម្មបទ ផ្នែកខាងសុត្តន្តបិដក ដែលព្រះពុទ្ធទ្រង់សំដែងប្រារព្ធចំពោះភិក្ខុជាច្រើនរូប ។ សូមអធិប្បាយបាលីថា « មេត្តា » ជាមុនរួចសឹមអធិប្បាយបាលី ថា មេត្តាវិហារី តទៅ ។

មេត្តា ប្រែថា សេចក្តីរាប់អានជាប់ស្អិត, ស្និទ្ធស្នាល មកអំពីស័ព្ទដើមថា "មិទ:" សមដូចវិគ្គហ:ថា សត្តេសុ ញាណេសុ មេជ្ជតិ សិនេហតីតិ មេត្តា ធម្មជាតណាជាប់ស្អិត រាប់អានស្និទ្ធស្នាល ចំពោះសត្វទាំងឡាយទាំងពួង, ធម្មជាតនោះឈ្មោះថា មេត្តា ។

មេត្តាធម៌នេះ ជាធម៌សំរាប់ធ្វើមនុស្សសត្វ ឲ្យបានទទួលនូវសេចក្តីសុខសម្រាន្តគ្រប់ពេលវេលា , ទុកដូចជាអាវុធមួយក្នុងព្រះពុទ្ធសាសនា សំរាប់ការពារសង្គមរបស់មនុស្សកុំឲ្យមានការបៀតបៀនពីអ្នកដទៃ តាំងជាឱសថដ៏វិសេសសំរាប់បន្សាបនូវពេត្រ គឺ កោធៈ ព្យាបាទៈ ជាដើមឲ្យស្ងប់រម្ងាប់បាន ព្រោះកោធៈ និង ព្យាបាទនេះ ជាឈ្នួនសគ្រាមក្នុងផ្លូវចិត្ត សំរាប់ដុតកំដៅសត្វឲ្យក្តៅក្រហាយអន្ទះអន្ទែង បើក្រៅអំពីទឹក គឺមេត្តានិងខន្តិ មិនងាយរម្ងាប់កំដៅក្នុងផ្លូវចិត្តនេះបានឡើយ ។

មេត្តាធម៌ ជាធម៌សំរាប់កសាងសង្គមមនុស្សឲ្យបានទទួលនូវសេចក្តីសុខ ចំរើនខាងសីលធម៌ , វប្បធម៌ , អារ្យធម៌ មិនថាសង្គមណាឬបក្សណាឡើយ តាំងជាគ្រឿងចងនូវមិត្តភាព សាមគ្គីភាព ក្នុងសង្គម ឬប្រទេសមួយ ៗ ឲ្យបានរឹងប៉ឹងផង ។

មេត្តាធម៌ជាសទ្ធិធម៌ គឺធម៌ស្ងប់សំរាប់ធ្វើចិត្តមនុស្សកុំឲ្យបៀតបៀនព្យាបាទគ្នាទៅវិញទៅមក ។ មេត្តាធម៌ជាធម៌ត្រជាក់ អាចលត់នូវភ្លើងខាងផ្លូវចិត្ត និងផ្លូវកាយបានដោយពិត ។

មេត្តាវិហារី ប្រែថា ភិក្ខុអ្នកនៅដោយមេត្តា បើតាមបាលីពុទ្ធភាសិតនេះ ក៏ហាក់ដូចជាព្រះសម្ពុទ្ធទ្រង់ដាស់តឿនចំពោះតែភិក្ខុ មិនទូទៅដល់គ្រហស្ថទេ ប៉ុន្តែក្នុងទីនេះបានជាព្រះអង្គទ្រង់សំដែងដូច្នោះ ព្រោះមានច្រើនតែភិក្ខុនៅគាល់ស្តាប់ធម៌ទេសនាក្នុងទីនោះ ទើបព្រះអង្គសំដែង

ចំពោះភិក្ខុតែម្តង ៗ ព្រះពុទ្ធជាអ្នកប្រាជ្ញមានព្រះទ័យពោរពេញដោយមេត្តានេះឥតឧបមា ប្រាថ្នាឲ្យសត្វទាំងអស់បានទទួលនូវសេចក្តីសុខ-ចំរើនគ្រប់ ៗ គ្នា ។

ភិក្ខុគួរជាអ្នកមានចិត្តប្រកបដោយមេត្តាគ្រប់ឥរិយាបថទាំង៤គឺ : ដើរ.ឈរ.អង្គុយ.ដេក ពោះដើរក្តី·ឈរក្តី-អង្គុយក្តី-ដេកក្តី គួរតែជាអ្នកក្រាស់ដោយមេត្តាធម៌នេះជានិច្ចឲ្យច្រើនជាងគ្រហស្ថ ព្រោះភិក្ខុអ្នកមានមេត្តាធម៌ រមែងជាអ្នកនៅជាសុខធំទូលាយក្នុងសាសនានេះ ៗ ភិក្ខុណាគ្មានមេត្តាធម៌ទេ, ភិក្ខុនោះរមែងបានខនូវទុក្ខ នាំមកនូវសេចក្តីអផ្សុកក្នុងព្រះពុទ្ធសាសនា ចំពោះខ្លួនឯង ព្រោះក្នុងព្រះសាសនានេះ គួរភិក្ខុមានមេត្តាធម៌ជាសាធារណៈ ។

ប្រជានិករក្នុងប្រទេសនីមួយៗ ឬក៏ក្នុងសកលលោក បើពុំមានមេត្តាធម៌ ប្រាកដជាមានចិត្តប្រកបដោយការបៀតបៀនគ្នាពុំខាន ។ បើជាអ្នកប្រាថ្នាសេចក្តីសុខ-ចំរើន សេចក្តីសរសើរ រុងរឿង គួរតែតាំងចិត្តពោរពេញចំពោះបុគ្គលដទៃ កុំប្រណែនឈ្នានីសគេ គួរតាំងចិត្តប្រ-កបដោយការពេញចិត្តគ្នាទៅវិញទៅមក ត្រូវតាំងចិត្តថា គេស្អប់សេចក្តីទុក្ខ ស្រឡាញ់សេចក្តីសុខ, ស្អប់ក្រ ស្រឡាញ់មាន, ស្អប់សេចក្តីវិនាស ស្រឡាញ់សេចក្តីចំរើន ដូចអាត្មាអញដែរ, គេដូចអញៗដូចគេ ៗ បើបុគ្គលណាផ្តាច់សេចក្តីសុខអំពីអ្នកដទៃ ហើយប្រមូលយក

សុខមកដើម្បីខ្លួន បុគ្គលនោះឈ្មោះថាមិនមានមេត្តាធម៌, ឈ្មោះថាគ្មានមិត្តភាពរវាងមនុស្សសត្វ រហូតដល់លោកទាំងមូល ។ ព្រោះថាផ្ទះមួយៗ ប្រទេសមួយៗ ឬប្រទេសទាំងអស់ក្នុងសកលលោក បើជនក្នុងផ្ទះឬប្រទេសនោះៗ មិនមានមេត្តាធម៌ ប្រាកដជាមិនមានមិត្តភាពរវាងផ្ទះមួយ-ប្រទេសមួយឡើយ បើមិនមានមិត្តភាព រវាងគ្នានឹងគ្នាហើយ សាមគ្គីធម៌ គឺការព្រមព្រៀងក៏មិនមាន, បើការព្រមព្រៀងគ្នាមិនមានហើយ សេចក្តីសុខរបស់ជនក្នុងផ្ទះ-ប្រទេសនោះៗ ក្នុងលោកនេះក៏មិនមាន, បើសេចក្តីសុខក្នុងលោកនេះមិនមានហើយ សេចក្តីសុខក្នុងលោកខាងមុខ ក៏រឹតតែមិនមានទៅទៀត ។

មនុស្សគ្រប់ជាតិក្នុងលោក គួរតែជាអ្នកសម្បូណ៌ដោយមេត្តាធម៌នេះណាស់ គួរបែរមករកកំណប់សុខក្នុងព្រះពុទ្ធសាសនា គួរអនុវត្តតាមសាសនា អប់រំចិត្តដើម្បីឲ្យចិត្តចេះកប់អាណិតចំពោះបុគ្គលដទៃ ដូចខ្លួនយើង ទោះគ្រហស្ថ ឬបព្វជិត ក៏គួរផ្សាយសេចក្តីស្រឡាញ់កប់អាននេះឲ្យរឹតតែរីកចំរើនឡើង ។ បើបុគ្គលដទៃមានជម្ងឺ ទោះគ្រហស្ថ ឬបព្វជិត បើមានថ្នាំសំរាប់កែបំបាត់រោគនោះ គួរតែដាក់ទានដល់បុគ្គលដែលមានជម្ងឺនោះ កុំស្តាយស្រណោះឲ្យសោះ ព្រោះការឲ្យនេះជាដួងចិត្តមិត្រមួយដ៏ប្រសើរចាត់ជាគិលានទាន ។ ការឲ្យបែបនេះ ចាត់ចូលក្នុងការសង្គ្រោះចំពោះអ្នកជម្ងឺ ឬអ្នកទទួលគ្រោះថ្នាក់គោកយ៉ាកត្រូវបត្រដួស

ឥតទីពឹងពំនាក់ ដូចសមាគមគិលានសង្គ្រោះនេះ ជាអង្គការជួយជួយផ្តល់នូវសុខភាពដល់ព្រះសង្ឃ ដើម្បីទ្រទ្រង់ព្រះពុទ្ធសាសនា បន្តអាយុសាសនាឲ្យចំរើនរុងរឿងតទៅអនាគត ។ ការសង្គ្រោះចំពោះអ្នកជម្ងឺនេះ អ្នកប្រាជ្ញទាំងឡាយតែងប្រព្រឹត្តឥតដែលខានឡើយ ។ គិលានសង្គ្រោះដែលពុទ្ធបរិស័ទធ្វើមកនេះ ជាសាខានៃមេត្តាធម៌ដោយពិត ។

មេត្តាធម៌នេះ មុនដំបូងលោកឲ្យចំរើនចំពោះអ្នកមានគុណមានមាតាបិតាជាដើម បន្ទាប់មកត្រូវចំរើនចំពោះបុគ្គលជាកណ្តាល ដែលមិនជាទីស្រឡាញ់ មិនស្អប់សិន រួចទើបត្រូវចំរើនចំពោះបុគ្គលដែលយើងធ្លាប់ស្អប់ ដករបតែចិត្តនោះរលាយការស្អប់ លែងមានឆាករទៅរកការស្អប់ទៀត ។

មេត្តាធម៌អាចហុចអានិសង្សដល់បុគ្គលអ្នកចំរើន ១១ ប្រការគឺ:

១. សុខំ សុបតិ អ្នកមានមេត្តាធម៌តែងដេកជាសុខ,

២. សុខំ បដិពុជ្ឈតិ អ្នកមានមេត្តាធម៌តែងភ្ញាក់ឡើងជាសុខ,

៣. ន បាបកំ សុបិនំ បស្សតិ អ្នកមានមេត្តាធម៌ តែងមិនឃើញសុបិនអាក្រក់ ដោយហេតុណាមួយ,

៤ មនុស្សានំ បិយោ ហោតិ តែងជាទីស្រឡាញ់នៃមនុស្សទាំងឡាយច្រើនប្រទេស,

៥-អមនុស្សានំ បិយោ ហោតិ រមែងជាទីស្រឡាញ់នៃពួកអមនុស្ស គឺពួកបិសាចកជកូន គឺមិនអាចបៀតបៀនបុគ្គលអ្នកមានមេត្តាធម៌,

៦.ទេវតា រក្ខន្តិ ទេវតាតែងរក្សាបុគ្គលអ្នកមានមេត្តាធម៌,

៧.នាស្ស អគ្គិ វា វិសំ វា សត្ថំ វា កមតិ ភ្លើងក្តី ថ្នាំពិសក្តី គ្រឿងសាស្ត្រាក្តី មិនឆេះ មិនពុល មិនមុត បុគ្គលអ្នកមានមេត្តាធម៌,

៨.តុវដំ ចិត្តំ សមាធិយតិ ចិត្តរមែងតាំងនៅមាំ,

៩-មុខវណ្ណោ វិប្បសីទតិ ទឹកមុខរមែងស្រស់បស់,

១០.អសម្មូឡ្ហោ កាលំ ករោតិ ធ្វើមរណកាលទៅ មិនវង្វេង,

១១. ឧត្តរិ អប្បដិវិជ្ឈន្តោ ព្រហ្មលោកូបគោ ហោតិ បើមិនទាន់បានសំរេចមគ្គផលទេ រមែងទៅកើតក្នុងព្រហ្មលោកមិនខាន ។

បុគ្គលអ្នកចំរើនមេត្តាធម៌ រមែងបានទទួលអានិសង្សទាំង ១១ ប្រការ ដូចរៀបរាប់ខាងលើនេះយ៉ាងជាក់ស្តែង, មិនតែប៉ុណ្ណោះ ឈ្មោះថាជាអ្នកមានចិត្តជឿស៊ប់ក្នុងព្រះពុទ្ធសាសនា, ព្រោះហេតុដូច្នោះបានជាព្រះពុទ្ធព្រះអង្គទ្រង់ត្រាស់សំដែងបញ្ជាក់ អំពីអានិសង្សរបស់បុគ្គលអ្នកចំរើនមេត្តាធម៌ថា: បុគ្គលអ្នកចំរើនមេត្តាធម៌រមែងបានជួបប្រទះនូវសេចក្តីសុខ ជាផលស្ងប់ ជាទីរលត់បង់នូវសង្ខារបាន ជាសេចក្តីសុខឥតប្រែប្រួល គឺព្រះនិព្វាន ។

សង្ខារូបសមៈ ក្នុងបាលីពុទ្ធភាសិតនេះ អដ្ឋកថាប្រាប់ថា ព្រះនិព្វានៗ ភិក្ខុដែលបានមគ្គផលនិព្វាន ក៏ព្រោះតែមានមេត្តាធម៌ ឬថាមានធម៌នេះជាជំហរ ឬស្ពានសំរាប់ឆ្លងទៅកាន់ព្រះនិព្វាន ។ ក្នុងព្រះពុទ្ធសាសនានេះ ព្រះពុទ្ធទ្រង់ជាកំពូលអ្នកប្រាជ្ញក្នុងសកលលោក ត្រាស់សរសើរចំពោះបុគ្គលអ្នកមានមេត្តាធម៌នេះណាស់ ព្រោះថា មនុស្សយើង ទោះបីជេះដឹងមានបុព្វានុភាពពូកែយ៉ាងណាក៏ដោយ ប៉ុន្តែបើបុគ្គលនោះឯង ពុំមានមេត្តាធម៌ក៏ឈ្មោះថា មិនមានសេចក្តីសង្គ្រោះដល់អ្នកដទៃ ទឹងអាចធ្លាក់ទៅជាអ្នកបៀតបៀនគេ ធ្វើឲ្យគេវិនាស ឲ្យគេសាបសូន្យ ចង់ឲ្យថ្កុំថ្កើងរុងរឿង តែខ្លួន ឬ គ្រួសារខ្លួន ឬក៏បានសុខតែម្នាក់ឯងប៉ុណ្ណោះទៅវិញ មិនសន្មតថា ជាអ្នកប្រាជ្ញដោយមេត្តាពុំទាន់បានឡើយ ។

ការសង្គ្រោះចំពោះសមណៈមានអាពាធ ឬគ្រហស្ថដែលមានជម្ងឺនេះ ទុកថាជារូបភាពនៃមេត្តាធម៌ដោយពិត ។

មេត្តាវិហារកថា សន្មតថាចប់ដោយសង្ខេប ។

សូមព្រះពុទ្ធសាសនារីកផ្សាយទូទៅពេញសកលលោក !

សូមកម្ពុជជនប្រកបដោយសុភមង្គលគ្រប់ប្រការ !

សូមសកលលោកប្រកបដោយសន្តិភាព !

# សុរពជាតក

(តមក)

លោក ជង–វង ចម្លងពីសាស្ត្រស្លឹករឹត

---

រីឯចៅកាពស លុះសួរបន្ទួនសព្វគ្រប់ហើយ មកកាន់អាពមវិញបានពីរបីថ្ងៃ គិតដល់មាស ទើបបើកហិបមើល រើសថ្នាំចេញឃើញទង់ដែង ពុំឃើញមាសឡើយ ទើបគិតថា « ប្រាកដជាកុដុម្ពិកនេះ លួចយកមាសអញ ហើយយកទង់ដែងមកដាក់ជំនួស សច្ចាហំ តំ បុច្ឆិស្សាមិ បើអញមិនសួរឥឡូវ កាលណាគាត់ខឹងទទួលដឹង គួរអញកុំសួរឡើយ ត្រូវរកឧបាយផ្សេងទៀត » គិតដូច្នោះហើយ ក៏ហៅកុដុម្ពិកនោះមកប្រាប់ថា ម្នាលឧបាសក ! ឥឡូវ អាត្មាមានបំណងចង់ទៅសួរញាតិឯណោះ ចូរអ្នកអនុគ្រោះឲ្យបុត្រអ្នកទៅនឹងអាត្មា ចំនួនពីរបីថ្ងៃនឹងវិលមកវិញ ឯហិបនេះ អាត្មាសុំផ្ញើទុកនឹងអ្នកទៀត ។ កាលនោះ កុដុម្ពិកមានសេចក្ដីជឿនិងធ្លល់ក្នុងចិត្ត ទើបលើហិបទៅទុកក្នុងផ្ទះ នាំកូនទៅប្រគេនព្រះសុទត្ត-សមណៈនោះ ។ ឯព្រះសុទត្តសមណៈនាំកូននោះទៅផ្ទះញាតិរបស់លោក ដំណាលប្រាប់ញាតិសព្វគ្រប់ ផ្ញើកូនទុកនៅទីនោះ ហើយចាប់ស្វាព្រៃមួយមកប្រដៅឲ្យដឹងភាសាមនុស្ស នាំមកកាន់អាពមវិញ លុះនាំស្វាមកដល់ប្រាប់កុដុម្ពិកនោះថា ហៃឧបាសក ! អាត្មានាំកូនអ្នកទៅដល់

ព្រៃមួយ កូនអ្នករើសស្លឹកឈើស៊ី ឥឡូវរូបពងក៏ខុសពីមនុស្សទៅ អាត្មាមានសេចក្ដីភិតភ័យ បានជានាំមកឲ្យអ្នកវិញ ៗ កុដុម្ពិកមានចិត្តតក់ស្លុតក៏ស្រដីថា បពិត្រលោកម្ចាស់ ! លោកម្ចាស់នាំយកមនុស្សទៅ ហេតុអ្វីក៏ក្លាយទៅជាស្វាវិញ ; យល់ខុសប្រែពណ៌ពីបុរាណពេកណាស់ ៗ ទើបព្រះសុខត្តសមណៈស្រដីថា ម្នាលឧបាសក ! មនុស្សក្លាយខ្លួនទៅជាស្វាព្រោះអំពើអកុសលទេតើ ! សចេ ឯ សទ្ទហសិ ថាបើ អ្នកមិនជឿអាត្មា ចូរអ្នកសួរម្ចាស់ខ្លួនចុះ ៗ ទើបកុដុម្ពិកសួរស្វាថា ត្វំ មម បុត្តោសិ ម្នាលពានរ ! អ្នកជាកូនរបស់យើងឬ ? ៗ ពានរឆ្លើយថា អាម បុត្តោស្មិ បពិត្រអ្នកជាឪពុក ! ខ្ញុំនេះជាកូននៃអ្នក ៗ កុដុម្ពិកលុះឮស្វាថាដូច្នោះ ឥតមានសេចក្ដីសង្ស័យអ្វីឡើយ ជឿជាក់ថាជាកូនមែន ក៏កើតទុក្ខទោមនស្សទួញយំដោយប្រការផ្សេងៗ គាល់តែសន្ទប់បាត់ស្មារតី លុះដឹងខ្លួនវិញសួរព្រះសុខត្តសមណៈថា បពិត្រលោកម្ចាស់ ! អកុសលខ្ញុំម្ចាស់បានធ្វើដូចម្ដេច ? បានជាកូនខ្ញុំម្ចាស់ជាមនុស្ស ប្រែខ្លួនក្លាយទៅជាស្វាដូច្នោះ តើមានពេទ្យណា ចេះធ្វើឲ្យប្រែទៅជាមនុស្សវិញបានដែរឬ ? បើព្រះគុណម្ចាស់ដឹង មេត្តាប្រាប់ខ្ញុំម្ចាស់ផង ៗ តេសំ កថេន្តានំ នាកាលអ្នកទាំងពីរកំពុងនិយាយគ្នាដូច្នោះ, កាលនោះ ព្រះបរមពោធិសត្វ ព្រះអង្គមកដល់អាវាសនុះ គង់នៅក្រោមដើមឈើមួយ ឮសម្លេង

កុដុម្ពិកក៏ពុនយំ ទើបចូលទៅកាន់សំណាក់ព្រះសុទត្តសមណៈ នមស្សការហើយអង្គុយនៅ ។ ឯព្រះសុទត្តសមណៈឃើញអាការរបស់ព្រះបរម-ពោធិសត្វ ប្រកបដោយលក្ខណៈ៣២ និងអនុព្យញ្ជនៈ៨០ បរិបូណ៌ ក៏ដឹងថា ព្រះមហាបុរសនេះ គាត់មានប្រាជ្ញាអាចពិភាក្សាក្តីរបស់អញបាន គួរអញសុំដែនហេតុទាំងពួងឲ្យគាត់ដឹង គិតដូច្នោះហើយ ទើបផ្តំណាលប្រាប់ ហេតុដែលឈ្លោះប្រកែកគ្នាថា មហាបុរស មិត្រមហាបុរស ! ចូរអ្នកជួយពិចារណាក្តីរបស់យើងទាំងពីរនេះ ។ ទើបព្រះបរមពោធិសត្វសួរចំពោះកុដុម្ពិកថា ម្នាលកុដុម្ពិក ! ដំណើរដើមដូចម្តេច ? ចូរអ្នកប្រាប់យើងដោយត្រង់មក សោភ តាបេះ តាបសិ កុដុម្ពិកក៏ប្រាប់តាមដំណើរ ។ រីឯព្រះបរមពោធិសត្វជ្រាបហើយរំពឹងគិតថា រីមនុស្សដែលប្រែទៅជាបក្សីពោននេះ មានទះបីប្រព្រឹត្តអំពើទុស្សីមួយ , ហើយសួរទៅព្រះសុទត្តសមណៈវិញ ។ ឯព្រះសុទត្តសមណៈក៏ប្រាប់តាមដំណើរតាំងពីដើមមកដែរ ។ ទើបព្រះមហា-បុរសពិចារណាថា :

" បើផ្លូវត្រង់ រីមនុស្សអ្នកដើរក៏ត្រង់ ថាបើផ្លូវវៀចមនុស្សអ្នកដើរក៏វៀចទៅតាមផ្លូវដែរ ; បើមាសសុទ្ធសាធអាចក្លាយទៅជាទង់ដែងបាន មនុស្សក៏អាចក្លាយទៅជាសត្វស្វាបានដូចគ្នា, នេះមកពីមនុស្សប្រព្រឹត្តអំពើវៀចវេរ " ។

ព្រះអង្គទ្រង់ពិចារណាដូច្នោះហើយ ទើបត្រាស់សួរទៅកុដុម្ពិកនោះថា ម្នាលកុដុម្ពិក ! ឯមនុស្សកាចអន្ធពាលនោះ យើងដឹងហើយ, ប៉ុន្តែបើអ្នកចេះមន្តអាចសេពទង់ដែង ក្នុងហិបព្រះសុទត្តសមណៈឲ្យក្លាយទៅជាមាសបាន យើងក៏អាចសេពមន្តវិជ្ជាធ្វើពានរកូនអ្នក ឲ្យក្លាយទៅជាមនុស្សបានដូចគ្នា ; បើអ្នកសេពទង់ដែងមិនបាន , ពានរនេះក៏សេពឲ្យក្លាយទៅជាមនុស្សពុំបានដែរ ។ កុដុម្ពិកបានស្តាប់ហើយ លាវិលទៅផ្ទះវិញ ដំណាលប្រាប់ប្រពន្ធថា កូនយើងបានជាក្លាយទៅជាពានរដូច្នោះ ព្រោះអំពើអកុសលនៃយើង ត្បិតយើងលួចមាសព្រះសុទត្ត-សមណៈ ដូច្នោះ ចូរនាំយកមាសទៅដាក់ដូចដើម យកទង់ដែងចេញ អម្ហាកំ បុត្តោ មនុស្សោ កូនយើងនឹងបានជាមនុស្សដូចដើម ។ កាលបើប្រពន្ធយកមាសទៅដាក់វិញហើយ , កុដុម្ពិកក៏លីហិបទៅប្រគេនព្រះសុទត្តសមណៈ ។ ឯព្រះសុទត្តសមណៈ បើកហិបមើលឃើញមាសហើយពោលថា : ទង់ដែងក្លាយជាមាសដោយអានុភាពនៃការទៀនគ្រង់, ឯមាសក្លាយជាទង់ដែងដោយអានុភាពនៃអំពើវៀចវេរ, ទើបសរសើរប្រាជ្ញាព្រះមហាពោធិសត្វដោយពាក្យថា " ការឃើញនូវព្រះអរិយទាំងឡាយជាការប្រពៃ , ការនៅរួមជាមួយសប្បុរសទាំងឡាយ នាំមកនូវសេចក្តីសុខសព្វកាល, បុគ្គលដែលមានសេចក្តីសុខជានិច្ច ព្រោះមិនស្ម័គ្រស្មាគមជាមួយពាលជនទាំងឡាយ " ។

ពីព្រះបរមពោធិសត្វគំលាព្រះសុទត្តសមណៈ ឆ្ពោះព្រះភក្ត្រទៅកាន់ព្រៃព្រះហិមពាន្ត ។ ឯព្រះសុទត្តសមណៈ នាំយកពានទៅលែងក្នុងព្រៃធំ រួចនិមន្តទៅកាន់ផ្ទះនៃញាតិរបស់លោក នាំយកក្មេងមកប្រគល់ឲ្យកុដុម្ពិកវិញ ។ ពោធិសត្តស្ស គុណានុភាវេន សក្កស្ស ភវនំ ឧណ្ហាការំ ទស្សេសិ បពិត្រអើយ! ក្នុងកាលនោះ វីអាសនានៃព្រះឥន្ទ្រាធិរាជ ក៏សម្តែងនូវអាការៈដ៏ក្តៅ ព្រោះអានុភាពនៃគុណរបស់ព្រះបរមពោធិសត្វ ទើបព្រះឥន្ទ្រាធិរាជបង្គាប់ព្រះវិស្សុកម្មថា: វិស្សកម្ម ម្នាលវិស្សុកម្ម! ឥឡូវព្រះសុពេកុមារជាពុទ្ធង្កុរ មានព្រះទ័យចង់បួស អ្នកចូរនិម្មិតបរិក្ខារនិងសាលាថ្វាយចុះ ។ ឯព្រះវិស្សុកម្មទេវបុត្រ ទទួលព្រះរាជឱង្ការហើយ ហោះផ្លោះមកពីស្ថានទេវលោក និម្មិតអាស្រមទុកក្នុងព្រៃមួយ, និម្មិតស្រះបោក្ខរណី ហើយនិង ទីចង្ក្រមប្រវែង៦០ហត្ថជិតសាលា ដាក់ពោយពាយដ៏ខ្ពស់ ហើយចារឹកអក្សរទុកថា យេ យេ ជនា វីជនទាំងឡាយណាមួយ ចង់បព្វជ្ជាចូរយកគ្រឿងប្រដាប់ទាំងនេះហោង, ស្រេចហើយព្រះវិស្សុកម្មបណ្តេញអស់ពួកសត្វម្រឹគពាឡសាហាវ រួចហោះទៅកាន់វិមានវិញ ។ តស្មឹំ ខណេ ក្នុងខណៈនោះ ព្រះបរមពោធិសត្វទ្រង់យាងទៅដោយមាគ៌ាតែមួយព្រះអង្គឯង ក្រឡេកមើលទៅៈឃើញអាស្រមហើយ ព្រះអង្គចូលទៅជិតដឹងថាសម្តេចឥន្ទ្រាធិរាជឲ្យមកសាងថ្វាយ ទើបបើកទ្វារមើលឃើញអក្សរចារឹក

ព្រះអង្គមានព្រះរាជហឫទ័យសោមនស្សពន់ប្រមាណ ទ្រង់ផ្លាស់គ្រឿងរាជភេទចេញ ប្រដាប់ស្បូវក្រាំងស្បែកខ្លា ទ្រង់ប្រព្រឹត្តចង្ក្រមដើរទៅដើរមកពុំដាច់ សំដែងឥរិយាបថរបស់អ្នកបួសឲ្យប្រាកដ ទ្រង់លាន់ព្រះឱស្ឋថា អហោ សុខំ អហោ បរមសុខំ "ឱ! សេចក្ដីសុខ, ឱ! សុខនេះជាសុខប្រសើរ," ស្រេចហើយព្រះអង្គគង់នៅទី១ រំពឹងតទៅទៀតថា សេចក្ដីសុខក្នុងរាជសម្បត្តិ នឹងយកមកប្រៀបផ្ទឹមក្នុងបព្វជ្ជានេះពុំបានឡើយ, បព្វជ្ជាឈ្មោះថាពុំមានភ័យ ពុំមានអន្តរាយ ជាទីប្រាថ្នារបស់អ្នកប្រាជ្ញទាំងពួង, លុះពិចារណាដូច្នេះរួចហើយ ព្រះអង្គទ្រង់ចំរើននូវព្រហ្ម-វិហារ៤ បានលុះនូវសមាបត្តិ ៨ ឈានសុខ១២ វិហាសិ ព្រះអង្គនៅជាសុខក្នុងឈាន, ប្រការមួយសោត ព្រះសុរពោធិសត្វទ្រង់មានព្រះប្រាជ្ញាល្បីឮទៅក្នុងលោកដរាបដល់ធកាមារៈបរសូត្តិ ។

ឧ. កាលព្រះបរមពោធិសត្វគង់នៅក្នុងព្រៃព្រះហិមពាន្ត, មានស្រុកមួយឈ្មោះធញ្ញាវតាគ្រាម នៅឆ្ងាយពីព្រៃព្រះហិមពាន្ត នៅក្នុងស្រុកនោះមានពួកព្រានចំនួន៥០០ នាក់ ៗ ឯកាទិវសំ ក្នុងថ្ងៃមួយ ព្រានទាំងនោះ កាន់អង្រុត ថ្នង សំណាញ់ចេញទៅនេសាទត្រី ៗ មានព្រានម្នាក់បង់សំណាញ់ទៅត្រូវក្តាមមួយយ៉ាងធំ គិតថាជាគល់ឈើ ទើបលោតចុះមុជទៅក្នុងទឹកប្រយោជន៍ដើម្បីនឹងដោះសំណាញ់ ហើយយកដៃទាំងពីរតើបកន្ត្រាក់សំណាញ់នោះឡើងពីក្នុងទឹក ឯអ្នកនៅក្នុងទូក ក៏ជួយគ្នា

ទាញទាំងពីរនាក់ យកមកដាក់លើគូក ស្រាប់តែឃើញក្ដាមខ្យាំងធំ ក៏ស្រែកហៅពួកព្រានទាំងអស់ឲ្យមកមើល ៗ ព្រានទាំងអស់ លុះឃើញហើយ លាន់មាត់ប្រាប់គ្នាថា ក្ដាមនេះធំណាស់ពុំ ! យើងពុំដែលឃើញឡើយ ទើបតែឃើញក្នុងថ្ងៃនេះ ៗ លុះល្ងាចត្រជាក់ព្រាននោះនាំយកក្ដាមមកផ្ទះប្រាប់អស់ពួកអ្នកភូមិទាំងឡាយ ៗ

ឯកោ គាសកោ កាលនោះ មានអ្នកស្រែម្នាក់មកមើលក្ដាមនោះ លុះឃើញហើយ មានចិត្តមេត្តាករុណាស្រឡាញ់ដូចកូនបង្កើត ទើបឲ្យប្រាក់ចំបានដល់ព្រានបំណាញ់ យកក្ដាមនោះទៅដាក់ក្នុងស្រះមួយជិតផ្ទះ ៗ ឯក្ដាមនោះ ពុំមានភ័យអន្តរាយអ្វីឡើយ នៅជាសុខសប្បាយក្នុងស្រះ ៗ ថ្ងៃមួយបុរសនោះចេញទៅភ្ជួរស្រែ យកក្ដាមទៅផង លែងឲ្យនៅក្នុងទឹក ៗ ឯក្ដាមវារចេញពីទីដែលអ្នកស្រែទុកឲ្យនៅ ទៅរកអាហារបរិភោគ ៗ កាលនោះ មានក្អែកមួយ ឃើញក្ដាមហើយហើរទៅជិតប្រុងចឹកស៊ីជាអាហារ ៗ ឯក្ដាម លុះឃើញហើយលើកដង្កៀបទាំងពីរឡើងដើម្បីការពារខ្លួន ៗ ឯអ្នកស្រែឃើញក្អែកដូច្នោះ ទើបលើកជន្ទាញឡើង ដេញក្អែកឲ្យហើរទៅ រួចយកក្ដាមទៅដាក់ក្បែរខ្លួនស្រដីថា: ម្នាលក្ដាម ! ចូរអ្នកនៅក្នុងទីជិតនេះចុះ បើអ្នកវារទៅឆ្ងាយ នឹងបានជាចំណីក្អែកហោង ៗ ក្ដាមឮដូច្នោះ ទើបស្រដីថា បពិត្រអ្នកឪពុក កាលក្អែកនោះមក ខ្ញុំដឹងខ្លួនដែរ វាពុំអាច

ស៊ីខ្ញុំបានទេ, ថាដូច្នោះហើយ ក្តាមនោះក៏វារចូលចុះទៅក្នុងទឹកថ្លុក ១ ៗ កាលនោះ មានក្អែកមួយទៀត ក្រឡេកឃើញក្តាមនៅក្នុងថ្លុកដូច្នោះ ទើបលើកជើងម្ខាងឡើងឈរ ហើយធ្មេចភ្នែកម្ខាងហាមាត់គិតនឹងចឹកក្តាមនោះជាអាហារ ៗ ក្តាមគិតថា ក្អែកនេះវាប្រុងចឹកអញស៊ី អញដណ្តឹងសួរវាមើល គិតហើយក៏សួរថា ម្នាលក្អែក! អ្នកនឹងស៊ីយើងឬ? បានជាលើកជើងម្ខាងធ្មេចភ្នែក ហាមាត់ដូច្នេះ ៗ ក្អែកឆ្លើយដោយពាក្យកុហកថា ម្នាលក្តាម! យើងមានសេចក្តីករុណាគួរអាសូរអ្នក បើអ្នកនៅក្នុងទីនេះ នឹងវិនាសខ្លួន ដោយសារអ្នកស្រែនេះ សម្លាប់អ្នកយកទៅស្ងោរបរិភោគជាអាហារ យើងមកនេះ ប្រាថ្នានឹងនាំអ្នកទៅឯព្រៃព្រះហិមពាន្ត ប្រសិនបើអ្នកទៅកាន់ព្រៃហិមពាន្តនឹងបានសេចក្តីសុខច្រើន ប្រាសចាកភ័យទាំងពួង ព្រោះជាទីក្សេមក្សាន្ត ៗ ក្តាមស្តាប់ហើយពុំជឿសោះ ឆ្លើយតបថា សំដីរបស់អ្នកពុំសមសោះ ព្រោះអ្នកភ្ជួរស្រែនោះជាឪពុកធម៌របស់យើង ឪពុកនឹងមកសម្លាប់កូនដូចម្តេចកើត អ្នកកុំស្រដីដូច្នេះឡើយ បើអ្នកស្រដីនឹងយើងដោយត្រង់ យើងនឹងតាមពាក្យរបស់អ្នក ៗ ក្អែកឆ្លើយថា នែកូយ! យើងពុំជាអ្នកអន្ធពាលដូចក្អែកដទៃទេ យើងឃើញអ្នកនៅក្នុងទីចង្អៀតរងទុក្ខវេទនាពេកណាស់ បើអ្នកនៅទីនេះមុខជានឹងស្លាប់ តស្មាហំ តំ អាទាយ ព្រោះហេតុនោះយើងនាំអ្នកទៅឯព្រៃហិមពាន្ត ឲ្យអ្នកទៅមើលស្រះធំ អ្នកកុំសង្ស័យឬ

ភ័យខ្លាចឡើយ ៗ ក្តាមស្តាប់ហើយឆ្លើយថា ម្នាលក្អែក ! បើអ្នកនិយាយពិតយើងនឹងទៅជាមួយអ្នក ប៉ុន្តែ យើងចង់ដណ្តឹងប្រស្នានឹងអ្នកលមើលបន្តិច ចូរអ្នកឆ្លើយកុំខាន ៗ ក្អែកឆ្លើយថា វីមនុស្សគេមានប្រាជ្ញា មេធាវី ដឹងក្នុងប្រស្នាទើបដោះបាន យើងជាជាតិសត្វតិរច្ឆានមានប្រាជ្ញាតិច នឹងដោះស្រាយដូចម្តេចបាន ? ក្តាមឆ្លើយថា អ្នកឈប់នៅទីនេះសិន យើងនឹងទៅប្រាប់សេចក្តីដល់បិតាយើង ថាដូច្នោះហើយ ក៏ទៅឯទីស្រែដកបថា បពិត្របិតា ! ក្អែកនោះ នឹងនាំខ្ញុំទៅព្រៃហិមពាន្ត ខ្ញុំនឹងលាបិតាទៅព្រៃហិមពាន្ត ប៉ុន្តែ ខ្ញុំសួរប្រស្នានឹងក្អែកនោះលមើល បើដោះស្រាយបានក្តី ពុំបានក្តី ខ្ញុំនឹងលាបិតាទៅ ៗ ឯបុរសនោះ បានស្តាប់ពាក្យក្តាមហើយពោលថា យថា សុខំ គច្ឆសិ ចូរចៅទៅឲ្យបានសេចក្តីសុខសប្បាយ យំ យំ ឥច្ឆសិ បើចៅប្រាថ្នាអ្វី ៗ ចូរសម្រេចតាមប្រាថ្នា ទុក្ខ សោក រោគ ភ័យ កុំបីតដល់ចៅឡើយ ចូរចៅឈ្នះអស់សត្រូវទាំងឡាយ ៗ ក្តាមកាលបើបុរសនោះអនុញ្ញាតហើយ ក៏ទៅកាន់សំណាក់ក្អែកវិញ ពោលថា ម្នាលក្អែក! បើអ្នកស្រាយប្រស្នាយើងបាន យើងនឹងទៅផង បើស្រាយពុំបាន យើងមិនទៅនឹងអ្នកឡើយ , ម្នាលក្អែក ! ប្រស្នានោះដូចតទៅនេះ ៖

(មានត)

## ផ្នែកអក្សរសាស្ត្រ

# រឿងហង្សយន្ត

(តមក)

លោក អ៊ឹម-ភន ចម្លងពីសាស្ត្រាស្លឹករឹត

---

### បទកាកគតិ

កាលនោះព្រះបាទ សម្តេចនរនាថ យល់ព្រះប្អូនភ្ងា ឈឺចុករ ណាស់ ញ័រអស់កាយា សម្តេចភជា ថប់ព្រះប្អូនរត់ ៗ ព្រះអង្គ ឱបក់ ព្រះលឹងនៃអ្នក ប្អូនមាសស្នេហ៍ស្និទ្ធ ក្សិណក្សត្រខ្សឹកខ្សួល ឆន អួលអាណិត ព្រះប្អូនពេកក្តាត់ សែនសោយសោកា ៗ ទ្រង់ព្រះកន្សែង ឱបន្ទូលថ្លែង នូវទំនួញថា ឱប្អូនមាសបង ម្តេចម្តងនេះណា ឃើញមក កំព្រា លំបាកពេកក្រៃ ៗ តែបងនឹងប្អូន មកសំរាលទុក កណ្តាល ទ្រូងព្រៃ ឥតអ្នកណាមួយ នឹងជួយឡើងនៃ ជាធ្ងុចកាន់ថ្ម ប្អូនមាស ឡើយហោង ៗ នៅស្រុកនាយពី ព្រះអយ្យិកា ព្រះអយ្យកោផង ព្រះ ជនកជននី បេតីស្នូលគ្រង អស់ញាតិផៅពង្ស ចោមចាំរក្សា ៗ ខេះ ម្តង៏អស់ញាតិ លំបាកសល់ខ្លួន កណ្តាលគង្គា ឱប្អូនកំសត់ អាច អត់ទៅពី ឃើញផែវេក កម្មពៀបផុន ៗ ធើនៅស្រុកនាយ បងមាន

អ្នកម្តាយ អ្នកជាប្រធាន អស់ញាតិកា វង្សសន្តាន មើលមាស
កល្យាណ ថ្នក់ថ្នមបីទ្រ ៗ ខ្ញុំតែងរកថ្នាំ រកឆ្មបមកចាំ មិនមានឲ្យក្រ
ខ្ញុំរកមេមត់ ខ្ញុំរត់ទៅរក អស់តាំងពេទ្យហ្ម មានថ្នាំឆាប់ផុត ៗ ការ
ខ្មោចបិសាច ការអស់តាំងពក ជក្កូតប្រាកដ ពេទ្យស្ដោះផ្លុំស្ដាំ ពេទ្យ
ថ្នាំបរិសុទ្ធ នូវអស់មេមត់ សែនព្រេនលៀងស្ងា ៗ ខ្ញុំសោកសង
ស្រន់ អង្វរហើយបន់ ខ្មោចទីងគ្រីហា ខ្ញុំសោភរត់រក ហោរមកម្មា
ទៀងតាយជាតា គន់គូរប្រកា ៗ ខ្ញុំសោកសង់ទៅ រកដាំទឹកក្តៅ
ស្រង់ប្អូនសង្ក្រា ខ្ញុំរកមេធំ ស័ក្តិសមសក្តា រក្សាកុមារ មិនឲ្យមាន
ហ្ន ៗ ឥឡូវះតាកយ៉ាក យើងមកលំបាក កាលគ្រានេះម្តង ត្រះមាច
សោះសូន្យ តែប្អូនទីងបង មកកណ្តាលដង ព្រៃព្រះហិមពាន្ត ៗ ឥត
ញាតិផៅផង តែប្អូនទីងបង ម្តេចឡើយមកមាន ដម្ងូវហាចូន់ ពេក
ពន់ប្រមាណ ធ្វើម្តេចទីងបាន រួចឥឡូវអើយ ៗ សម្តេចពជា សែន
សោយសោកា ណាល់ណាស់ពុំស្បើយ ឌងនាថទេវី សង្ខាពិលាប
ហើយ ក្សត្រាគ្រាណត្រើយ លោមយាត់ប្អូនតេន ៗ គ្រាលីងបងអើយ
កុំសោយសោកឡើយ ព្រៃនេះឋានស្ងាត់ ក្រែងខ្មោចបិសាច ពជក្កូត
ព្នាត់ ប្អូនមាសប្រមាត់ រាប់រៀតបិន្ទា ៗ ប្អូនហើយឥឡូវ ឥតពេទ្យ
ណានៅ ចេះមន្តគាថា ការខ្មោចបិសាច ពជក្កូតមាយា ទាំងអើយ
បងមហា ថប់ពន់ប្រមាណ ៗ ហាក់ដូចអ្នកយក កាំស្មៅមកមុត សង្កត់

លើប្រាណ បង់ធុញថប់ថៃ ឥតឯស្រាកស្រាន្ត ដៀតប្អូនមាសមាន
ជម្ងឺនេះម្ដង ៗ ប្អូនអើយហេតុវី. បាកយើងគំពី បុរាណជាតិផង តាម
មកពាន់ឮ នាព្រៃនេះហោង គាបឡើយើងវង់ ទុក្ខទល់ពុំក្សាន្ត ៗ
ថ្ងះអ៊ីបង់ម៉្មុះ ជម្ងឺប្អូននេះ មកទុក្ខឯប្រាណ បងទឹងឈឺតាង ឡើនាង
ស្រាកស្រាន្ត ឥតលុះពុំបាន ឯងឥឡូវអើយ ៗ ចរប្អូនមាសអត់ តាម
គ័គំសត់ យើងណាប្អូនអើយ ពេកពេកក្រៃ យើងឯងផ្តល់ហើយ ព្រ.
លឹងមង់អើយ ចៀសបាកពុំបាន ៗ នាងនារីរតន៍ ស្ដាប់ព្រះរៀម
យាត់ នាងនាថកល្យាណ គាបអត់ជម្ងឺ នាងឈឺក្នុងប្រាណ
ហាក់ហើយស្រាកស្រាន្ត នាងពុំសោកា ៗ សម្ដេចភូធរ ថ្វាថ្ងៃ
អង្វរ អស់ពាំងទេវតា ទូរខ្មោចបិសាច រាជ់ក្នុងដងណា ស្ដេចស្ងួត
គាថា ប្រសើរខត្តមោ ៗ អ្នកជាក់នេត្ត ទេពសព្វ វិសេទ្ធិកោ
សោឡសសត់ ហាឌវិនោ ថលបព្វះតា បិសាចសព្វ ៗ យាចសម្មោ
នាសិទេព មហាទុក្ខំ ជយជយា ទេ្វដាកាយំ និរទិប្បំ ឥតានិយោ ៗ
បតិត្រូទេត្តា អ្នកបិតនៅនា សោឡសវិស័យ តោះអ្នកបិតហាង ហ៊ម
ពាន្ធនាយនៃ សឹងសព្វព្រឹក្សព្រៃ ស្រះស្រង់គង្គា ៗ សូមអ្នកពាំងនោះ
ជ្រោមជ្រែងជួយដោះ ទុក្ខយើងហោងណា គ្រោះនេះឡើបាន ស្រាក
ស្រាន្តទុក្ខា ធុតឆាប់ប្រសប្រថ្ា- កជកាលនេះម្ដង ៗ ទូរអស់បិសាច រាជ
ក្នុងផងគាប ថេរបិតនៅហោង ដោយដងហ៊មតាន្ត វិហារនេះហោង

កុំបីអ្នកបង ចិត្តបៀតចិន្តា ៗ សូមអ្នកមែនមាន ចិត្តចិន្តាថាន ជ្រោមជ្រែងរក្សា ផ្សែងយើងគោកយាក លំបាកណាស់ណា តែពីអង្គ កណ្ដាលព្រះព្រៃ ៗ ស្ដេចស្ដ្រគាថា អទ្ទិទេព្ភា អស់ទាំងខ្មោចព្រៃ ទើបព្រះកុមិន្ទ នរិន្ទ ជៀសជ័យ មានព្រះហឫទ័យ ទ្រង់ព្រះចិន្តា ៗ ផ្លូវព្រះស្មារតី សម្ដេចកុមារ ចំរើនការនា ការខ្មោចបិសាច ពជក្ខុតនាយា ស្ដេចឃុកធមជាំ ពាំនាក់សញ្ញាថ្ងៃ ៗ តេជៈសម្ភារ សៈម្ដចភូបាល ទំនងនាងរាជនៃ បាន សាងពីមុន មកៈច្រើនក្រាស់ក្រៃ ព្រះអារម្មថ្ងៃ ថ្ងៃង៉ូងពុំបាន ៗ រី ក្សិណានោះណា អ្នកនៈងនាថជា អង្គអគ្គសប្បាណ ប្រសូតពជបុត្រ បរិសុទ្ធប្រៈបព្រាណ រូមបរិបូណ៌បាន ចេញចាកទ្វារ ៗ បុត្រគេនត្រកូល ដូចកែវពិទូរ្យ ថ្លាថ្លៃបវរ ព្រះកក្រ សាក់ណា ដូចបទ្មថៃងចរ ពួកអម្ដារ ពាលពេញបូណ៌មី ៗ ប្រកបកើតមក ជាបុត្រពន្ធក ព្រះជនកជននី ត្រកាលត្រកូល អម្បូរជាតិ កើតកបអស់ក្ស- សួរសេមសោភា ៗ ក្សណ នោះព្រះអង្គ ជង់ទឹកមកស្រង់ ព្រះកដបុត្រា ស្រង់ទាំងទេពី ក្សត្រី កញ្ញា សាយសព្វអង្គ ជាស្រេចហ្មត់ហ្មង ៗ នាងនាថអោ ដោយស្រង់ គង្គា ត្រជាក់នោះហោង នាងថ្វាយបង្គំ ប្រណម្យពបរង អង្វរព្រះ បង ព្រះបាទកុមារ ៗ បពិត្រអម្ចាស់ ខ្ញុំអោណាស់ ញ័រអស់ឥន្ទ្រិយ ទល់ ទប់ពុំបាន សូមពានកុមារ ស្ដេចរកអគ្គី ឲ្យខ្ញុំអាំងកំ ៗ ពង្សព្រុទ្ធក្ក ស្ដាប់ ព្រះបន្ទូល ស្ដេចៈសាយសោភា ណាល់ណាស់អនិច្ច ភាណិត

អនាថ អាសូរប្អូនភ្ងា ពេកពន់ប្រមាណ ៗ ស្ដេចខំបបួល ឱប្អូន
បណ្ដាល ធ្វើម្ដេចនឹងបាន ភ្លើងឡើងប្អូនស្ងួន ខ្ញុំខ្លួនអាំងប្រាណ
ដែកភ្លើងសោកគ្មាន សូន្យសោះទេណា ៗ មាសអើយទីហ្នឹង ព្រៃ
ព្រះហិមពាន្ត ខេត្រខណ្ឌធ្លា ដុះដោយរបោះ ចន្លោះព្រឹក្សា សឹង
ចន្ទន៍ក្រឹស្នា ឥតមានក្រសោះ ៗ ស្ដេចស្ដែងទតទៅ យល់ភ្លើងភ្លឺនៅ
នាកេត្រោះនោះ កណ្ដាលសមុទ្រ ប្រាកដស្មានស្មោះ ស្ដេចចិន្តាត្រោះ
យកភ្លើងនោះណា ៗ សម្ដេចភូមី ជួមព្រះប្អូនស្រី បន្ទូលផ្ដាំថា
ហៃប្អូនព្រលឹង បងនឹងលីលា ទៅឋានកេត្រា យកភ្លើងនោះហោង ៗ
ឱប្អូនមាសថ្លៃ ស្ងួនអើយនោះនៃ ខ្ញុំមានស្នេហ៍ស្ងួន នាងនៅដឹងកូន
ណាប្អូនមាសបង បងអ្នកនឹងផ្គង វិលវិញឆាប់ណា ៗ រីឯនាងនាថ
ឱនឱបព្រះបាទ ទៀនទូញទូលថា សូមព្រះអង្គឆាប់ ក្រឡេបមកពី
អ្នកអើយប្អូនខ្លាច ខ្លាចពន់ពេកក្រៃ ៗ ខ្ញុំនៅម្នាក់ឯង ត្រមោច
កណ្ដាន កណ្ដាលទ្រើនព្រៃ កុំបីព្រះអង្គ ផ្សព្វផ្សងឡើយនៃ ស្ដេច
ឆាប់វៃ ។ កុំយូរឡើយហោង ៗ

## បទព្រហ្មគីតិ

កាលនោះព្រះភូមី ផ្ដាំប្អូនស្រីស្រេចឥតផ្គង ស្ដេចគង់យន្ដហោះផ្សង
លុះកណ្ដាលសាគរ ៗ ឆៀបឆាប់ទន់ទាបទៅ ស្ដេចសំដៅដល់

កេត្រា ព្រះហស្តថ្វៃប្រវ៉ា ចាប់អង្កត់នៃអគ្គី ។ បានហើយហោះម្ហី
ម្នា ពីកេត្រាចរចេញទៅ ព្រះហស្តកាន់អគ្គី ដាក់លើយន្តហើយហោះ
ផ្សេង ។ ឯអស់អ្នកកេត្រា គិតការមាផ្ដើលអីឯកឯង ស្មើរក្លូកកេត្រា
ផង ស្រែកបង្អើលអីឯគ្រប់គ្នា ។ ឯអង្គព្រះកូមី បានអគ្គីពីកេត្រា
ដាក់លើយន្តនោះណា ព្រះករកាន់កើបយន្តហោះ ។ រីភ្លើងមិញ
ត្រូវខ្យល់ ឆេះដូចដល់ខ្សែយន្តនោះ ឆេះទាំងខ្សែបាន់ហោះ នេះ
ខ្សែស្លាបសង់ទាន់ណា ។ យន្តមាសមិញនោះ រុះធ្លាក់ចុះក្នុង
គង្គា សម្ដេចព្រះពជា ធ្លាក់ក្នុងកាលនោះឯងនៃ ។ ហង្សយន្ត
មិញសោតសាត់ អណ្ដែតបាត់ភ្លាត់ទីនៃ ពីព្រះបាទជៀសជ័យ
ដោយទឹកហូរខ្សែល់ផាត់ទៅ ។ កាលនោះពោធិសត្វ លំបាកក្ដាត់
កាលធ្លាក់ទៅ កណ្ដាលសាគរជ្រៅ សាត់ព្រាត់ពីយន្តមាសមៃ ។
ស្ដេចហែលហើយសោយសោក សោកអាមោក្សពន់ពេកក្រៃ បង្អៀត
អស់ហឫទ័យ វេទនាទតំនឹងកពេក ។ ផ្គុកផ្ដើះក្រគ្រខ្សឹកខ្សួល ឯង
អន់អួលអួលកាណេត ទ្រង់ព្រះកន្សែងក្ដាត់ ទូរទំនួញដោយពាក្យថា ។
ខ្ញុំញបានយន្តហោះ ដោយមណ្ឌលព្រះវិហារ៍ ឥឡូវយន្តនោះ
ណា ធ្លាក់ក្នុងទឹកសាត់បាត់បង់ ។ ម៉េះហើយសមអញក្សយ
កាលនេះនៃពិតពុំលង់ អសារគណ្ឋាលក្នុង មហាសមុទ្រនេះឯង
ណា ។ គោះបីអង្គអញមរណ៍ ក្នុងសាគរគម្ភីរ ពុំឃ្លានខ្លួន

ឡើយណា គិតអាសូរតែប្អូនស្រី ។ ខ្ញុំប្អូនគន់ទុក្ខ សង្វាតមក
បង់បុរី បង់ទាំងព្រះជននី ព្រះជនកនៅនាយផង ។ ហេតុជៀតប្អូន
មាសថ្លៃ នាងអាល័យអាឡោះបង ខ្ញុំឥឡូវម្តេចម្តង នេះបងបង់មេ
មាសមិត្ត ។ អាសារសោះមកមរណ៍ កង្សាតនេះឯងឥត ដំណួច
ដំណឹងពិត ពុំបានដឹងដល់ប្អូនភ្ងា ។ ខ្ញុំពាក្យពៅផ្តែផ្តាំ នោះបង
ចាំ ចាំក្តាត់ណា ពុំឃើញបងលើលា នាងរៃរៃសែនសោះសោកា ។
ពិលាបអស់ចិត្តប្អូន ហើយនាំកូនយាងយាត្រា ដើរជាយដងមាគ៌ា
ពុំដឹងដំបន់ទិសទី ។ ខ្ញុំមាសព្រលឹងបង ពុំដែលដើរឯងដោយដី ឥឡូវ
នេះប្អូនស្រី មកលំបាកជៀតខ្លួនបង ។ ខ្ញុំអាសូរប្អូនក្មេង ពុំដែលដឹង
ទុក្ខភ័យផង ទើបតែគ្រានេះម្តង មាសមេមកលំបាកក្រៃ ។ បងគិតមួយ
ខ្លាចក្រែង នុងវង្វេងកណ្តាលព្រៃ សម្រេចហត់ហាលថ្ងៃ ជាពុំពន
បានគន់ ។ ប្អូនអើយបងថប់ថៃ ឈឺគត់ឯស្រាកស្រាន្តស្រន់ ឆ្អក
ផ្ទើះអួលអន្តគន់ ឥតឯសៀយដល់តិចណា ។ មួយឈឺប្អូនបណ្តូល
មួយអាសូរឈឺបុត្រា ខ្ញុំកូនស្ងួនពុំងា បាកើតមកលំបាកក្រៃ ។ ខ្ញុំបា
បុត្រសំឡាញ់ ប្រសូតចេញ-ចេញពីផ្ទៃ មាតានៅក្នុងព្រៃ ព្រះ
ហិមពាន្តហានព្រឹក្សា ។ កាលនោះឯអាពុក បានយល់មុខ.មុខបារ៉ា
រំពេចពុំលង់ណា ហើយអាពុកប្រែប្រាសបង់ ។ បាបុត្រស្ងួនថ្នមថ្លៃ
មកមរណ៍ក្ស័យ-ក្ស័យលិចលង់ កណ្តាលប្រវាលក្នុង មហាសមុទ្រធ្លាក់

អាពុកពុំគិតខ្លួន គិតតែប្អូន-ស្ងួនកំព្រា ពីនាក់ទីវិមាតា នៅនាព្រះ
ហិមពាន្ត ៗ ថ្ងៃនេះអាពុកប្រាស ប្រាសទិពសបុត្រកល្យាណ ម៉្លេះ
ហើយសមពុំបាន យល់មុខកូនភ្ញាក់ឡើយ ៗ អាពុកគិតទៅគ្រប់
គ្រប់ហើយថប់-ថប់ពុំស្បើយ នុះប្អូនអាពុកអើយ អាពុកថប់ពេកច្រើនក្រៃ ៗ
បំណាច់មាសភ្ញាក់ បាបានមកចាប់ថដិ-សន្ទិបុត្រត្រាប្រើយ លែងអាពុក
បានកេរ្ត ៗ ផ្ដាក់ផ្ទម-ផ្ទមផ្ដេកផ្ទិត ឲ្យអស់ចិត្តអាពុកក៏ សន្សើមប្រាស
ឃាតឃា តាមជោយកម្មវិបាកបាន ៗ មួយសោកតះតោះបីបើ បាប
អំពីបុណ្ណណាព្រេង ក្រែងយើងតាំងពីបុរាណ ធ្វើអំពើអំពល់ពិត ៗ វេទនៅ
តៀកម្ម នេះបង់តាំងពាយកហិត ទីផ្ដល់ផ្ដាច់ជីវិត ឲ្យក្សិណក្ស័យ
នៃជន្មា ៗ តាំងនេះហេតុតែកម្ម បងមកតាមតាទនេះណា ឲ្យប្រាស
ប្អូនពុំពា កណ្ដាលព្រៃណាទាំងអើយ ៗ ម៉្លេះសមមាសព្រលឹង តែង
ទន្ទឹង-ទន្ទឹងហើយ មើលផ្លូវពុំយល់ឡើយ គិតស្មានបងរួចទៅបាន ៗ
មិនដឹងជាមរណ៍ គង់សាងរងទុក្ខព្រៀវ ឲបងអាស្រូវពៅ ជាមេម៉ាយ
ឯងកំព្រា ៗ តែពីរនាក់ទីងកូន ស្ងាត់សោះសូន្យគ្មានអ្នកផ្ញា ឲបង
ប្រណីណា ក្រែងសត្វម្រឹគយង់ឃ្នងផង ៗ រាដើរមកតះតីបពះ ជួបប្រទះ
ប្អូនមាសបង ទីងកូនតន់ប្អូនគ្រង ក្រែងរាចាប់បរិភោគា ៗ មួយ
សោកក្រែងគ្រជាក់ ខ្លាអ្នកមាសស្ងួនក្ស ដោយឥតអគ្គិណា សម
ប្អូនតែឯងឯកអង្គ ៗ នៅព្រៃព្រះហិមពាន្ត ទួលទីឋានត្នោតស្រះស្រង់

សោះសូន្យជីវិតបង់ ដ្បិតកំសត់វេទកំព្រា ។ ឱប្អូនមាសថ្មើមថ្ងៃ ក្រែងប្អូនក្ស័យជន្មា បានបងនៅទូក បងទទឹងលើកសពប្អូនស្រី ។ ស្រេចហើយបងទទឹងក្ស័យ ផងមាសថ្ងៃរំពេចន្ទ តាំងបុត្រស្ងួនភ្ជាប់ប្រីយ បរិបូណ៌មួយទីងគ្នាហោង ។ ឥឡូវម្តេចប្អូនមាស មេព្រាសព្រាត់បង្បែង បង ស្ងួនអើយតែនេះម្តង បងជាប់ផងទន់ម្លូលផ្កា ។ ឈឺធ្ងួលធៀបស្មើផេះ ហក់ហើយស្មើប្រេះទាក ដូចអ្នកយកខាន់ថ្វា កាន់កាត់ក្រវាពុង ពោះបង ។ ពោះឈឺដោយពាំខាន់ ពុំឈឺដូចេះជាម្តង ដ្បិតព្រាសប្អូន ស្នេហ៍ស្ងួន ក៏បងឈឺពន់ពេកណា ។ ប្អូនអើយបងគិតល្មេង មួយ សោតក្រែងអស់ទេពតា លោកៈប្រាំមព្រៃងក្រោ ឲ្យប្អូនមាសមានឫទ្ធិ ។ ទីងបុត្រស្ងួនសង្សារ នៅកណ្តាលព្រៃធ្ងួពៅ ឱបងប្រណីពៅ សងស្បៀម ស្ងាត់ឯងហោងណា ។ សប្អូនខ្ទឹងក្តាត់ តាំងបងបាត់ពន់វេលា កាលកលសោយសោកា ពិលាបលន់ពន់ពេកក្រៃ ។ សូម្បីបុត្រពន្ទក ហើយរត់រកដោយដងព្រៃ ទេត្រនាងគង់រំពៃ ឯអាកាសវេហាស៍ផង ។ សម្រេកសត្វហានព្រៃ ហិមពាន្តជ្រោះជ្រលង អស់ចិត្តប្អូនហើយហោង សមប្អូនមាសទីងមរណា ។ ស្ងួមមួយមូលតាំងបី រំពេចខ្ញុំព្រមផងគ្នា កុំឲ្យព្រាសឃ្លាតឃ្លា តាកបង្បែងដូចេះនៃ ។ សម្តេចព្រះពុជា សោក ឈឺផ្សាបុត្រាថ្ងៃ នៅកណ្តាលព្រះព្រៃ ទីងថ្ងៃងថ្ងៃពុំបានណា ។ នេះ ទើបស្តេចខ្ញុំញាតិ ព្រះជនកទីងមាតា ព្រះឱស្ឋថ្ងៃថ្ងៃងថា ឱអម្ចាស់តាំង

ពីរពន្ស ៗ កាលកូនយាត្រាមក ព្រះបិតាមាតាទ្រង់ កន្សែងទាំងពីរពន្ស
ឲបផ្ដាំៈហើយផ្ដាំផ្ដិត ៗ ពាក្យអ្នកទាំងពីរផ្ដាំ នោះកូនចាំ ៗ ទៀងទាត់
ឲ្យកូនធាប់លៃថ្កាត់ កុំឲ្យយូរលង់ឡើយណា ៗ អ្នកៈអ័យឥឡូវកូន
អសារសូនឲ្យក្នុងគ្គា ហន្យយទ្ដមិញយ្យាភយ្យា ដាច់រកាត់បាត់បង់ហើយ
ណា ៗ កាលកូនពុំបានទៅ ថ្កានព្រះទៅវាំងពីរឡើយ សមកូនលុះដល់
ត្រើយ ព្រះម្រឹគឹ.ឃ្លូរៅៈហោង ៗ ឲ្យអ្នកៈមមានគុណ គុ.ណមហាធ្ងន់ៗកន្ទង
ម៉ែកូនពុំបានសង ព្រះគុណទាំងពីរនេះឡើយ ៗ ហេតុបាបពៀរពីព្រេង
កម្មរបស់កូនមកផ្ដល់ហើយ ឲ្យម្នាស់ថ្លៃកូនអើយ កុំកូនគិតពុំបាត់ណា ៗ
សម្ដេចព្រះភូមី ហៃលជលធីគឹរប៉ះវ៉ា បីវិនទៀងប្រាសប្រា- កដនៅបី
ពត្រើផង ៗ ព្រះអង្គលើកទសករ ថ្វាត់ថ្វាបវរវន្ទាផ្គង ដាក់លើព្រះសិរ
ហោង បង្គំគុណព្រះរតនត្រៃ ៗ មួយគិតគុណព្រះពុទ្ធ ជាមកុដប្រ-
សើរត្រៃ នូវគុណព្រះធម៌ថ្លៃ នូវគុណព្រះសង្ឃសោតហោង ៗ នូវ
គុណអស់ទេព្ដា រែងរក្សាសមុទ្រផង នូវគុណមាតាគ្រង់ នូវគុណព្រះ
វរបិតា ៗ ហើយព្រះអង្គក្រវីន រែងចំរើនធម៌ភាវនា ស្ដេចយកព្រះ
ធម៌ជា ត្រើយពំនាក់ព្រះអង្គហោង ៗ តេជៈព្រះធម៌ថ្លៃ ក្យគ្រជៀស្ល
ជ័យរក្សាគ្រង់ អស់ទាំងទេព្ដាផង រួមរក្សាព្រះនរនាថ ៗ មួយសោត
ព្រះបារមី ស្ដេចសាងពីបុរាណជាតិ ជ្រោមជ្រែងជួយព្រះបាទ ប្រាកដ
កាលនេះឯងហោង ៗ ក្បែណនោះនាយកេត្រា នូវអស់ពាណិជនោះផង

នាំនាយកេត្រាបួន ឈ្មោះហៅសមុទ្ទគោចរ ។ បើកការកេត្រាត្រង់

យល់ព្រះគង្គក្នុងសាគរ ឯនាយកេត្រាអរ ឲ្យកូនឈ្មួញចុះសម្ប៉ាន ។ ទៅ

ស្រង់ព្រះពោធិសត្វ បុរសគេន់រួចឡើងបាន ដល់ដាក់លើសំប៉ាន

ហើយនាំទៅដល់កេត្រា ។ ឯនាយសំពៅសឹង សួរដណ្ដឹងព្រះរាជា

អ្នកអើយហេតុអ្វីណា ក៏អ្នកមកហែលដល់ ។ ត្រមោចលិចបាក់ប្រាណ

ព្រោះហេតុមានប្រការអ្វី ចូរអ្នកថ្លែងពិតពី ដំណើរនោះប្រាប់យើងក៏ ។

ក្សណនោះព្រះជៀសវជ័យ ស្ដាប់ស្រវៃមនាយកេត្រា នៃទើបព្រះរាជា

បន្ទូលប្រាប់ដំណើរតើ ។ កំណើតព្រះអង្គជា បុត្រក្សត្រាក្រុងបុរី

ប្រាប់កាលព្រះភូមី ចេញចាកពីព្រះនគរ ។ ប្រាប់កាលព្រះអង្គបាន

នាងកល្យាណនាំចេញចរ គាប់ជួនឃើញទ័រ ឈប់ប្រសូតរាជបុត្រា ។

នៅកណ្ដាលព្រះព្រៃ ក្សត្រថ្លាថ្លៃប្រាប់កាលគ្រា ស្ដេចគង់យន្តយាត្រា

មកយកក្លិនពីសំពៅ ។ ប្រាប់កាលព្រះភូមី បានអង្គហើយហោះ

ទៅ ប្រាប់កាលព្រះចមហៅ ដាច់យន្តធ្លាក់ក្នុងសាគរ ។ ស្ដេច

ប្រាប់អស់សេចក្ដី សព្វឥតចំខ្ទះឡើយណា រីឯនាយកេត្រា នូវអស់

ពាំងកូនឈ្មួញផង ។ បានស្ដាប់ព្រះភូបាល ប្រាប់ប្រការដូច្នោះហោង

ហើយចរចាឥតគ្គង សឹងកាសួរព្រះរាជា ។ ឯអង្គពង្សពោធិ-សត្វវរ-

វិសេសសោភា នៅនឹងនាយកេត្រា ស្ដេចពុំគិតតួព្រះអង្គ ។ គិតតែវរជា-

យា នឹងបុត្រភ្ញាជៀតប្រាសចង់ ស្ដេចគិតហើយស្ដេចទ្រង់ ព្រះកន្សែង

សោកពេកណា ។ ពុំដែលឡើយហៅមាន ស្រាលស្រាកស្រាន្តពីទុក
ព្រះឥន្ទ្រសោយសោកា ជាទិវន្តរៀងទៅហោង ។ កាលនោះមានគេត្រា
មួយទៀតណាបើកផ្លាស់ទូង ដោយគៀនដែលកន្ទុង គេត្រាប័ងបើលាចរ ៗ
ឯនាយគេត្រានោះ ដោយនាមឈ្មោះហៅសាគរ ពាណិជនោះចរចរ
ទីទីអស់កូនឈ្មួញផងណា ។ បើកសំពៅទូងផ្លាស់ យល់ហង្សមាសក្នុងគង្គា
ហើយយកឡើងមម្ញា ដាក់លើសំពៅនោះនៃ ៗ យល់ហង្សមាសពិចិត្រ
ត្រេកអរក្តៅពន់ពេកក្រៃ យករឹកទិសវិស័យ ពុំងឹងហោះដោយវេហាស៍ ។
ដំណើរកោធិសត្វ ប្រសើរគន់ពេកជា នៅទីនាយគេត្រា យើងឈប់
ស្មេះទៅនេះនៃ ។ ហើយយើងមកស្រដី ចាំថ្ងៃពីក្សត្រិថ្ងៃ នាងនៅឯង
ក្នុងព្រៃ កំព្រាព្រាត់ព្រះស្វាមី ៗ

បទកាកគតិ

កាលនោះនាងនាថ ចាំព្រះភូបាល ដូចជាទិនបី យល់ព្រះបង់បាត់
វិរគន់ក្សត្រី សែនសោយសោកពី- លាបលន់ណាស់ណា ។ នាងយក
ព្រះករ ចាំងពីនាងគរ គគក់ទុក ហើយហៀបនឹងក្ស័យ ប្រល័យ
ជន្មា ហេតុដៀតសោកា ឈឺសន្សាថ្ងៃ ៗ ឈឺអស់ទុក នាងនាថឈឺផ្សា
ព្រះរៀមវសពល ផ្សាខ្វាបក្តៅក្តាត់ ស្រីគន់ទិមល ប្រះព្រាណដួល
ដល់ ដេកដោយលាក ។ នាងឈឺស្វាមី ហាក់ដូចសត្តិ ចេះក្នុងទុក
សព្វសាច់សួតថ្លើម ដង្ហើមវយា ក្តៅក្តាត់ឈឺផ្សា ឡើងឡង់សន្ធប់ ។

រំឭកស្មារតី សម្ដេចទេវី ថៃថប់សោកសល់ ពុំអាចបំបាន ប្រឹង
ប្រាណទប់ទល់ សន្ធប់ដួលដល់ លន់ពន់ពេកក្រៃ ៗ លុះភ្ញាក់ស្មារតី
ផាលផោះឡើងពី ភូមិគតនោះនៃ នាងបីបុត្ររតន៍ ត្រាច់កាត់ដោយ
ព្រៃ រកព្រះចមព្រៃ ពុំឃើញឡើយណា ៗ នាងនាថប្រសើរ ទៀយ
ណាស់នាងដើរ ក្នុងព្រៃព្រឹក្សា ហើយហាលថ្ងៃផង ពុំពឹងបាពា នាង
បីបុត្រា ចូលឈប់អាស្រ័យ ៗ ក្រោមម្លប់ព្រឹក្សា ហើយយកពស្ត្រា
ល្អមានដំឡៃ នាងក្រាលផ្ដេកផ្ដិត បុត្ររតន៍ថ្មីមថ្ងៃ បំពៅហើយនៃ
នាងនាថខ្ញូញថា ៗ ឱបុត្រថ្ងៃម្ដាយ ចាបឡើអប្បាយ ឲ្យកូនសុនក្ស៍
កើតក្នុងសាន្ដក្រោះ សូន្យសោះកំព្រា ប្រាសព្រះបិតា ធិកដៀស្ដជ័យ ៗ
កូនអើយម្ដាយស្រក រកអាពុកអ្នក ដោយដងព្រះព្រៃ ពុំយល់សោះសូន្យ
ណាកូនមាសថ្ងៃ កំម្ដាយសង្រៃ សង្រេងសោកា ៗ អម្ចាស់ម្ដាយ
អើយ ឥឡូវនេះហើយ ម្ដាយទីងយាត្រា រកព្រះកូនរ ព្រះវរបិតា
ម្ដាយទីងឃកបា ទៅពុំបានឡើយ ៗ ក្រែងកូនមាសថ្ងៃ ត្រូវកំដៅ
ថ្ងៃ កើតជម្ងឺហើយ ម្ដាយរែងផ្សាក្ដៅ ឥតឯហៅសៀយ អម្ចាស់ម្ដាយ
អើយ អ្នកនៅនេះនៃ ៗ នាងយកព្រះទម្រង់ រតន៍រស្មីឧត្ដម ប្រ-
សើរពេកក្រៃ ត្បូងស្វាកាណ៌រតន៍ ល្អឥតដំឡៃ នាងចងនៅដៃ
ព្រះបរុស្ដបុត្រា ៗ ហើយនាងបីបុត្រ នាងទ្រង់កំសត់ ពិលាបខ្ញូញ
ថា៖ ឱមាសផ្ទិនផ្អៅ អ្នកបៅមាតា ឲ្យផ្អែតហោងណា អម្ចាស់ម្ដាយ

អើយ ៗ ម្ដាយនឹងយាត្រា ទៅតាមបិតា អ្នកឥឡូវអើយ ម្ដាយ
ឈឺពេកក្ដី ឥតឯហៅស្បើយ អម្ចាស់ម្ដាយអើយ ម្ដាយមកវិញណា
នាងផ្ដេកកដបុត្រ សោយសោកស្រយុត ញ៉ាំអស់អង្គា ទង្គិះឡើក
ខ្ញុល អន់អួលទុក នាងថើបបុត្រា ស្រេចហើយនាងថេរ ៗ ចេញ
បង់បុត្រា វរពជជាយា ត្រាច់កេក្ខរ ស្រើតេទ់ពន្ទុក នាងយកព្រះ
គរ ចាំងពីរនាងគរ ទ្រូងទ្រង់សោកា ៗ នាងស្រែកអន្ទះ អន្ទែង
ស្ទែងស្ទះ តែកេកជា សត្វប្រោះប្រលង៍ ដោយដងអញ្ជា ពុំយល់ព្រះ
មហា ពន្ទុកថ្មើមថ្ងៃ ៗ នាងវែងសោកសល់ កេះរៀងរូបដល់ សា
គរនាយនៃ ត្រាច់ដើរដោយទ្នេរ គម្ពីរផលស័យ ពុំឃើញដៀស្ដ័យ
នាងនាថទូញថា ៗ ឱព្រះបពិត្រ ធ្លាប់វែងថេរបិត នឹងខ្ញុំវិញណា
ឥឡូវព្រះមាស ប្រែប្រាសឃ្លាតឃ្លា ឱប្អូនឯងអា- សារសោះសូន្យ
សល់ ៗ ឱព្រះពន្ទុក ប្អូនត្រាច់ដើរក ដោយដែនក្រសល់ ព្រៃព្រឹក្ស
ឋានអាយ សត្វសាយពុំយល់ អ្នកអើយប្អូនទល់ ទុក្ខតែម្នាក់ឯង ៗ
ឱព្រះប្រសើរ អ្នកអើយប្អូនមើល សមុទ្រធំធេង ទូលាយបាត់ត្រើយ
ព្រះហើយប្អូនក្រែង ខ្លាចព្រះអង្គឯង ក្ស័យក្នុងគង្គា ៗ ខ្ញុំមើលមហា-
ក្សត្រ ខ្លាចក្រែងខ្យល់ផាត់ បោកព្រះសព្វមហា . សត្តមកប្របទ្នេរ
គម្ពីរផលសា សពព្រះរាជា ពុំយល់ឡើយនៃ ៗ ប្អូនមើលអាកាស
ពពកសាត់ផាស សាត់ទៅច្រើនក្រៃ ឱព្រះប្រសើរ ប្អូនមើលស្រមៃ

ហាក់ដូចក្សត្រថ្ងៃ ស្តេចហៀរហោះផ្សង ៗ ឲ្យប្អូនស្រមៃ ពពកទេវៃ
ស្មានជាព្រះចន្ទ ឯព្រះបពិត្រ បាត់មិត្តទេហោង អ្នកអើយប្អូនរង់ ទុក្ខទោ.
មនស្សា ៗ ឲ្យប្អូនយល់ហោង ហើរហើយវិលវង់ តាមដោយវេហាស៍
ប្អូនស្មានព្រះចន្ទ ហោះផ្សងមកណា មិនដឹងបក្សា ហង្សហើរហួសទៅ ៗ
ប្អូនរែងស្រណោះ យល់បក្សានោះ គិតជាព្រះពៅ ព្រះអង្គធ្លាប់គង់ ហង្ស
យន្តមាសខ្ពៅ រស្មីសន្ធៅ ព្រោងព្រាយអាកាស ៗ ម្តេចឡើយព្រះ
មាស មិត្តមិញប្រែប្រាស បងប្អូននៅអាយ ឈើផ្សងផ្កាផ្សង ឲ្យរះស្ទើរ
ធ្លាយ ស្មារតីកាយមាយ ភ្ញួសឡេវឡើង ៗ ឲ្យព្រះកជា ប្អូនគិតមួយណា
មួយនឹងភ្ញាប់ក្រែង ព្រះមាសពន្លក ហោះរកប្អូនឯង ហើយស្តេចរង្គើង
ទីហានដែលឈប់ ។ ក្រែងព្រះទេសពល រកប្អូនពុំយល់ ហើយវិល
ត្រឡប់ រត់រកដោយដង ព្រៃផងសាយសព្វ ពុំយល់ស្តេចឈប់
ហង្សយន្តមាសមៃ ៗ ប្អូនត្រាច់ដើររក សព្វព្រៃឈូងឆក ពុំយល់ប្អូន
ណា ក្រែងសត្វម្រឹគផង យង់ឃ្នងពាធា ក្សិណក្សយជន្មា សោះសូន្យ
បាត់បង់ ៗ គោះព្រះចក្រី មរណ៍មែនពិតក្តី លែងបានឃើញហង្ស
ប្អូនមើលពុំយល់ ត្បិតបាត់ព្រះអង្គ បាត់ស្តេចតាំងហង្ស តាំងអង្គពជា ៗ
ឲ្យព្រះទេសពល អ្នកអើយប្អូនឆ្ងល់ ពន់ពេកណាស់ណា ប្អូនពុំដឹងដើរ
ទីទិសមាគ៌ា ទឹងរកព្រះមហា ពន្លកថ្មើមថ្ងៃ ៗ ឲ្យព្រះត្រាណត្រើយ
អម្ចាស់ប្អូនអើយ ប្អូនកុំព្រាត់ព្រៃ ត្រមោចកណ្តាល ឯកឯងក្នុងព្រៃ

ប្រាសព្រះជៀសជ័យ ចេញពីទេព ៗ ឱព្រះបាទបង់ ពីថ្ងៃនេះហោង

តែងទីនឃ្លាតឃ្លា និកសារសោះសូន្យ បងប្អូនកាលគ្រា នេះទៅអត្ថា

ព្រៃព្រះហិមពាន្ត ៗ ឱព្រះពន្លក ស្តេចនាំប្អូនមក បងនឹងពៅផ្កាន

ក្រុងទេពបុរី ជាទីកដរបាន ម្តេចឡើយមកមាន ទុក្ខព្រាត់ប្រាសគ្នា ៗ

ឱអម្ចាស់ថ្លៃ ប្អូនជាទុក្ខព្រៃ ឯកអង្គអនិច្ចា ត្រូវមាតព្រាត់ប្រាស ព្រះមាស

សេ្នហា គង់ព្រៃព្រឹក្សា ទូរទេហាងស្ងាត់ ៗ ឱព្រះវរមេបា ប្រែប្រាសប្អូន

ទៅ អសារសល់គាត់ ប្អូនឃើញផ្កា ខ្ចាប ល្អោះល្អោចប្រមាត់ ដ្បិតព្រះ

ប្រាសព្រាត់ ចាកចម្ងាយបង់ ៗ ប្អូនឈឺទសពល ជៀសនៀចដួចគល

អគ្គីនេះគង់ ទុកក្ដៅក្ដាត់ ដ្បិតបាត់ព្រះអង្គ ព្រះហើយប្អូនឆ្ងង ដ្បិតវែង

សោកសល់ ៗ នាងនាថទៅ វរគេទក្សត្រី សោយសោកសល់ ទៀង

ទូញព្រះបាទ នរនាថទសពល នេត្រាជោរជល ស្រក់ស្រោចភក្ត្រា ៗ

នាងទូញបណ្ដើរ ស្រីរតនប្រសើរ ត្រាច់គង់អត្ថា ពុំយល់ស្វាមី ក្សត្រី

ថ្ងៃថ្នា នាងនាថវែងជា ទុក្ខទូញទៅហោង ៗ ដំណើរនេះនៃ កាល

ក្សត្រីថ្លៃ ត្រាច់រកព្រះបង់ និទានគ្រានេះ យើងស្វែងក្សេណហោង ដោយ

ចវទំនង ដំណើរនាងនាថ ៗ ទើបយើងនៅថ្លែង ដំណើរដំណែង

និទានកំពោល ក្សត្រមួយអាច រើសពងកុមារ. កាលក្រោយនាងនាថ

ត្រាច់រកស្វាមី ៗ ឥឡូវនេះនៃ សុរិយាល្ងាចថ្ងៃ ថ្ងៃជាបះហើយខ្ញុំ យើង

នឹងបញ្ឈប់ ទុកស្ទុះសិនទៃ វេលាពីរប្រែថៃ គ្រាន់គ្រប់មួរហោង ៗ

(មានត)

# រឿងព្រេងនិងរឿងបុរាណប្រទេសជប៉ុន

(តមក)

លោក ភឹម-ប៊ុក រៀបរៀង

---

ព្រះមហាក្សត្រដ្ឋៃវ៉ៃ បានសូមអញ្ជើញលោកឲ្យមកធ្វើជាទក្ដមប្រឹក្សា របស់ព្រះអង្គ, តែលោកមិនព្រមទទួលដំណែងនេះ ព្រោះលោកយល់ ថា ព្រះមហាក្សត្រអង្គនេះ បានដណ្ដើមរាជសម្បត្តិពីបិតា ៗ លោក ក៏បានអញ្ជើញទៅកាន់រដ្ឋអួរអេ ; ព្រះមហាក្សត្រនៃរដ្ឋនេះ សូមឲ្យ លោកកាន់ដំណែងជាន់ខ្ពស់ ៗ ប៉ុន្តែ លោកមិនព្រមទទួល ៗ ក្នុងពេល នោះ ទទួលមានព្រះអង្គម្ចាស់ជាក្មួយនៃព្រះមហាក្សត្ររដ្ឋល្វ បានយក ដង្វាយមកជូនលោកឲ្យវិលទៅរដ្ឋល្វវិញ ៗ

លោកកុង-ហ្វុងសី បានវិលត្រឡប់ទៅកាន់រដ្ឋកំណើតរបស់លោក ក្រោយដែលលោកបានធ្វើដំណើរទៅកាន់រដ្ឋឯទៀត អស់រយៈវេលា ១៤ ឆ្នាំ ៗ ព្រះបាទឆាយព្រះចៅរដ្ឋល្វ ទ្រង់មិនបានឲ្យលោកកាន់ដំណែង អ្វីឡើយ ទ្រង់គ្រាន់តែប្រឹក្សាជាមួយនឹងលោក ចំពោះបញ្ហាណាដែល ស្មុគស្មាញ ៗ ក្នុងពេលនេះ លោកបានតែរៀបចំសៀវភៅដែលលោក តែងគឺ:

១- សៀវភៅ យី-គីង បានផ្ដល់សៀវភៅពណ៌នាអំពីការកែប្រែ គ្រប់យ៉ាង,

២ សៀវភៅ ស៊ូ-គីង បានដល់សៀវភៅប្រវត្តិសាស្ត្រ,

៣-សៀវភៅ ស៊ី-គីង បានដល់សៀវភៅពណ៌នាពីកាព្យឃ្លោង,

៤-សៀវភៅ យី-គីង បានដល់សៀវភៅក្បួន ឬ វិទ្យាសាស្ត្រ ថ្លែងនូវសមភាពរវាងមនុស្ស អមនុស្ស ទៅតាទីឋានព្រហ្ម ។

លោកបានមានប្រសាសន៍ថា: បើខ្ញុំរស់នៅ ៥០ ឆ្នាំទៀត ខ្ញុំនឹងកែប្រែ សៀវភៅភាវនា អំពីការប្រែប្រួលសព្វយ៉ាងឲ្យបានពិស្ដារជាងនេះទៅទៀត ។

មុនលោកទទួលអនិច្ចកម្ម, គង់ពេលនោះ លោកទៅបាញ់សត្វ, លោកបាញ់បានសត្វចំឡែកមួយ ហៅថា គោពិសិដ្ឋ (Licorne) ។ លោកក៏នឹកដល់ពេលដែលលោកមកចាប់បដិសន្ធិ គង់ផ្ទៃនៃមាតាលោក ។ មាតារបស់លោក បានសុបិនឃើញ សត្វគោពិសិដ្ឋនេះដែរ, លោកក៏ចេញវាចាថា "អាយុខ្ញុំអស់ហើយ" ។

តមក លោកមានជម្ងឺធ្ងន់, គង់ពេលនោះ មានសាវ័ករបស់លោកម្នាក់ បានមកសួរលោក ៗ មានប្រសាសន៍ថា:

" អ្នកមកយឺតយូរពេក . . ពិភពលោកលែងស្គាល់ធម៌ហើយ, ខ្ញុំមិនដែលបានជួបប្រទះនឹងអ្នកណាម្នាក់ ដែលចង់បានខ្ញុំ ធ្វើជាគ្រូបាអាចារ្យសោះ " ហើយលោកច្រៀងថា:

" ព្រះវិហារពិត តាំងដែលនឹកគិត ពីការគ្រាំគ្រា ដូចរូបខ្ញុំនេះ តាម

ដោយសន្ធារ តែងចាស់ត្រាំត្រា សូម្បីស្លាប់ចុះតែប៉ុណ្ណឹង ។ ដរាបណាខ្ញុំរស់នៅតែងខំ ធ្វើការត្រឹមត្រូវ ជាដង្ហើយមេឃ ឥតមានបង្អង់ សួយពីកកុផុន ឲ្យឆ្អកបានទេះ ” ។

មុនពេលដែលលោកទទួលអនិច្ចកម្មមួយថ្ងៃ លោកបានពោលថា :

កាលខ្ញុំអាយុ១៥ឆ្នាំ ចិត្តខ្ញុំខ្វល់ខ្វាយតែពីការសិក្សា, អាយុ៣០ឆ្នាំ ខ្ញុំបានពិចារណាអំពីលក្ខគោលនៃវិជ្ជាដោយមាំមួន, អាយុ៤០ឆ្នាំ ខ្ញុំលែងសង្ស័យបុច្ឆល់អំពីវិជ្ជាទាំងឡាយ, អាយុ៥០ឆ្នាំ ខ្ញុំបានស្គាល់បទបញ្ញត្តិច្បាប់មហាមេឃ គឺច្បាប់ដែលមហាមេឃបានកំណត់ចំពោះជីវសត្វមួយៗ ដើម្បីសម្រេចនូវជោគវាសនាទាំងឡាយ, អាយុ៦០ឆ្នាំ ខ្ញុំបានយល់ដោយស្រួលនូវហេតុនៃព្រឹត្តិការណ៍ទាំងឡាយ, អាយុ៧០ឆ្នាំ ខ្ញុំបានបំពេញករណីយកិច្ចចំពោះចិត្តរបស់ខ្ញុំដោយមិនឲ្យហួសកំរិតតាមសមគួរ ។

លុះដល់កំណត់ លោកក៏រលត់ខន្ធទៅកាន់លោកខាងមុខក្នុងឆ្នាំ ៤៧៩ មុនគ្រិស្តសកពជ ។

## តើលទ្ធិរបស់បណ្ឌិតកុង-ហ្វុងសឺយ៉ាងណាទៅ ?

លទ្ធិរបស់បណ្ឌិតកុង-ហ្វុងសឺ មិនមែនសំដៅយករូបមន្ត ឬចរិយារបស់បុគ្គលជាលក្ខគោលទេ, លទ្ធិកុង-ហ្វុងសឺមិនមែនជាសាសនាទេ គឺជាទស្សនវិជ្ជានីតិវិទ្យាសាស្ត្រលាយជាមួយគ្នា ។ ចំពោះលទ្ធិនេះ គ្មាន

សាសនា គ្មានសីលធម៌ទេ ! មានតែវិជ្ជានិងគតិបណ្ឌិត ដែលមានលំនាំទៅតាមជាតិចិនប៉ុណ្ណោះ ។

គោលលទ្ធិរបស់កុង-ហ្វូងសឺ និងពុទ្ធសាសនាខុសគ្នាយ៉ាងណា ?

ព្រះពុទ្ធសាសនា យក «កម្ម» គឺអំពើដែលសត្វធ្វើជាមូលដ្ឋាន, យកអដ្ឋង្គិកមគ្គទាំង៨ ជាលក្ខគោលនៃការប្រព្រឹត្តិប្រតិបត្តិ ; អ្នកណាផុនលះបង់ទូតៃណ្ហា តស៊ូចំពោះកិលេសជាគ្រឿងសៅហ្មង ធ្វើចិត្តរបស់ខ្លួនឲ្យផូរផង់ អ្នកនោះនឹងបានរួចក្តីទុក្ខតាមលំដាប់ រហូតដល់បរមត្ថសុខគឺព្រះនិព្វាន ។

លទ្ធិកុង-ហ្វូងសឺយកវិជ្ជានិងគតិបណ្ឌិតជាលក្ខគោល ដោយយល់ថា មនុស្សមានវិជ្ជា មិនយូរមិនឆាប់នឹងទៅជាបណ្ឌិត, វិជ្ជាបានជាទីទ្រស្តីគតិបណ្ឌិតបានជាទីការប្រព្រឹត្តិប្រតិបត្តិ ។ វិជ្ជានេះយកមកអនុវត្តន៍ក្នុងជីវភាពរាល់ថ្ងៃ រចនាចរិយារបស់ខ្លួនឲ្យទៅជាបណ្ឌិតបាន, ព្រោះហេតុនោះ បានជាមានពាក្យមួយឃ្លាដែលលោកកុង ហ្វូងសឺពោលទុកថា :

“ចេះឲ្យដឹងថាខ្លួនចេះ, ល្ងង់ឲ្យដឹងថាខ្លួនល្ងង់ ; នេះហៅថាចេះពិត, បើល្ងង់មិនដឹងថា ខ្លួនល្ងង់ ប្រកាន់តាំងខ្លួនជាអ្នកចេះ ធ្វើម្តេចនឹងដេញសេចក្តីល្ងង់ចេញពីសន្តានចិត្តបាន! ធ្វើម្តេចនឹងឲ្យការចេះដឹងនោះចូលមកបិតនៅក្នុងសន្តានចិត្តបាន!, លុះត្រាតែខ្លួនល្ងង់ ស្គាល់ច្បាស់ថាល្ងង់ពិត ទើបតែល្ងង់នោះ ឲ្យទៅជាបណ្ឌិតបាន ។ បណ្ឌិត

មានវិជ្ជាជាបុព្វហេតុ មានការប្រព្រឹត្តល្អជាសកម្មភាព មានសេចក្តីសុខជាផល" ។ នេះជាលទ្ធិកុង-ហ្វូងស៊ឺ ។

តើលទ្ធិកុង-ហ្វូងស៊ឺ និងលទ្ធិតាវខុសគ្នាយ៉ាងណាខ្លះ?

លទ្ធិតាវ គឺលទ្ធិរបស់បណ្ឌិតឡៅស៊ឺ ដែលយកចិត្តជាមូលដ្ឋាន គឺអសកម្មភាពជាគោល គឺថារូបកាយនៅស្ងៀម ចិត្តចេះតែពិចារណា គិតគូរ ល្បួចល្បី ឲ្យយល់នូវធម៌ទាំងឡាយ ។ នេះជាលទ្ធិតាវ ។

ឯលទ្ធិកុង-ហ្វូងស៊ឺ សំដៅយកកាយវាចាចិត្ត, គឺបើបុគ្គលប្រព្រឹត្តកាយទុច្ចរិត វចីទុច្ចរិត មនោទុច្ចរិត បានទុក្ខ ; បើប្រព្រឹត្តកាយសុចរិត វចីសុចរិត មនោសុចរិត បានសុខ ។

លទ្ធិតាវ សំដៅយកសមាធិចិត្តតែមួយ សមដូចពុទ្ធភាសិតក្នុងគម្ពីរធម្មបទខុទ្ទកនិកាយ ត្រង់គាថាចិត្តវគ្គថា:

ទុន្និគ្គហស្ស លហុនោ យត្ថ កាមនិបាតិនោ

ចិត្តស្ស ទមថោ សាធុ ចិត្តំ ទន្តំ សុខាវហំ ។

ប្រែថា សេចក្តីបង្ហាត់ចិត្ត ដែលសង្កត់សង្កិនបានដោយក្រ ដែលស្រាល មានប្រក្រតីធ្លាក់ទៅតាមប្រាថ្នាក្នុងអារម្មណ៍ណាមួយបាន ជាគុណឲ្យសម្រេចប្រយោជន៍ ព្រោះចិត្តដែលគេបង្ហាត់បាន តែងនាំសុខមកឲ្យ ។

ថ្ងៃមួយ លោកសីលូ បានសួរបណ្ឌិតកុង-ហ្វូងសឺថា ដូចម្ដេច ដែលហៅថា មនុស្សល្អ? ។

បណ្ឌិតកុង-ហ្វូងសឺឆ្លើយថា មនុស្សល្អ គឺមនុស្សចេះគោរពគោរពខាងចាស់ព្រឹទ្ធាចារ្យ ។

លោកសីលូ សួរថា: តែប៉ុណ្ណោះទេឬ លោកគ្រូ? ។

បណ្ឌិតកុង-ហ្វូងសឺឆ្លើយថា: មនុស្សល្អធ្វើខ្លួនឱ្យបានចំរើន ហើយញុំាងអ្នកដទៃឲ្យចំរើនផង ។

លោកសីលូ សួរទៀតថា តែប៉ុណ្ណោះទេឬ លោកគ្រូ? ។

បណ្ឌិតកុង-ហ្វូងសឺឆ្លើយថា មនុស្សល្អ ធ្វើខ្លួនឱ្យបានចំរើនដើម្បីសន្តិភាពផែនដី ។

## ប្រមូលទ្ធិលោកកុង-ហ្វូងសឺ គឺ:

១–កម្ម ,

២–ការរៀនសូត្រវិជ្ជាទាំងឡាយ ,

៣–ការប្រព្រឹត្តិប្រតិបត្តិនូវវិជ្ជាទាំងឡាយ ដើម្បីបនាខ្លួនឲ្យមានវឌ្ឍនភាព ,

៤–ការគោរពដល់ដូនជីតា ទេវតា អមនុស្ស ។ល។ ,

៥–គតិបណ្ឌិត ។

# អធិប្បាយ

១ កម្មៈ ប្រែថា អំពើ; អំពើល្អ អំពើអាក្រក់ ហៅថាកម្ម; អ្នកណាធ្វើល្អ បានល្អ, អ្នកណាធ្វើអាក្រក់ បានអាក្រក់, ហេតុបែបណា បានផលបែបនោះ ហេតុល្អផលល្អ, ហេតុអាក្រក់ផលអាក្រក់ ជីវសត្វនិងធម្មជាតិទាំងឡាយ មានហេតុមានផល, សកម្មភាពនៃមនុស្សទាំងឡាយមានគោលការ មានកំសួល, ស្គាល់ហេតុ-ផល ឈ្មោះថាស្គាល់គោលការនិងកំសួល ។ នេះជាពិធីសំរាប់ដឹកនាំវិចារណញ្ញាណរបស់មនុស្សទៅកាន់សុក្រឹតភាព ។

២-ការរៀននូវវិជ្ជាទាំងឡាយៈ លោកកុង-ហ្វុងស៊ឺបានពោលថា ត្រូវតែសិក្សានូវវិជ្ជាទាំងឡាយ, ឯការសិក្សា ត្រូវតែពិនិត្យហើយចំណាំ បើគ្មានការពិចារណា នាំឲ្យខាតពេលវេលា, ពិចារណា តែគ្មានការសិក្សានាំឲ្យកាន់ច្រឡំ ។

តើការសិក្សាជាអ្វីទៅ ?, ការសិក្សាគឺការរៀនយកនូវវិជ្ជាទាំងឡាយ រួចពិចារណាឲ្យយល់ការខុសត្រូវ ហេតុផលសព្វគ្រប់ ។

៣-ការប្រព្រឹត្តិប្រតិបត្តិនូវវិជ្ជាទាំងឡាយ ដើម្បីបនាខ្លួនឲ្យមានវឌ្ឍនភាពៈ លោកកុង-ហ្វុងស៊ឺបានពោលថាៈ ឧត្តមសិក្សាឬទស្សនវិជ្ជាខាងវិធីប្រតិបត្តិ គឺការធ្វើឲ្យចំរើនខាងវិចារណញ្ញាណដែលយើងបានទទួលពីព្រះអាទិទេព (Roi du ciel) ដើម្បីបនាខ្លួនឲ្យមានសភាពជិត្តន៍

ខ្ពស់ ។ ករណីយកិច្ចត្រូវតែមានដូចគ្នា ចាប់តាំងពីមនុស្សខ្ពង់ខ្ពស់បំផុត រហូតដល់មនុស្សថោកទាបលិចលង់ ។ ការកែប្រែឬរចនាខ្លួនឯងឲ្យបានវិសិដ្ឋភាពចាត់ជាមូលដ្ឋាននៃវឌ្ឍនធម៌ដោយពិត ។ មនុស្សដែលមានប្រាជ្ញាមុតមាំ ឬបញ្ញាមធ្យម អាចសិក្សានូវឧត្តមវិជ្ជាបាន ។ មនុស្សដែលមានបញ្ញាទន់ខ្សោយ ជាងបញ្ញាមធ្យម មិនអាចសិក្សានូវឧត្តមវិជ្ជាបានឡើយ ។

៤- ការគោរពជីដូនជីតា ទេវតា អមនុស្ស ។ល។ : គឺការប្រើកម្លាំងរបស់ខ្លួនដើម្បីយុត្តិធម៌ ដល់ការគោរពជីដូនជីតា ។ ល ។ នេះហៅថាជេះ ។ ពួកទេវតានឹងទេពធីតាដែលត្រួតត្រាពិភពលោក, ពាក្យចិនថា ខៀន-ម៉ីង ប្រែថា "អំណាចស្ងាត់" បានដល់អាណត្តិរបស់ព្រះអាទិទេព ។ អាណត្តិនេះ គឺគេប្រគល់ជូនចំពោះបុគ្គលណាដែលមានគុណសម្បត្តិ ចរិយាសម្បត្តិបរិបូណ៌ ។

៥- គតិបណ្ឌិត: អ្នកណាមួយ មានការសិក្សាល្អហើយ ប្រតិបត្តិទៅតាមការចេះដឹងនោះ, បើពោលដោយចំពោះ គឺអ្នកណាមួយយល់ការខុសត្រូវដោយខ្លួនឯង អ្នកនោះឈ្មោះថា មានគតិបណ្ឌិត ។

លោកកុង-ហ្វ៊ូស៊ឺ បានពោលថា មនុស្សដែលមានគុណសម្បត្តិដ៏ឧត្តុង្គឧត្តម ព្យាយាមក្នុងការប្រព្រឹត្តផ្លូវកណ្ដាល ផ្លូវកណ្ដាលនេះឯងជាកំពូលនៃគុណសម្បត្តិទាំងឡាយ ។

អ្នកណាមិនស្គាល់ផ្លូវកណ្តាល អ្នកនោះមិនស្គាល់ធម៌ មិនស្គាល់មូលដ្ឋានពិតនៃលោកនិងច្បាប់សាកល ឈ្មោះថា មិនអាចប្រាស្រ័យចំពោះវត្ថុដែលគេឃើញដោយមំសចក្ខុ ។

ព្រោះហេតុនោះ ទើបបណ្ឌិតកុង ហ្វូស៊ី បានណែនាំមនុស្សឲ្យប្រតិបត្តិតាមផ្លូវកណ្តាល ជាហេតុនាំមនុស្សឲ្យបានសេចក្តីសុខគ្រប់យ៉ាង ។

## សុភាសិតរបស់បណ្ឌិតកុង-ហ្វុងស៊ី

### ក) អាណត្តិព្រះអាទិទេព

-អាណត្តិព្រះអាទិទេព គឺជាគោលការសម្រាប់ប្រតិបត្តិតាមផ្លូវប្រាជ្ញា ដែលព្រះអាទិទេពបានផ្ញើអំណោយចំពោះសត្វទាំងឡាយ ។

-អាណត្តិព្រះអាទិទេព រមែងផ្តល់អំណាចមកឲ្យមនុស្សគ្រប់រូប ប៉ុន្តែបើមនុស្សប្រកបដោយទុច្ចរិត, អាណត្តិព្រះអាទិទេពរមែងលះបង់ចោលមនុស្សបែបនេះ ។

-កាលណា គេប្រព្រឹត្តល្មើសនឹងអាណត្តិព្រះអាទិទេព គ្មានអ្នកណាជួយទេ ។

-ក្នុងលោកគ្មានព្រះអាទិទេពពីរទេ, ប្រជារាស្ត្រគ្មានព្រះមហាក្សត្រពីរដែរ ។

ខ) ជីដូនជីតា

- ត្រូវធ្វើពលិកម្មចំពោះជីដូនជីតា ហាក់ដូចជាជីដូនជីតានោះមកឋិតនៅចំពោះមុខយើង ហើយត្រូវគោរពទឹកសំដែងនូវកតញ្ញូតាធម៌ចំពោះលោកជានិច្ច ។

គ) បុរាណបណ្ឌិត

- ខ្ញុំជឿជាក់ចំពោះបុរាណបណ្ឌិត ទើបខ្ញុំមានចិត្តភក្តីចំពោះលោក ខ្ញុំកើតមកមិនមែនឯកការីវិជ្ជាមកដទៃទេ ខ្ញុំជាមនុស្សស្រឡាញ់បុរាណបណ្ឌិត ហើយខ្ញុំព្យាយាមស្រាវស្រាវរកវិជ្ជារបស់លោក ។

លោកសឺ - តាង ឆ្ពងសួរទៅបណ្ឌិតកុង-ហ្វូសឺ ថា "សូមលោកគ្រូមេត្តា! តើមាគ៌ានៃការប្រតិបត្តិរបស់មនុស្សដែលមានគុណសម្បត្តិនោះ តើយ៉ាងណា ?" ។ លោកកុង - ហ្វូសឺតបថា: "មាគ៌ានេះជាមាគ៌ាគ្រាប់គ្រង់ទៅមុខ មិនចាំបាច់ធ្វើតាមបុរាណបណ្ឌិតទេ, " បើរដ្ឋបុរសត្រូវគ្រាប់ប្រទេសអស់រយៈ៧ឆ្នាំ រដ្ឋបុរសនោះ អាចបេនាមនុស្សអាចឲ្យទៅជាស្លូត ហើយបំបាត់នូវអាការៈកំណាចចំពោះអ្នកដទៃបាន " ។

ឃ) ភាពទំនៀតដែលមើលមិនឃើញ

បើគេមិនអាចប្រព្រឹត្តទៅលើមនុស្សដោយសមរម្យបាន ម្តេចឡើយគេនឹងអាចប្រព្រឹត្តទៅនឹងអមនុស្សបាន! ។

បណ្ឌិតមិនដែលពោលអំពើកំហឹងចំពោះអ្នកណាឡើយ ។ តែងត្រូវ

គ្រាប្រទេសខ្វះខាតដោយប្រើគុណសម្បត្តិនិងសមត្ថភាពដ៏ពេញលក្ខណៈ គឺដូចជាផ្កាយក្រពើដែលបិតនៅស្ងៀមឥតប្រែប្រួល ចំណែកផ្កាយឯទៀតវិលជុំវិញផ្កាយនោះ ហើយយកផ្កាយនោះជាមគ្គុទ្ទេសក៍ ។

ប្រាជ្ញារបស់វេជ្ជបុរសមានសភាពសមៀមអស្ចារ្យ ផលនៃប្រាជ្ញានោះអាចពាយអនាគតបាន ។

ង) ទំនៀមទម្លាប់និងកេរ្តិ៍

កាលណាមាតាបិតារស់នៅ យើងត្រូវបំពេញករណីយកិច្ចចំពោះលោកទាំងពីរ ដោយយកគោលច្បាប់ព្រះអាទិទេពមកជាមូលដ្ឋាន ។

កាលបើ មាតាបិតាទទួលអនិច្ចកម្ម ត្រូវយកសពលោកទៅកប់ឲ្យស្រួលបួលដោយធ្វើពិធីបុណ្យតាមទំនៀមទម្លាប់ ។

ច ) ឧត្តមមនុស្ស ( មនុស្សខ្ពង់ខ្ពស់ )

ឧត្តមមនុស្ស កាលណាលោកអង្គុយដិតតុបរិភោគអាហារ លោកមិនបរិភោគដោយប្រញាប់ប្រញាល់តាមឃ្លាននោះទេ, កាលណាលោកបិតនៅក្នុងផ្ទះរបស់លោក, លោកមិនបិតនៅស្ងៀម ឬក្រេកត្រអាលសប្បាយដោយកាមគុណទេ, លោករមែងតាំងខ្លួនលោកក្នុងអប្បមាទធម៌ គឺប្រព្រឹត្តករណីយកិច្ច ពោលពាក្យផ្អែមល្ហែមជានិរន្តរ៍, លោកចូលចិត្តសេពគប់មនុស្សដែលមានចិត្តស្លូតត្រង់ ដើម្បីនឹងកែប្រែចរិយាមារយាទរបស់លោកឲ្យដូចមនុស្សនោះ ។

ឧត្តមមនុស្ស គឺមនុស្សដែលយកពាក្យល្អរបស់ខ្លួនមកអនុវត្ត ហើយពោលៈទៅតាមសកម្មភាពល្អរបស់ខ្លួន ។ លោកតែងប្រព្រឹត្តសេចក្តីល្អទៅលើមនុស្សទាំងអស់ មិនស្រឡាញ់អ្នកនេះ ស្អប់អ្នកនោះឡើយ ។

ហីនមនុស្ស (មនុស្សថោកទាប) តែងមានគំនិតតែប្រយោជន៍ផ្ទាល់ខ្លួន គ្មានចិត្តល្អចំពោះមនុស្សផងគ្នាទេ ។

ឧត្តមមនុស្ស យកតែសេចក្តីសុចរិតជាមូលដ្ឋានសម្រាប់ប្រតិបត្តិ ។

ឧត្តមមនុស្ស មានចិត្តទឹងធឹង ទឹកចិត្តស្ងប់ស្ងាត់ ។

ឧត្តមមនុស្ស ទោះមនុស្សមានគុណសម្បត្តិឧត្តុង្គឧត្តម តែងព្យាយាមដើរតាមផ្លូវកណ្តាល ។

ឧត្តមមនុស្ស ព្យាយាមពិចារណា កុំឲ្យអកុសលចូលមកសង្កត់ចិត្តរបស់លោកបាន ។

ឧត្តមមនុស្ស តែងធ្វើឲ្យចំរើនគុណសម្បត្តិមនុស្សឯទៀតជានិច្ច ។

ឧត្តមមនុស្ស តែងរស់នៅដោយសន្តិភាពចំពោះមនុស្សទាំងឡាយ តែមិនប្រព្រឹត្តតាមមនុស្សទាំងនោះទេ ។ មនុស្សថោកទាប តែងប្រព្រឹត្តប្រតិបត្តិតាមមនុស្សថោកទាប តែមិនរិះរកមធ្យោបាយបំពេញសកម្មភាពរបស់ខ្លួន ឲ្យត្រូវនឹងសកម្មភាពរបស់ឧត្តមមនុស្ស ។

បុគ្គលពិបាកថែរក្សាទាសីទាសាណាស់, បើទុកវាជាបងប្អូន វាមិនខ្លាចយើង បើឲ្យវានៅឆ្ងាយពីខ្លួន វានឹងស្អប់គំនុំគំគួនយើង ។

ដើម្បីនឹងឲ្យបានគុណធម៌, ត្រូវយើងខំបំពេញករណីយកិច្ចជាទី ១, ត្រូវទុកលទ្ធផលនៃករណីយកិច្ចនេះជាទី ២ ។

ឆ) ការឲ្យដំនឹងខុសតាម- ការគួរសម

អំពើទាំងអស់ អ្នកអាចប្រព្រឹត្តបានដោយសេរី ប៉ុន្តែកុំឲ្យសេពគប់នឹងមនុស្សដែលមានប្រាជ្ញានឹងចិត្តវង់ខ្វាយជាងអ្នក, បើអ្នកធ្វើខុស ត្រូវប្រញាប់កែចរិយារបស់អ្នកភ្លាម ។

ចូរអ្នកពិចារណាដោយម៉ឺងម៉ាត់នូវចរិយារបស់មនុស្សថា តើមនុស្សទាំងនោះ មានចរិយាបែបណាខ្លះ? ។ តើអ្វីដែលនាំឲ្យរីករាយសប្បាយចិត្ត ។

ឈើពុកគេមិនអាចយកមកឆ្លាក់ជាក្បាច់រចនាបានទេ ឯដញ្ជាំងកក់កំបោរគេមិនអាចលាបថ្នាំពណ៌សបានដែរ ។

អ្នកណាដែលមានវិជ្ជា តាំងពីថ្ងៃដែលកើតមក អ្នកនោះគេហៅថាបណ្ឌិតទី ១, អ្នកណាដែលព្យាយាមក្នុងការសិក្សា ទើបមានវិជ្ជា អ្នកនោះគេហៅថា បណ្ឌិតទី ២, អ្នកណាមានបញ្ញាអាប់ឱន ប្រឹងព្យាយាមសិក្សា ទើបមានវិជ្ជា អ្នកនោះ គេហៅថា បណ្ឌិតទី ៣, អ្នកណាល្ងង់ខ្លៅ, ហើយមិនរៀនសូត្រ អ្នកនោះ គេហៅថា មនុស្សល្ងង់ ។

សកម្មភាពអាក្រក់ ៤ យ៉ាងគឺ:

១.អ្នកណាមិនខ្វល់ខ្វាយ ប្រដៅប្រជាពលរដ្ឋ, ហើយយកប្រាជ្ញាទៅ

សម្លាប់ប្រជារាស្ត្រ ឲ្យប្រជារាស្ត្រធ្លាក់ទៅកាន់សេចក្តីអាក្រក់ អ្នកនោះគេហៅថា មនុស្សកំណាច ។

២-មិនដាស់តឿនប្រជារាស្ត្រជាមុន ហើយបណ្តោយឲ្យគ្នាប្រព្រឹត្តទៅតាមវិធីគនិងផល នេះគេហៅថា កំហែងចង្ហំ ។

៣-មិនបង្គាប់គ្នាឲ្យច្បាស់លាស់ ហើយចង់ឲ្យការងារសម្រេចដោយល្អ នេះគេហៅថា អយុត្តិធម៌ ។

៤-ធ្វើចិត្តកំណាញ់ចំពោះខ្លួនដទៃមនុស្សទាំងឡាយ នេះគេហៅថា មានភាគប្បកិរិយាអាក្រក់ ។

ឧត្តមវិជ្ជាមិនត្រូវផ្តល់ឲ្យមនុស្សល្ងង់ទេ ។

មនុស្សមានប្រាជ្ញាមធ្យម គេអាចនឹងប្រាប់នូវឧត្តមវិជ្ជាបាន ។

បើអ្នកចង់សន្ទនានឹងមនុស្សចំពោះរឿងខាងប្រាជ្ញា បើអ្នកអាក់ខានមិនបានសន្ទនា អ្នកនឹងខូចកិត្តិយសចំពោះខ្លួនឯង ។ បើមនុស្សណាមួយ មិនត្រូវការដោយការទូន្មានពីអ្នកខាងប្រាជ្ញា បើអ្នកនៅតែទូន្មានមនុស្សនោះ អ្នកនឹងសាបសំដី ។ មនុស្សជាបណ្ឌិតមិនឲ្យខូចកិត្តិយសចំពោះមនុស្សទាំងឡាយសោះឡើយ ទាំងមិនឲ្យខូចការទូន្មានរបស់ខ្លួនចំពោះអ្នកដទៃផងទៀត ។

គួរអ្នកទូន្មានចំពោះជនដទៃ កុំប្រកាន់ឋានៈឲ្យសោះ ។

តាមធម្មតា បើយើងមានការគប់រកចង់ភ្ជាប់ជិតគ្នាបាន ។បើមិនមានការគប់ យើងបែកនៅឆ្ងាយពីគ្នា ។ មានតែមនុស្សដែលមានវិជ្ជាជាន់ខ្ពស់ទេ មិនប្រែប្រួលក្នុងការសេពនៅ ជាមួយមនុស្សទាំងឡាយដែលល្ងង់ខ្លៅ ។

ជ) ការត្រួតត្រាមនុស្សទាំងឡាយ-ប្រជាកស្រ្ត

បណ្ឌិតដែលត្រួតត្រា, ត្រូវធ្វើសេចក្ដីល្អចំពោះប្រជាកស្រ្ត, បង្ខំឲ្យប្រជាកស្រ្តធ្វើការ, កុំធ្វើអាចារ្យកិរិយាឲ្យប្រជាកស្រ្តស្អប់, ចង់បានគោរព្យជាបន្ថែម កុំលោភលន់កំណាញ់ហួសប្រមាណ, ត្រូវមានបរិយាថៃថ្នូរ ទីងមារយាទឧត្ដមឧត្ដម ។

បើមន្ត្រីនៅក្នុងសង្គមគោរពទំនៀមទម្លាប់ ប្រជាកស្រ្តនឹងមិនខ្វាបគោរពទំនៀមទម្លាប់ទេ, បើមន្ត្រីប្រព្រឹត្តដោយយកយុត្តិធម៌ជាមូលដ្ឋានប្រជាកស្រ្តគោរពកោតខ្លាចជានិរន្តរ៍, . បើមន្ត្រីពេញចិត្តប្រព្រឹត្តដោយសេចក្ដីស្មោះស្ម័គ្រនឹងកតញ្ញូភាព, ប្រជាកស្រ្តតែងតែប្រព្រឹត្តប្រតិបត្តិតាមខ្លះៗ បើមន្ត្រីយកចរិតជាមូលដ្ឋាន, ប្រជាកស្រ្តលែងគោរពកោតខ្លាច ។

បើមន្ត្រីធ្វើសេចក្ដីល្អ ហើយគ្មានអ្នកណាយល់ជួយ នេះជាការល្អបំផុតគ្មាន, បើធ្វើសេចក្ដីអាក្រក់ ហើយគ្មានអ្នកណាឃាត់ហាម នេះជាហេតុធ្វើរដ្ឋឲ្យវិនាស ។

មន្ត្រីបើមានបំណាច់ចង់ឲ្យរដ្ឋចំរើន, ត្រូវតែត្រួតត្រាព្រះរាជអាណាចក្រដោយល្អ, បើចង់ឲ្យព្រះរាជអាណាចក្រគង់វង់ ត្រូវគិតតែប្រយោជន៍របស់រដ្ឋទុនអ្នកទាំងអស់ ។

ឈ) ទាវៈផ្សេង ៗ

របៀបមិនមែនឋិតនៅឆ្ងាយពីមនុស្សទេ, បើរបៀបឋិតនៅឆ្ងាយពីមនុស្ស គេមិនហៅថា របៀបទេ ។ មនុស្សគោរពធ្វើផ្លូវនៃគុណធម៌ឲ្យទូលំទូលាយបាន, ផ្លូវនៃគុណធម៌មិនអាចធ្វើមនុស្សឲ្យធំទៅបាន ។

មនុស្សណាមួយស្អប់យើង ត្រូវប្រើសេចក្ដីយុត្តិធម៌ទៅវិញ, ឯមនុស្សដែលធ្វើល្អនឹងយើង ត្រូវធ្វើល្អទៅវិញ ។

មានចិត្តស្មោះត្រង់ហើយស្រឡាញ់អ្នកដទៃ ឲ្យដូចការស្រឡាញ់ខ្លួនឯង ។

បណ្ឌិតមានការយឺតក្នុងការពោលពាក្យ រហ័សក្នុងកិច្ចការដែលត្រូវធ្វើ ។

ចប់លទ្ធិរបស់បណ្ឌិតកុង·ហ្វង់សឺ

(មានត)

# រឿងស្រីគ្រប់លក្ខណ៍

(តមក)

យុក-វិធីរ រៀបរៀង លោក ផេង-ជ្រីវ ពិនិត្យ

ប្ដីជាអ្នកជញ្ជាត់ ប្រពន្ធកណ្ដៀតកញ្ជើតាមក្រោយ តែកញ្ជើនោះធ្លុះបាត ៗ ប្ដីជញ្ជាត់បានត្រី ហើយចាក់ដាក់មកក្នុងកញ្ជើដែលប្រពន្ធកណ្ដៀត ឯត្រីជញ្ជាត់បានធ្លាក់ទៅក្នុងទឹកអស់ តាមរន្ធកញ្ជើធ្លុះ ឯប្រពន្ធឥតអើពើសោះ ៗ លុះលុយទឹកជញ្ជាត់ទៅ ៗ ប្ដីប្រពន្ធ ក៏សត់បានទៅដល់ទន្ទឹមនឹងសំពៅមួយដែលឈប់ចតនៅទីនោះ ៗ ប្រពន្ធនាយសំពៅ កាលបើឃើញត្រីចេះតែធ្លាក់ទៅក្នុងទឹកវិញតាមរន្ធកញ្ជើដូច្នោះ ក៏មានវាចាប្រាប់ទៅប្រពន្ធមាយើងថា នាងអើយ! ហេតុអ្វីក៏មិនរកបាចស្មៅចុករន្ធកញ្ជើ ! មិនអាណិតប្ដីទេឬ គាត់ខំជញ្ជាត់បែកញើសហូរញើស ហើយត្រីឥតមាននៅគង់មួយសោះដូច្នេះ ៗ នាយសំពៅនិមិត្តតែបានពួករយានៃអាត្មាពេលដូច្នោះក៏ប្រច័ណ្ឌ ដោយនឹកស្មានថា ប្រពន្ធខ្លួនស្រឡាញ់មាយើង ហើយនិយាយបន្ទោសថា ហងឯងចេះដឹងអ្វី! ៗ ប្រពន្ធឆ្លើយថា បានជាខ្ញុំប្រាប់ ព្រោះអាណិតប្ដីដែលខំជញ្ជាត់ស្ទើរស្លាប់ហើយឥតមាននៅសល់ត្រីមួយ ៗ នាយសំពៅក្ដៅចុងច្រមុះ ពោលកំហែងប្រពន្ធថា បើហងឯងស្រឡាញ់វាណាស់ក៏ទៅចុះ អញឥតស្រណោះទេ ៗ ដែលនាយសំពៅហានពោលយ៉ាងនេះ

ព្រោះមួយវិញដោយការប្រច័ណ្ឌ មួយទៀត ដោយឃើញប្រពន្ធមាឃើងមានរូបល្អហើយចង់បាន រួចនាយសំពៅហៅមាឃើងមកនិយាយជួរប្រពន្ធគ្នា ។ ប្រពន្ធមាឃើងបាននៅនាយសំពៅ ប្រពន្ធនាយសំពៅបានមកមាឃើង ដោយប្រការដូច្នេះ ។

លុះនាយនិយាយចប់ហើយ សោភណាទឹកពេញចិត្តចំពោះប្រពន្ធនាយសំពៅដែលបានមកជាប្រពន្ធមាឃើងភ្លាមៗ ។ នាងធ្វើការ នាងដើរ នាងគេង នាងតែងនឹកដល់ប្រពន្ធមាឃើង ដែលជាស្រីគ្រប់លក្ខណ៍ជានិច្ចកាល។

ពេលវេលាពាំងចក្របស់ខ្លួនឲ្យប្រព្រឹត្តទៅជាធម្មតា ។ ចំណែកសោភណាកាន់តែពេញរូបពេញរាង ហើយជាស្រីទ្រាញពាក់កាននៃកូនឈូលពាំងឡាយព្រមទាំងអ្នកស្រុកជិតខាង ។

ខ្សៀវនាងដល់សោឡសឆ្នាំហើយ ។ នាងធ្វើកិច្ចការក្នុងផ្ទះទាំងអស់ជំនួសម្ដាយនាង ។ សោភណាមិនប្រកាន់ខ្លួនប៉ុណ្ណា ។ ពល់ថ្ងៃនាងក្បាត់ពីព្រលឹម ដើរហាលដោយកាន់ផ្លែឈើ ទូរកូនឈូលប្រុសស្រីឲ្យចេញទៅធ្វើការតាមនាទីរៀងខ្លួន ៖ មានមានទាសីជំនិតពីរនាក់សម្រាប់ទៅធ្វើការផ្ទះជាមួយ គឺនាងសុភី ១ នាងចន្ទី ១ ។ សុភីនឹងចន្ទីមានអាយុច្រើនជាងនាងបន្តិច ។ ទោះបីមានការទុកចិត្តចំពោះសេចក្ដីស្មោះត្រង់នៃទាសីទាំងពីរនោះក៏ដោយ សោភណានៅតែមិន

បណ្ដោយឲ្យទាសីធ្វើការតែឯកឯង ដោយមិនមានការត្រួតពិនិត្យមើលនោះឡើយ ។

ក្រោយពេលដែលឈ្នួលប្រុសស្រីចេញផុតទៅ នាងត្រួតមើលស្ពូកទីងចន្ទីបោសផ្ទះជូតតុទូ ដងទឹកដាក់ពាង បោកគក់សំលៀកបំពាក់លាងចានឆ្នាំងអំបែង ។ល។ នាងមិនបណ្ដោយឲ្យស្ពូកទីងចន្ទីផណ្ដាំស្មូទេ នាងទុកគ្រាន់តែឲ្យជួយកំឡាំងនាងប៉ុណ្ណោះ ។ ព្រោះនាងយល់ថា បាយសម្លមិនឆ្ងាញ់ពិសា ជាហេតុនាំឲ្យកូនឈ្នួលធ្វើការមិនពេញលេញ និងជាហេតុនាំឲ្យចំណាយប្រាក់អស់ច្រើន ។ នាងមិនកំណាញ់ទេ ប៉ុន្តែក្នុងឋានៈជាស្ត្រីមេផ្ទះ នាងយល់ចិត្តថា ត្រូវតែចេះសំចៃ ត្រូវចេះរកឧបាយយ៉ាងណា ធ្វើកុំឲ្យចាយប្រាក់ឥតប្រយោជន៍ ។ បើស្ពូកទីងចន្ទី ធ្វើឲ្យបែកឆ្នាំងឬបែកចានឬក៏ធ្វើអ្វីមិនសមរម្យ នាងមិនបន្ទោសទេ នាងបែរជាពន្យល់ហើយឲ្យដំបូន្មានវិញ ។ ម្ល៉ោះហើយទាសីទាំងពីរគោរពនាង ព្រមទាំងមានចិត្តស្រឡាញ់នាងជាទីបំផុត ។

ធនសេដ្ឋីនិងភរិយាស្រឡាញ់កូនណាស់ ហើយទុកសោភណាជាព្រះចន្ទ្រមួយវង់ក្នុងគេហស្ថានរបស់លោក ។ សោភណាដឹងគួរសមណាស់ចំពោះភ្ញៀវនិងមិត្តភក្តិនៃលោកធនសេដ្ឋីជាបិតា ។ កាលណាមានភ្ញៀវមកផ្ទះ នាងយកទឹកតែបារីឬហិបស្លាដាក់ជូន ដោយមុខរីករាយ មិនចាំបាច់ឲ្យឪពុក-ម្ដាយបង្គាប់ឡើយ ។ អាកប្បកិរិយាដ៏សុខុមរបស់

ខាង បណ្ដាលឲ្យភ្ញៀវមានចិត្តត្រេកអរនឹងសរសើរយើងពន់ពេក ។ មានពាក្យចំនៀមខាងឥណ្ឌាថា: "មានភ្ញៀវមកផ្ទះ ឈ្មោះថាគេនាំសិរីសួស្ដីមកឲ្យ" ។ ដូច្នេះទោះបីយើងកំពុងមានចិត្តថាំងថាក់វេទនាក្នុងផ្ទះក៏ដោយ បើមានភ្ញៀវចូលមក ត្រូវយើងសំដែងកិរិយាពេះពយកពក់ពាក់នៅកេះភ្ញៀវមួយខណៈសិន បើមិនដូច្នោះ សិរីសួស្ដីដែលភ្ញៀវនាំមកនឹងវិនាសចេញពីផ្ទះយើង ។

សូម្បីសូមយាចកក៏ដោយ តែមកដល់ផ្ទះសោកណាហើយ ទៀងតែនឹងបានអ្វីខ្លះត្រឡប់ទៅវិញជាមិនខាន ។ ម្ល៉ោះហើយជនសេដ្ឋីបានទៅជាកុដុម្ពិកម្នាក់ជាទីស្រឡាញ់រាប់អាន របស់មនុស្សទាំងឡាយក្នុងស្រុកជាមួយផង ក្នុងស្រុកដទៃផង ។

## ជំពូក ២

លុះវិលត្រឡប់មកផ្ទះកំណើតវិញ សិរីវឌ្ឍន៍ឥតព្រួយប្រហែសក្នុងការងារឡើយ ។ អ្នកជួយធ្វើកសិកម្មម្ដាយ មិនចាយប្រាក់ផ្ដេសផ្ដាស ចំសំចៃលុយទុកដើម្បីការពារនឹងឧបសគ្គជាយថាហេតុ ដែលអាចនឹងកើតមានឡើងបានក្នុងគ្រួសារ ។

បន្ទាប់ពីពេលអាពាហ៍ពិពាហ៍នៃចៅជនជាមិត្រ សិរីវឌ្ឍន៍គិតថា: "ខ្លួនអញជាមិត្រនឹងជន ឥឡូវគេមានប្រពន្ធហើយ ។ នាំកិរិយាទៅនៅដីភូមិល្អ ដើម្បីប្រកបអាជីវកម្ម ចំណែកខ្លួនអញគួរគប្បីតែទៅល្បងស្វែង

រកស្រីគ្រប់លក្ខណ៍ តាមក្បួនដែលបានរៀនមក ដើម្បីដណ្ដឹងយកធ្វើជាប្រពន្ធ ។ ជីវភាពនៃគ្រួសារអញសព្វថ្ងៃ មានសភាពជាមួនគួរសមហើយ គឺជាប្រាក់កាសមានទុកបំរុងក្នុងការចាយវាយគ្រប់គ្រាន់ តាមឋានៈនៃគ្រួសារមធ្យម " ។

លុះពិចារណាដូច្នេះហើយ សិរីវឌ្ឍន៍សុំលាម្ដាយមេម៉ាយចេញដើរស្វែងរកស្រីគ្រប់លក្ខណ៍ ដើម្បីដណ្ដឹងយកមកធ្វើជាគូស្រករ ។ អ្នកបានជំរាបអ្នកមានគុណថា : "សូមអ្នកម្ដាយប្រាប់ថា ដរាបណាកូនមិនបានជួបស្រីគ្រប់លក្ខណ៍ ដរាបនោះកូនមិនវិលវិញឡើយ" ។

នាងសារី កាលបើបានឮកូនលាចេញទៅស្វែងរកស្រីគ្រប់លក្ខណ៍ នឹកចង់ឃាត់កូនដែរ ព្រោះខ្លួនគាត់តែចាស់ តែនាងបែរជាអាក់ខានវិញ ដោយនឹកឃើញថា បើឯងឃាត់កូនទៅ ហាក់ដូចជាបង្អាក់បំណងរបស់កូនជាបំណងដែលកូនបានចិញ្ចឹមទុកក្នុងចិត្ត មកយូរណាស់ហើយ ។ ប៉ុន្តែ នាងគ្រាន់តែទូន្មានកូនថា: " កិរិយាមារយាទជាដើមទុន ឯទ្រព្យសម្បត្តិនិងវិជ្ជាជាដើមក្រោយ ត្រូវកូនប្រតិបត្តិពាក្យម្ដាយកុំប្រមាទ"

ចៅសិរីវឌ្ឍន៍ត្រាច់ចរពៃគយគន់ពីភូមិតូចចូលភូមិធំ ពីស្រុកមួយទៅស្រុកមួយឆ្លងកាត់ខេត្តខណ្ឌ ចូលកាន់ទីក្រុងនិគម ប្រយោជន៍រកនារីគ្រប់លក្ខណ៍ ។ ចួនកាលអ្នកសំណាក់ទីផ្ទះអ្នកស្រុក ចួនកាលចូលសំណាក់ក្នុងវត្តលោកសង្ឃ ។ ការស្វះស្វែងនេះ បានជួបប្រទះឧបសគ្គ

ទីនេះសេចក្ដីទុក្ខលំបាកច្រើនប្រការ ៗ ប្រាក់កាសដែលយកពីផ្ទះទៅចាយ អស់រលីង សំលៀកបំពាក់រហែកគ្មានសល់ ៗ បើយ៉ាងដូច្នេះ តើអ្នកទីនេះធ្វើដូចម្ដេច ដើម្បីញ៉ាំងវត្ថុបំណងរបស់អាត្មាឲ្យសម្រេច ? មានមធ្យោបាយមួយ បានផុះឡើងប្រាកដ ចំពោះដួងចិត្តនៃអ្នកស្វះស្វែងកំសត់ ដើម្បីដោះស្រាយបញ្ហាជីវភាពបណ្ដោះអាសន្ន ៗ អ្នកចូលស៊ីឈ្នួលក្នុងសំណាក់អ្នកស្រុក អ្នកកាន់របរកសិកម្ម អ្នកស៊ីឈ្នួលតែងតែញញួចចិត្តគ្រប់គ្នាចំពោះការងារ ទីនេះចរិយាវៃស័ក្ដិទេ ៗ ទោះបីគេមានការស្និទ្ធស្នាលនឹងខ្លួនយ៉ាងណា ក៏អ្នករក្សាការសម្ងាត់របស់ខ្លួនមិនឲ្យអ្នកណាម្នាក់ដឹងឮឡើយ ៗ

ជួនកាលអ្នកចូលធ្វើការឈ្នួលគេសរយៈពេលមួយខែ ជួនកាលពីរ-ខែ ឬ បីខែ ជួនកាលមួយឆ្នាំក៏មាន ហើយអ្នកច្បៀតឱកាសនោះ ក្នុងពេលមានពិធីអ្វីផ្សេង ៗ ដើម្បីពិនិត្យសង្កេតនារីគ្រប់លក្ខណ៍ ប៉ុន្តែអ្នកពុំដែលបានជួបម្ដងនោះ ៗ មាននារីខ្លះរូបឥតគួរសម ពាស់អាងដំណើរទីងការបង់ប៉ោយ មាននារីខ្លះទៀតដំណើរគួរសម ពាសធ្មេញប្រឡោះខ្មោច ពាស់មុខអុត មានខ្លះទៀតរូបក៏សម ដំណើរក៏សម ធ្មេញក៏ល្អដូចផ្កាម្លុះក្រពុំ ញញឹមក៏ស្រស់គួរដោះទេវតា ពាស់ចរិយាមិនម៉ត់-ចត់ បានតែខាងតែងខ្លួនដើរកុំផាន ចំណែកមុខការរបស់ខ្លួនគឺកិច្ចការក្នុងផ្ទះបណ្ដែតបណ្ដោយទុកឲ្យតែកូនឈ្នួល ហើយបើខ្លួនខានមិន

ឆ្ងាញ់ អាងតែទៅរកម្ហូបចំណីអាហារឯផ្សារបន្ថែម ។

អ្នកស្វះស្វែងយើងគ្រវីតែក្បាល ហើយពិចារណាថា «អញមិនដឹងនឹងទៅរកនៅទីណាទេ នូវស្រីគ្រប់លក្ខណ៍នោះ ។ អញដើរមកនេះ អស់រយៈពេលច្រើនឆ្នាំ បានឆ្លងកាត់ស្រុកដែនក៏ច្រើន ហើយអាយុកាន់តែច្រើនផង បើបណ្តោយទុកឲ្យចាស់ខ្លួនទៅ ហើយប្រសិនបើបានជួបនារីគ្រប់លក្ខណ៍ត្រឹមត្រូវតាមក្បួនមែន គេគង់នឹងព្រមទទួលយកខ្លួនធ្វើជាប្តីទេ ។

លុះគំនិតនេះផុះឡើង សិរីវិឡាទ៍មានសេចក្តីព្រួយបារម្ភយ៉ាងខ្លាំង ។ ឥឡូវអ្នកមានអាយុជិត ៤០ ឆ្នាំហើយ ។

ថ្ងៃមួយអ្នកចូលទៅសំណាក់នៅវត្តលោកសង្ឃ ។ ទទួលយប់នោះមានភ្លៀងធ្លាក់យ៉ាងច្រើន ។ លោកគ្រូចៅអធិការមានព្រះហឫទ័យសប្បុរស បានប្រគេនកន្ទេលមួយស្អាតជាប់តែឯងដល់អ្នកកំសត់យើង ។ វេលាដែលព្រះភិក្ខុសង្ឃសឹងស្ងាត់ ហើយព្រះពិរុណអន្ទរលា នៅមានតែគ្រាប់តូចៗធ្លាក់មក ដំណក់ភ្លៀងដែលស្រក់ពីសំយាបមកដីបណ្តាលឲ្យមានសូរជាចង្វាក់តក់ . . . តក់ . . . តក់ មកប៉ះនឹងសោតប្រសាទចៅកំសត់អនាថា ។ ដោយយកសូរដំណក់ទឹកភ្លៀងជាអារម្មណ៍ ចៅកំសត់ស្រាប់តែរលឹកស្រុកកំណើត រលឹកដល់ម្តាយមេម៉ាយដែលអ្នកបានលះបង់ចោលមកជាយូរឆ្នាំ ពុំដឹងជាលោកមានសេចក្តីសុខទុក្ខយ៉ាងណាៗ

អ្នកទឹកដល់សំដីទៅធនជាសំឡាញ់ ដែលបានហាមឃាត់មិនឲ្យរៀនវិជ្ជានេះ ៗ ទើបមានគំនិតថ្មីមួយកើតឡើងថា «ស្រីគ្រប់លក្ខណ៍មានឬគ្មានបើមានក៏មិនដឹងនៅឯណា ៗ ម្យ៉ាងទៀតរឿងគ្រប់លក្ខណ៍ និងមិនគ្រប់លក្ខណ៍នោះ ស្រេចនៅលើការអប់រំរបស់គ្រូសារទឹងវង្គាភិបាលទេតើ ៗ ក្បួនដែលអញបានរៀននេះជាក្បួនកុហក អញគប្បីវិលត្រឡប់ទៅស្រុកកំណើត ហើយបន្តការងារជាប្រវេណីរបស់មាតាវិញ ទើបល្អ ទើបសមជាកូនមានសេចក្តីកតញ្ញូ" ។

ប៉ុន្តែក្នុងខណៈនោះ ស្រាប់តែបំណងដើមដែលចូលមកដក់ពាសក្បាលនេះ : បើមានក្បួនហើយ ស្រីគ្រប់លក្ខណ៍ទៀងតែមាន ៗ ពាក្យបុរាណមានចែងទុកមកថា "មិនដែលមានក្អែង គ្មានផ្សែងទេ" ៗ ត្រូវតែញាំងបំណងខ្លួនដែលបានដៅទុកនោះឲ្យសម្រេច ទើបពេញជាអង្គប្រុស ឯការសុខទុក្ខជាធម្មតារបស់មនុស្សលោក មិនគួរក្រឡេកមើលតាមកម្លាំងខ្យល់នេះឡើយ ៗ

ព្រឹកឡើង សិរិវឌ្ឍនក្រាបថ្វាយបង្គំលាលោកគ្រូមេវត្ត ហើយធ្វើដំណើរចេញទៅទៀត ដោយដោតចិត្តទៅលើស្រីគ្រប់លក្ខណ៍យ៉ាងមាំ ឥតកម្រើកដូចសត្វប្រឡាំងកាសឈ្មោល ពីងផ្អែកពីសនាលើប្រឡាំងកាសញីដូច្នោះ ៗ អ្នកគោចរបន្តដំណើរផ្សងព្រេងទៅទៀត ចូលព្រៃលេចពីលផុតពីលចូលព្រៃ កាត់ស្រុកតូចធំនិគមជនបទ ហើយតាំងចិត្ត

ឬជាអាយុជីវិត លើស្រីគ្រប់លក្ខណ៍ គឺថាបើមិនបានជួបទេ ស្លាប់ក្តី រស់ក្តី អ្នកនៅតែនឹកដល់នាងអស់ ។

ចាប់តាំងពីសិរីវឌ្ឍន៍ចេញចាកស្រុកកំណើតមកដល់ថ្ងៃនេះ មានចំនួនជិត២ឆ្នាំហើយ ។ អ្នកដើរទៅវង្វេងចូលព្រៃ ដោយនឹកស្មានថា មិនដែលនឹងមានភូមិគេនៅខាងមុខ ។ ប៉ុន្តែពុំដូច្នោះ អ្នកដើរចូលទៅក្នុងព្រៃញាតស្បាតសោះ ទីងថយក្រោយក៏ឆ្ងាយ ម្ល៉ោះហើយបុរសកំសត់តោងតែរុលទៅមុខ ។ ស្បៀងអាហារគ្មាន ។ អ្នកអាស្រ័យតែផ្លែឈើជួនពេល ។ មុននឹងបេះមកទទួលទាន អ្នកឃ្លាំមើល បើសត្វស៊ីផ្លែណា ទើបអ្នកហ៊ានស៊ីផ្លែនោះ ។ ខោអាវរហែកដាចអស់ ដោយគោះនឹងបន្លា ។ សិរីវឌ្ឍន៍អស់សង្ឃឹមព្រោះអ្នកឃើញតែសេចក្តីស្លាប់នៅប្រចាំតែពីមុខ ។ អ្នកដើរគេច គ្រាន់តួនអំពីសត្វសាហាវ មានដំរីខ្លាចចកជាដើម ។ យូរៗ អ្នកឮខ្លាស្រែក ដំរីកោះខ្ទុរ ដែលធ្វើឲ្យអ្នកព្រឺកសាច់សពាង្គកាយស្ទើរស្លុតបាត់ស្មារតី ។ ជួនកាល ពោះថ្លាន់ធំសម្បើមលៀនអណ្តាតក្រហម ៗ វារកាត់មុខអ្នក ជួនកាលអ្នកដើរជាន់លើទ្រាដំរី ហើយអ្នកភ្ញាក់ភ័យ ស្ទុះស្រែកភ្ញាក់ភ្ញាត់ តែម្នាក់ឯងកណ្តាលអដ្វា ឥតមានជនណាម្នាក់ជួយញញឹម ឬជួយព្រួយអ្នកឡើយ ។ ជួនកាលអ្នកត្រាច់ត្បាល ៗ ទៅ ស្រាប់តែក្បាលអ្នកមានស្នូកតែសរសៃសពីងពាងព័ទ្ធជុំវិញ អ្នកត្រូវតែឈប់អង្គុយដើម្បីបេះសរសៃចាំងដ្រៈ

នេះពេលចេញដោយសើម ។ ព្រោះអ្នកធ្លាប់ឮតស់ ។ ពោលថា ស្ទើរសែ ពីងពាងប៉ះភ្នែកៗទីងខ្លាក់ ។ ម្យ៉ាងហើយអ្នកព្រួយណាស់ ហោតែ ខ្លាក់ភ្នែក មិនដឹងបើងឹងទៅទីពីងជនណាឡើយ ។ ពេលកត្រីអ្នក ឡើងដេកលើប្រគាបឈើ ខ្លាចក្រែងសត្វសាហាវយាយី ។ កណ្តាល យប់ស្ងាត់ឈឹង សំឡេងគួកទីងបលក់ខ្លោចដែលទម្លុះរហស្រោពជា ទីសម្លុសម្រាកនៃសត្វទាមា ធ្វើឲ្យអ្នកព្រឺក្បាលប៉ុនកញ្ចៃ ។ សរីវត្ត្រទ គ្រាប់តែក្ដុងព្រៃអស់យេះពេលកន្ទះវៃ ។

ព្រលឹមថ្ងៃទី ១៦ អ្នកចុះពីដើមឈើ ហើយដើរទៅមុខបន្តិច ស្រាប់តែឮសូរស្ទើរស្រិបៗ ដូចខ្យល់បក់នៅពីខាងមុខ ។ ប៉ុន្តែស្លឹក ឈើឥតកម្រើក ។ ក្រឡេកមើលតាមចន្លោះដើមឈើទៅមុខ អ្នក ឃើញផ្លូវស្ទើរស៊ាំងផុត ។ គឺជាស្ទឹងមួយដែលហូរមកពីជ្រោះភ្នំ ហើយ ហូរកាត់កណ្តាលព្រៃហាត់ព្រៃហោងនេះ ។ បុរសអនាថាឈរនៅមាត់ ស្ទឹងក្រឡេកមើលទៅត្រើយម្ខាង ក្រឡេកមើលបណ្តោយតាមដងស្ទឹង ដោយសេចក្តីទុក្ខព្រួយ ។ អ្នកជញ្ជឹងគិតថា បើនឹងឆ្លងទៅត្រើយនាយ តើបានអ្វីធ្វើ ស្បៃនឹងហែលខ្លាចក្រែងមានក្រពើ ។ នៅទីនោះមិន មានអ្វីជាសញ្ញាថា មានមនុស្សមកដល់ឡើយ ។ អ្នកឃើញតែស្នាមជើង សត្វព្រៃដែលដើរចុះមករកទឹកផឹក ។

បុរសអនាថាសំឡឹងទៅខាងណោះម្តង ទៅខាងណេះម្តង ជារបៀប

មនុស្សពាល់គំនិត ៗ បន្តិចមក អ្នកឃើញអ្វីស្លុង ៗ អណ្តែតចុះមកពីចម្ងាយ ៗ អ្នកសំឡឹងមិនដាក់ភ្នែក ដោយសង្ស័យថាប្រហែលជាទូករបស់អ្នកស្រុកណាអុំមក ហើយខ្លួនមុខជានឹងអាចសុំជិះដោយសារផងបាន ៗ ប៉ុន្តែលុះមកជិតល្មមសំគាល់បានថាជាអ្វី គឺគល់ឈើសោះ ជាគល់ឈើឆាប់យ៉ាងធំបង្គ្រោង ៗ កាលបើបានយល់ច្បាស់ជាគល់ឈើហើយ សិរីវឌ្ឍន៍ស្ទុះទៅចាប់វល្លិ៍នៅជិតនោះបានមួយទង ៗ ជាកុសល គល់ឈើនោះអណ្តែតក្បែរត្រើយដែលអ្នកឈរនៅ ៗ លុះគល់អណ្តែតមកដល់ទន្ទឹម អ្នកក៏គ្រវែងវល្លិ៍ដូចគេបង់សំណាញ់ ដោយកាន់ចុងទាំងសងខាង ហើយទាក់ទាញអូសសន្សឹមៗចូលមកខាងបាន ៗ អ្នកគិតថា ទៅឯនាយខាងក្រោមស្ទឹង មុខជានឹងមានភូមិមនុស្សជាមិនខាន ៗ រួចអ្នកឡើងទំលើគល់ បណ្តែតខ្លួនតាមយថាកម្ម ដោយពឹងផ្អែកទៅលើជំនួយនៃទេព្តា ៗ

ចំណែកព្រះអរុណរះឡើងយ៉ាងច្បាស់ ចាំងរស្មីមកលើរុក្ខលតាវល្លិ៍ទាំងឡាយ ជាប្រផ្នូលនៃថ្ងៃប្រកបដោយសុភមង្គល ៗ គេឮសូរមាន់ព្រៃរងាវស្រួយស្រែសទទួលព្រះអាទិត្យ ដែលទើបត្រាច់ចរចាកចេញពីយប់សន្ធិយា ហើយដែលធ្វើឲ្យសត្វភាគច្រើនព្រមទាំងមនុស្សនានាប្រាសចាកសេចក្តីព្រួយបារម្ភ អំពីការស្ថិតនៅក្នុងរាត្រីកាលនោះ ៗ

(មានត)

# បន្លាមុត យកបន្លាដោះ

លោក ប៊ូ-ប៊ី រៀបរៀង

---

វិស័យមនុស្សពាល បើពុំមានអ្នកណា សង្កត់សង្កិនផ្ចាញ់ផ្ចាលទេ ក៏រឹតតែបានចិត្តព្រហើនកោងកាចឈ្លានពាន ខ្លាំងឡើងលើសដើម ដោយសំគាល់ថា គេខ្លាចខ្លួន ដូចគោធ្លាប់គៀចម្ដងបានហើយ ក៏ឡើងចាំងចេះតែគៀចញយ ៗ តទៅទៀត ។ ប៉ុន្តែ បើមានអ្នកណាគេដឹងពុតពាន់ គេធ្វើអំពើយង់ឃ្នងផ្ចាញ់ផ្ចាល់តបវិញក្លាម ៗ ។ មនុស្សពាលក៏នឹងកងចាលអស់ពុតត្បុតខ្វះមិនខាន ។ ដូចមានរឿងដំណាល ក្នុងកូដវាណិជជាតកទុកនិបាតថា ៖

មានឈ្មួញពីនាក់ ម្នាក់នៅក្រុង ម្នាក់នៅស្រុកស្រែ ជាសម្លាញ់នឹងគ្នាយ៉ាងជិតស្និទ្ធ រកស៊ីលក់ដូរចូលគ្នាជានិច្ច ទាល់តែជឿចិត្តគ្នាទៅវិញទៅមកឥតសង្ស័យ ។ ថ្ងៃមួយ ឈ្មួញនៅស្រុកក្រៅយកផាលប្រាំរយទៅផ្ញើទុកនឹងឈ្មួញនៅក្នុងក្រុង ។ ឯឈ្មួញអ្នកក្រុងទទួលយកផាលទៅទុកនៅកន្លែងមួយ ហើយចេះតែលក់ដាច់អស់ផាលទៅ ទើបគិតថាសម្លាញ់អញ ជឿទុកចិត្តអញយូរណាស់មកហើយ អញនិយាយអ្វីៗក៏ចេះតែជឿអញដែរ ឥឡូវនេះ ត្រូវអញធ្វើឧបាយកលយកប្រាក់ថ្លៃផាលរបស់សម្លាញ់ឲ្យអស់ទាំងប្រាំរយផាល, ទើបប្រើមនុស្សឲ្យរកកើបអាចម៍កណ្ដុរ

ពីទីនេះទីនោះឲ្យបានច្រើន យកមកចាក់គរជាគំនរធំនៅត្រង់កន្លែងដែលខ្លួនដាក់ផាលនោះ ធ្វើហាក់ដូចជាកណ្ដុរស៊ីផាលអស់ ដោយគំនិតគិតទុកថា បើសម្លាញ់អញមកទារប្រាក់ថ្លៃផាល អញនឹងប្រាប់ថា បានប្រាក់ពីណា បើកណ្ដុរវាស៊ីផាលអស់ទៅហើយ ឥតបានលក់ផាលមួយសោះ ។

កន្លងមកមិនយូរប៉ុន្មានថ្ងៃ ឈ្មួញស្រុកក្រៅមកទារគេប្រាក់ថ្លៃផាលពីឈ្មួញអ្នកក្រុង ។ ឈ្មួញអ្នកក្រុងធ្វើឫកពើហាក់ដូចជាអាណិតសម្លាញ់ខ្លាំងណាស់ និយាយប្រាប់ថា ឱសម្លាញ់! ខ្ញុំមិនចង់នឹកនាទេ តែនឹកពីរឿងផាលទៀត អាណិតសម្លាញ់ណាស់ស្ទើរស្រក់ទឹកភ្នែក ដ្បិតកណ្ដុរវាស៊ីផាលចាំងប្រាំរយអស់រលីង ឥតសល់ផាលមួយសោះ សូម្បីតែលក់ដាច់ផាលមួយក៏គ្មានដែរ ខ្ញុំឲ្យគេរៀបទុកដាក់ផាលនៅកន្លែងមួយជិតជិតល្អណាស់ លុះកន្លងមកមិនយូរប៉ុន្មាន ខ្ញុំឲ្យមនុស្សទៅជញ្ជូនយកផាលមកលក់ ស្រាប់តែបាត់ផាលអស់ គ្មានឃើញមួយសោះ ត្រឡប់ជាឃើញសុទ្ធតែអាចម៍កណ្ដុរទៅវិញ ប្រាកដជាកណ្ដុរវាស៊ីផាលអស់ ហើយវាជុះអាចម៍ទុកគរនៅកន្លែងនោះ បើសម្លាញ់មិនជឿខ្ញុំ ចូរសម្លាញ់ទៅមើលឲ្យឃើញនឹងភ្នែកខ្លួនចុះ រឿងនេះហួសវិស័យខ្ញុំនឹងថែរក្សាការពារបាន ហើយសូមសម្លាញ់កុំគិតស្មានថាជាការអ្វីឡើយ ។ ឈ្មួញជនបទចូលទៅមើលកន្លែងដាក់ផាល ឃើញសុទ្ធតែអាចម៍កណ្ដុរមែន ទើបនៅស្ងៀមស្ងាត់មិនថាអ្វីមួយម៉ាត់សោះ ប៉ុន្តែ នឹកក្នុងចិត្តថា ផាលជាដែក ជារបស់រឹង

ណាស់ ៖ មិនមែនជាអាហារចំណីរបស់កណ្ដុរទេ ហេតុអ្វីក៏សម្លាញ់អញនិយាយថាកណ្ដុរស៊ីផាលអស់ ៖ ធ្ញកណ្ដុរអាចកកេរដែកជាចំដែរឬ ? ម្យ៉ាងទៀត ក្អិនឬសេរបស់ដែក គឺមិនគួរនាំឲ្យកណ្ដុរកាត់ឬស៊ីបានទេ បើដូច្នេះ ច្បាស់ជាសម្លាញ់នេះមិនស្មោះត្រង់នឹងអញទេ មុខជាគិតគោងបោកប្រាស់យកប្រាក់អញជាប្រាកដ ណ្ហើយចុះ ចាំអញគិតធ្វើឧបាយកលផ្ដួញផ្ដាល់នឹងឧបាយកលវិញ ព្រោះវិស័យពាលបើមិនធ្វើឲ្យដឹងខ្លួនខ្លះទេ មុខជាពេះតែបានចិត្ត បេះតែឡើងតាង ហ៊ានកុហកបញ្ឆោតបោកប្រាស់អញញយ ៗ តទៅទៀត ហើយព្រះហើនមើលងាយអ្នកដទៃថាគេមិនដឹងដល់គំនិតខ្ជូរវៀចវេររបស់ខ្លួន ពេលនេះ គួរតែអញទូន្មានសម្លាញ់អញដោយអាជ្ញាដ៏ធ្ងន់ ទើបបានស្មើសមគ្នា ។

ឈ្មួញជនបទស្រុកក្រៅ លុះគិតឃើញយ៉ាងនេះហើយ ថ្ងៃមួយទៅលួចនាំយកកូនប្រុសតូចរបស់ឈ្មួញអ្នកក្រុងទៅផ្ទួតទឹកឯកំពង់ ហើយនាំកូននោះទៅផ្ញើលាក់បំពួនទុក នឹងញាតិសន្ដានទៅភូមិមួយឆ្ងាយមិនឲ្យអ្នកណាដឹងឮ ហើយផ្ដាំថា កុំឲ្យកូនតូចនេះចេញមកក្រៅបន្ទប់ឲ្យសោះរហូតដល់ខ្ញុំត្រឡប់មកយកកូននេះទៅវិញ ។ អ្នកផ្ទះក៏ទទួលមើលថែរក្សាកូននោះតាមបណ្ដាំគ្រប់ប្រការ ។ ឯឈ្មួញអ្នកស្រុកក្រៅផ្ញើកូនរួចហើយត្រឡប់ទៅឯផ្ទះឈ្មួញអ្នកក្រុងវិញ ។ ចំណែកឈ្មួញអ្នកក្រុងបាត់កូន ខំដើរកេសព្វច្រកល្ហកពុំឃើញ ដ្បិតកាលសម្លាញ់លួចនាំយកកូនទៅនោះ

ខ្ញុំពុំបានដឹង លុះស៊ើបសួរដំណឹងទៅ ឮគេប្រាប់ថា សម្ទាញ់នាំកូនទៅ ដ្ឋតទឹកតាំងពីព្រឹកព្រហាម លុះពេលជិតព្រលប់ទើបឃើញសម្ទាញ់នោះ មកដល់ផ្ទះ ក៏ស្រែកសួរពីចម្ងាយថា នែសម្ទាញ់ អ្នកនាំកូនខ្ញុំទៅដ្ឋតទឹក មែនឬទេ ?

ឆ្លើយ- ខ្ញុំនាំកូនអ្នកទៅដ្ឋតទឹកមែន ។

សួរ - នាំទៅដ្ឋតទឹកកន្លែងណា ?

ឆ្លើយ- នាំទៅត្រង់កំពង់អ្នកនេះឯង ។

សួរ - ចុះម៉េចក៏បាត់យូរដល់ម៉្លេះ ?

ឆ្លើយ- ព្រោះកើតហេតុដែលគួរឲ្យតក់ស្លុត បើប្រាប់គេទៅ គ្មានអ្នកណាជឿទេ ។

សួរ - កើតហេតុដូចម្ដេចខ្លះ ?

ឆ្លើយ- កើតហេតុខ្លែងឆាបកូនកេង ។

ឈ្មោញអ្នកក្រុង គ្រាន់តែឮដូច្នោះ ក៏ទឹកដល់កូនខ្លួនក្លាម ទើប សួរយ៉ាងប្រញាប់ថា កូនខ្ញុំទៅឯណា ?

ឆ្លើយ- កូនសម្ទាញ់សត្វខ្លែងឆាបយកទៅបាត់ហើយ, ខ្ញុំចុះ ទៅដ្ឋតទឹក ឲ្យវានៅចាំលើមាត់ច្រាំង ស្រាប់តែសត្វខ្លែងហើរចុះពីអាកាស មកឆាបយកកូនសម្ទាញ់បាត់ទៅ ខ្ញុំដេញវាមិនទាន់សោះ ជាការហួស វិស័យរបស់ខ្ញុំ ។ ដេញតាមវារហូតដល់តែអស់កម្លាំងក៏មិនរួច ទើបវិលមកវិញ

ព្រោះជាប់ជញ្ជាំងតាមសត្វខ្លែង បានជាខ្ញុំបាត់យូរតាំងពីព្រលឹម ដល់ព្រលប់យ៉ាងនេះ ។

ឈ្មួញអ្នកក្រុងទឹកអាឡោះអាល័យស្តាយកូន ក៏ខ្ញាល់យំសោកស្រក់ទឹកភ្នែកសស្រាក់ហើយនិយាយថា សត្វខ្លែងនោះខ្លួនវាតូចទេ ម៉េចក៏វាឆាបយកកូនខ្ញុំដែលខ្លួនធំជាងវាទៅរួច ពាក្យអ្នកឯងនោះមិនគួរឲ្យជឿទេ (ដែលគេថាយ៉ាងនេះ ព្រោះគេក្លួចរឿងកណ្តុរស៊ីផាលដែក) ។

ឈ្មួញស្រុកក្រៅឆ្លើយថា សត្វខ្លែងវាតូចក៏មែនហើយ ប៉ុន្តែវាឆាបយកកូនទៅបាន ទើបជារឿងគួរឲ្យឆ្ងល់ គួរឲ្យអស្ចារ្យណាស់ អ្នកទាំងពីរប្រកែកដដែកឈ្លោះគ្នាជាខ្លាំង ឈ្មួញអ្នកក្រុងប្រកែកមិនព្រមជឿថាសត្វខ្លែងឆាបយកកូនខ្លួនសោះ សូម្បីស្តាប់ឮទាំងអស់ ក៏គ្មានអ្នកណាម្នាក់ជឿដែរ ។ ឯឈ្មួញស្រុកក្រៅ បើទុកជាគេមិនជឿពាក្យខ្លួនសោះ ក៏នៅតែនិយាយពាក្យដដែលថា សត្វខ្លែងឆាបកូនក្មេងយកទៅបាត់ មិនកែប្រែប្រួលឡើយ ។ ទើបឈ្មួញអ្នកស្រុកក្រុងនាំយករឿងនេះទៅប្តឹងទៅក្រមសាលាៈតាខប្រកាន់ថា ឈ្មួញស្រុកក្រៅសម្លាប់កូនរបស់ខ្លួនដោយអាងថា សត្វខ្លែងឆាបយកទៅ ។

កាលតុលាការសួរដេញដោលថា អ្នកបាននាំកូនក្មេងទៅងូតទឹកឯកំពង់ពិតមែនឬទេ ?

ឆ្លើយ– បាទ! ខ្ញុំបាទបាននាំក្មេងនោះទៅងូតទឹកមែន ។

សួរ – សត្វខ្លែងឆាបយកកេ្ងនោះទៅមែនឬ ?

ឆ្លើយ– បាទ! មែនពិតហើយ ។

តុលាការសួរផ្ទួនៗដល់ ៣ ដងថា សត្វខ្លែងឆាបយកក្មេងនោះទៅមែនឬ ? ឆ្លើយថា មែនទាំង ៣ ដង ។ តុលាការមិនជឿពាក្យថា សត្វខ្លែងឆាបក្មេងនោះសោះ បេះតែជម្រឹតសួរហើយសួរទៀតគំហកកំហែងយ៉ាងណា ចម្លើយនៅតែឆ្លើយប្រកាន់ពាក្យដដែលឥតរើរុះ ។

តុលាការនឹងវិនិច្ឆ័យថា ចម្លើយ សម្ដាប់កូនក្មេង ឬលួចពង្រត់កូនក្មេងក៏មិនបាន ព្រោះពុំមានសាក្សីជាសំអាងថា ចម្លើយបានធ្វើយ៉ាងនោះមែន, ឬនឹងវិនិច្ឆ័យតាមពាក្យរបស់ចោទក៏ថា ក្មេងនោះសត្វខ្លែងឆាបយកទៅក៏មិនបាន ព្រោះមិនមានអ្នកណាដឹងឃើញផង ទើបតុលាការលួងលោមឈ្មួញស្រុកក្រៅថា សូមប្រាប់តាមការពិតទៅចុះរឿងនេះតើដូចម្ដេច ?

ឈ្មួញស្រុកក្រៅគិតថា ពេលនេះ គួរអញបញ្ចេញសេចក្ដីពិតហើយ ទើបចាប់ផ្ដើមសួរតុលាការថា លោកធ្លាប់ឃើញកណ្ដុរស៊ីផាលដែកដែរឬទេ ?

តុលាការឆ្លើយថា យើងមិនធ្លាប់ឃើញទេ លុះឆ្លើយយ៉ាងនេះហើយ លោកតែងនឹកឃើញភ្លាមថា ប្រហែលជាចោទក៏នឹងចម្លើយមានរឿងទាស់ទែងគ្នាពីមុនមកហើយ ទើបសួរថា រឿងកណ្ដុរស៊ីផាលនោះមាន

ហេតុដូចម្តេចខ្លះ ចូរជំណាលឲ្យយើងស្តាប់ផង ។

ឈ្មួញស្រុកក្រៅជំណាលរឿងដើមប្រាប់តុលាការថា យើងខ្ញុំទាំងពីរនាក់ជាសម្លាញ់នឹងគ្នា ជឿទុកចិត្តគ្នាជាយូរយារណាស់មកហើយ ខ្ញុំបានយកផាលដែកប្រាំរយទៅផ្ញើនឹងសម្លាញ់ទុកលក់ឲ្យផង លុះខ្ញុំមកទារប្រាក់ថ្លៃផាល សម្លាញ់អ្នកចោទក៏ប្រាប់ខ្ញុំថា ផាលអ្នកឯងកណ្តុរស៊ីអស់ទៅហើយ អ្នកចូរទៅមើលអាចម៍កណ្តុរចុះ ខាងក្រោយមក ខ្ញុំនាំកូនរបស់សម្លាញ់ទៅងូតទឹក ក៏កើតសត្វខ្លែងមកឆាបយកកូនក្មេងនោះទៅ បើកណ្តុរស៊ីផាលបាន សត្វខ្លែងក៏ឆាបយកក្មេងទៅបានដូចគ្នា បើកណ្តុរស៊ីផាលមិនបានទេ សត្វខ្លែងក៏ឆាបយកក្មេងទៅមិនបានដូចគ្នាដែរ ។

ទើបតុលាការសួរចោទក៏ថា កណ្តុរស៊ីផាលមែនឬទេ ?

ឆ្លើយ– រឿងនេះមិនមែនទេ ព្រោះខ្ញុំបញ្ឆោតយកប្រាក់ថ្លៃផាលរបស់គេ បានជាប្រាប់កុហកថា កណ្តុរស៊ីផាលអស់ទៅហើយ ។

សួរ– អាចម៍កណ្តុរមានច្រើននៅកន្លែងនោះមែនឬទេ ?

ឆ្លើយ– មែន ព្រោះខ្ញុំប្រើមនុស្សឲ្យដឹកជញ្ជូនអាចម៍កណ្តុរយកពីទីដទៃមកដាក់នៅទីនោះ ។

សួរ– អ្នកព្រមបង្វិលប្រាក់ថ្លៃផាលឲ្យដល់ចម្លើយវិញឬទេ ?

ឆ្លើយ– ខ្ញុំព្រមបង្វិលប្រាក់ថ្លៃផាលឲ្យចម្លើយទាំងអស់ ។

តុលាការនិយាយនឹងចម្លើយថា ឥឡូវនេះ ចោទក៏គេព្រមឲ្យ

ប្រាក់ថ្លៃផាលមកអ្នកវិញហើយ  រឿងកូនរបស់ចោទក៏ដែលអ្នកនាំយកទៅងូតទឹកនោះ សត្វខ្លែងឆាបយកទៅមែនឬទេ ។

ឆ្លើយ– មិនមែនទេ ។

សួរ– អ្នកយកក្មេងនោះទៅទុកឯណា ?

ឆ្លើយ– ខ្ញុំយកទៅផ្ញើទុកនឹងញាតិនៅភូមិឯណោះ ។

សួរ– អ្នកព្រមទៅយកកូននោះមកប្រគល់ឲ្យចោទក៏វិញឬទេ ?

ឆ្លើយ– បើចោទក៏ព្រមបង្វិលប្រាក់ថ្លៃផាលឲ្យខ្ញុំៗ ក៏នឹងព្រមបង្វិលក្មេងឲ្យដល់ចោទក៏វិញដែរ ។

តុលាការវិនិច្ឆ័យឲ្យឈ្មួញអ្នកក្រុងប្រគល់ប្រាក់ថ្លៃផាល ឲ្យទៅឈ្មួញស្រុកក្រៅ ហើយវិនិច្ឆ័យឲ្យឈ្មួញស្រុកក្រៅប្រគល់កូនឲ្យឈ្មួញអ្នកក្រុងវិញ ។ ចាប់ដើមអំពីនោះមក ឈ្មួញទាំងពីរនាក់ក៏សុខចិត្តសះជានឹងគ្នា លែងចោទប្រកាន់គ្នាទៅវិញទៅមក ប៉ុន្តែ លែងទុកចិត្តគ្នាតទៅមុខទៀតៗ

រឿងនេះ បានគតិជា ២ យ៉ាងគឺ:

១– ឈ្មួញអ្នកក្រុង ត្រូវមហាជនតិះដៀលថាជាមនុស្សអាក្រក់ ទុច្ចរិតទ្រុស្តមិត្ត មិនគួរអ្នកផងចូលសមាគមសេពគប់រកឡើយ ។

២– ឈ្មួញស្រុកក្រៅ ត្រូវមហាជនលើកដំកើងសរសើរថាជាមនុស្សល្អសុចរិត មានឧបាយល្អិតសុខុមគិតធ្វើកិច្ចកលផ្ចាញ់ផ្ចាល់កិច្ចកលបំបាត់សេចក្តីទុច្ចរិតរបស់ឈ្មួញអ្នកក្រុងបាន ដូចសុភាសិតបុរាណថា ៖

បន្លាមុត យកបន្លាដោះ ។

# ទៅលេងស្ពានស្លួគិប្លួនជប់ប្វៃ

លោក ញូង-សៀង រៀបរៀង

កាលពីយូរឆ្នាំបន្តិចហើយ មានសេចក្ដីដំណាលថា មានគ្រូព្រះកម្មដ្ឋានម្នាក់នៅក្នុងតំបន់មួយ ល្បីល្បាញថាជាអ្នកចេះដឹងធម៌វិបស្សនាកម្មដ្ឋានជ្រៅជ្រះល្អិតល្អន់ណាស់ ។ យាយ-តាចាស់ៗ ទាំងជិត ទាំងឆ្ងាយ ផ្ញើលក្ខណ៍ឈ្មោះទៅរៀនសមណធម៌(១)ពីលោកគ្រូនោះជាច្រើនគ្នាណាស់ ស្ទើរតែកកកុញនៅសំណាក់អាស្រ័យមិនបាន ។ លោកគ្រូព្រះកម្មដ្ឋាន បានទទួលលាភសក្ការៈ ច្រើនពោរពាសប្រើប្រាស់ចាយវាយយ៉ាងធូរស្រួល ។ ឯអ្នកដែលបានរៀនរួចហើយត្រឡប់មកផ្ទះវិញ មិនដឹងជាបានរៀនដល់ថ្នាក់ណា ហើយបានស្រូបធម៌ព្រះកម្មដ្ឋាននោះដូចម្ដេចទេ, តែចេះតែអួតសរសើរតៗគ្នាថា បណ្ដាគ្រូព្រះកម្មដ្ឋានទាំងអស់មានតែលោកគ្រូមួយនោះទេដែលពេញជាគ្រូ "ធម្មិកធំ" ពិតប្រាកដ ។

ថ្ងៃមួយ មានយាយម្នាក់ឈ្មោះយាយខែន នៅភូមិឆ្ងាយបន្តិចពីតំបន់នោះ គាត់បានឮគេអួតសរសើរលោកគ្រូនោះខ្លាំងណាស់អត់ទ្រាំមិនបាន ក៏ផ្ញើលទៅនឹងគេដែរ ។ កូនចៅរបស់គាត់ បានរៀបចំប្រដាប់ប្រដាជូនដំណើរគាត់ទៅតាមបំណង ។ មិនយូរថ្ងៃប៉ុន្មានយាយខែនក៏បានវិលត្រឡប់មកផ្ទះវិញ ។ គាត់មានចុកពាតយ៉ាប់ថវៃប

១– សព្វថ្ងៃគេហៅក្លាយថា សំណាក់ធម៌ ។

ស្រុកស្រែតំរៀមមជាន់ពីមុន ទាំងពីតាហាននិយាយឡើងកាលណា គឺប្លែកពីធម្មតាហើយគាត់ច្រើនតែនិយាយខ្សឹបតិចៗ ហឹមៗផង ជាហេតុនាំឲ្យកូនចៅរបស់គាត់ ព្រមទាំងអ្នកជិតខាងភូមិផងរបងជាមួយខ្លះ សំគាល់ទុកដាក់ថា គាត់បានលុះធម៌សមាធិ យ៉ាងជ្រៅជ្រះម៉ត់ចត់ពិតប្រាកដមែនទែន ។ កាលបើមានអ្នកជិតខាងដែលធ្លាប់ស្និទ្ធស្នាល ទៅនិយាយលេងកំសាន្តជាមួយនឹងគាត់ ដោយពាក្យមិនគួរសមផ្តេសផ្តាស គាត់តបភ្លាមថា "ខ្ញុំឥឡូវនេះមិនដូចពីដើមទេ" ហើយបើមានគេសាកសួរគាត់អំពីរបៀបធម៌កម្មដ្ឋានយ៉ាងណាៗនោះ គាត់តបថា រឿងនេះលោកគ្រូបានហាមដាច់ខាត ប្រាប់មិនបានទេ ព្រោះជា "ធម៌ក្ង" អ្នកណាបានទៅរៀនផ្ទាល់ខ្លួន អ្នកនោះទើបបានដឹងចំពោះខ្លួនតែម្នាក់ឯង ។ កាលបើគេចេះតែដដឹកសួរដេញដោលខ្លាំងទៅទៀត គាត់គ្រាន់តែប្រាប់យ៉ាងខ្លីថា គាត់បានធ្វើឋានសម្រាប់ខ្លួនគាត់ទុកជាស្រេចហើយ ។ ពួកអ្នកស្រុក អ្នកភូមិនោះ លុះបានឮដូច្នោះហើយ ក៏បែកយោបល់គ្នាជាពីរ អ្នកខ្លះថា យាយទែនដូចជាមិនសូវស្រួលបែបបែកធ្មង់, អ្នកខ្លះថា កុំនិយាយលេងវ៉ុយ គាត់បានលុះ "ធម៌ក្ង" របស់គាត់ពិតប្រាកដមែនហើយ ។

ចំណែកយាយទែន គាត់តែងអង្គុយការនាស៊ឹងស្ងាច់នៅមុខគ្រែព្រះធម៌ ក្នុងផ្ទះគាត់រៀងរាល់យប់ជាធម្មតា ។ គិតត្តិចមក, យាយទែន

តែងរៀបទៀត ពណ៌នាអួតសរសើរហើយ ៗ តែពីរឿងស្ថានតាវតិង្ស ស្ថានតុសិតថា សប្បាយអស្ចារ្យណាស់ ព្រោះព្រលឹងគាត់បានទៅដល់ រឿងកល់យប់ក្នុងពេលដែលគាត់បានចូលកាន់សមណធម៌នោះៗ យូរៗទៅ យាយវែន ចង់ហោះទៅស្ថានសួគ៌ទាំងរូបស្រស់ ព្រោះគាត់គិតថា បានទៅដល់តែព្រលឹងដូចជាមិនអស់ចិត្តសោះ, ទើបថ្ងៃមួយ គាត់ចូលកាន់សមណធម៌ទាំងថ្ងៃត្រង់ ក្នុងបន្ទប់ផ្ទះគាត់មួយស្របក់ធំ ស្រាប់តែគាត់ក្រោកពីមុខគ្រែព្រះធម៌ ហើយស្ទុះឡើងឈរបំទិតជើងលើមាត់បង្អួចត្រង់ក្បាលដំណេក, ក្បាលគាត់ងើយបន្តិច, ភ្នែកគាត់សំឡឹងទៅលើអាកាស ហើយគាត់ស្រែកយ៉ាងខ្លាំងៗ ថា « លាសិនហើយ កូនចៅអើយ ! អញទៅលេងស្ថានសួគ៌បួនដប់ថ្ងៃ កុំឲ្យរន្ធន់មើលផ្ទះអញ » ។ កូនចៅទាំងក្នុងផ្ទះក៏ផ្អើលនោះឡោឡូឆោ ខ្លះស្ទុះស្ទាទៅរកចាប់ឃាត់គាត់ តែចូលទៅក្នុងបន្ទប់គាត់មិនរួច ព្រោះគាត់ខ្ទាស់ទ្វារក្តាពីក្នុងជាប់ ខ្លះជាឲ្យរកជណ្តើរដាក់តាមបង្អួចពីក្រៅ ដើម្បីឡើងទៅចាប់ឃាត់គាត់ឲ្យចុះពីមាត់បង្អួចទៅវិញ ខ្លះទៀតថាណ្ហើយមិនអីទេ គាត់គ្មានទៅហ៊ានលោតហោះទៅណាទាំងរស់ដូចេះទេ ។ ឯអ្នកជិតខាងទាំងចាស់ ទាំងក្មេងក៏ផ្អើលឈូឆរត់ប្រញាប់ខ្ញាត់ខ្វែងទាំងថ្ងៃត្រង់ ស្រែកហៅគ្នាថា មករ៉ុយទៅមើលយាយវែនហោះទៅលេងស្ថានសួគ៌ ។ កាលបានទៅដល់ អ្នកខ្លះថាគាត់លេងមែនទែន ឬក៏លេងៗទេ អ្នកខ្លះតបមកវិញថា

ឮគេហៅឈ្មោះគាត់ថា «ខែនៗ» ក៏អាចដឹងបានហើយ គឺថាមុខជាគាត់ លើនមែនខែនហើយ, អ្នកខ្លះទៀតយាត់ថា កុំកាលខាតតជ្រុសផ្តាស ចាំមើលគាត់សិន ៗ អ្នកទាំងអស់គ្នា ក៏ខំប្រឹងសង្កេតពាល់ភ្នែកសំឡឹង ជាទិចអំពីរយៈមាតបង្អួច ទៅលើមេឃ ដោយប្រយ័ត្នប្រយែងក្រែងគាត់ ហោះលឿនពេកមើលមិនទាន់ ៗ ឯកូនចៅរបស់គាត់ រឹតជ្រួលច្របល់ ដផែកផែកខ្វែងគំនិតគ្នាមិនដាច់ស្រេចតែពីរៀងតាត់ៈសោះ មួយថាដូច្នេះ មួយថាដូច្នោះ ៗ ពេលនោះ យាយខែន លើកដៃទាំងពីរប្រណម្យសំពះ តម្រង់ត្រឹមប្រជុំចិញ្ចើម រួចហើយកក់ទំលាក់ដៃម្ខាងខ្វាកសំយាកស្ពឹម បង្កើនស្លូត ដៃម្ខាងទៀតលាតល ហុចហក់ក្ដក់ញ៉ៀទៅមុខពត់ម្រាម ងស្លូត ហើយកន្ទ្រញ់អន្ទ្រញ់ញញើងម្នង រាងរាំបដូចកូនយក្សរេចបរៀន ហោះ ភ្នែកគាត់ឆ្មេចប៉ើក ៗ មួយស្របក់ ស្រាប់តែលេចធ្លោពីមាត់ បង្អួច ក្បាលជាំចុះត្រូវចុះទំនេរដីរង ក្បាលដំណែក ៗ អ្នកឈរមើល ខ្លះភ្ញាក់ព្រើតស្រែកថា ឯងខំប្រឹងសំឡឹងមើលទៅលើមេឃស្ទើរមិនហ៊ាន បប្រិចភ្នែក ព្រោះឮថាគាត់ហោះទៅស្ថានសួគ៌ ឥឡូវគាត់ត្រឡប់ជា ល្មោតចុះមកស្ថាននរកវិញឆ្កួយ ! ៗ ឯពួកកូនចៅគាត់ក៏ជ្រួលច្របល់ ស្ទុះស្ទាក់យំគ្រហេបគ្រហប ញាំទទ្រាត់ទទ្រើតស្រែកភ្ញាក់មាត់ភ្ញាត់ ភ្ញៃ ប៉ះនោសគ្នាលន់ ហើយនាំគ្នាស្ទុះទៅលើកបីត្រកងសែងគាត់ឡើង

យកទៅលើផ្ទះ ៗ អ្នកឈរមើលទាំងនោះ ក៏បានជួយឈឺឆ្អាលទាំង
អស់គ្នា ៗ ប៉ុន្តែជីវិតអាយុសង្ខារយាយវែន បានថយចេញចាក
រូបកាយរបស់គាត់ តាំងពីក្នុងពេលដែលគាត់ប៉ះដល់ដីភ្លាមៈម៉្លេះ មាន
ផ្ទៃអ៊ីទីងរស់ បើក្បាលគាត់សំយុងដាំចុះមកមុន ដូចនេះបុកបម្រុក
សម្រុញសន្ធុញកគាត់ផ្លុបទៅនឹងដីផ្ទះបោះទៅហើយ ៗ ពេលនោះកូន
ចៅទាំងក្រុមគ្រួសារគាត់ យំសោកបោកខ្លួនក្រាលកន្ទក់កន្ទេញស្តាយ
ស្រណោះអាឡោះអាល័យម្តាយកំបត់ មិនគួរប៉ិព្រាត់ទាំងស្រស់ ៗ
ដូច្នេះសោះ ៗ កាបបានដឹងជាក់ថា យាយវែនអស់អាយុសង្ខារផ្ទះបោះ
ហើយ, ពួកក្មេង ៗ ខ្លះនិយាយគ្នាថា យាយវែនគាត់បានលាកូនចៅ
ទៅនេះស្ថានសួគ៌តែខ្លួនចប់ថ្ងៃទេ, ឥឡូវនេះ គាត់បែរជាទៅហូត
លែងត្រឡប់វិញតែម្តង ៗ ចំណែកចាស់ ៗ មានទឹកមុខស្លុតស្លូបក្រៀម
ក្រំគ្រប់ ៗ គ្នា ដោយមិនស្មានថាមានគ្រោះថ្នាក់ដល់ស្លាប់ផ្ទះបោះសោះ ៗ

បន្ទាប់មក ពួកកូនចៅទាំងក្រុមគ្រួសារព្រមទាំងញាតិមិត្រទាំងអស់
ក៏បានបញ្ចប់រឿងយាយវែន ដោយរៀបចំធ្វើបុណ្យបូជាសពគាត់តាម
ប្រពៃណីធម្មតាទៅហោង ៗ

# រឿងមរណមាតា

(តមក)

លោក ប៊ី-សុវណ្ណ ចម្លងពីសាស្ត្រាស្លឹករឹត

---

ប្រទះហ្វូងសត្វម្រឹគ ដើរគគឹកក្នុងអដ្វា ខ្លះដេញខ្លះជល់គ្នា សឹងសត្វ
សុទ្ធពាលយង់ឃ្នង ៗ ដំរីរោមាបខ្លា ជាសដេញគ្នាៈពទ័រពង ខ្លះ
ថយកំរំងគន្ធង ជល់ចាលចាញ់ដេញចូលព្រៃ ៗ កុដុម្ពកកុលកេសី
ឃើញដំរីកាំងកិតភ័យ ខំដើរប្រាំពីរថ្ងៃ ដល់ចុងស្រុកខែត្រស្មោះស្មានៗ
ជាស្រុកជនបទ ដោយនឿយហត់ឈប់សម្រាន្ត លុះព្រឹកឡើងទើប
បាន ចូលក្នុងស្រុកក្នុងភូមិនោះ ៗ ខេត្តនោះធំទូលាយ សុខសប្បាយ
ភូមិច្រើនច្រុះ បញ្ញើយកតែប្រុស រាប់ដល់សែនរូបជាតធំ ៗ មនុស្ស
ក្នុងខេត្តនោះក្តី ខាងរកស៊ីមិនស្ទូវខំ ខាងមន្តខាងអាគម នោះសង្វាត
ឃ្លាតខ្លីខ្លាន់ ៗ ខនេ្ទញវេញរត់មាត់ ញាប់ញ័រក្តាត់មើលមិនទាន់
វៀនត្រូវវៀបវង្វាន់ ផ្ទះមួយល្វែងដាក់មិនអស់ ៗ រវៀចខាងសេសបាប
ចេះជរាបមិនចន្ទោះ លួចប្លន់យករបស់ កាប់សម្លាប់ឥតញញើត ៗ
ស្រុកក្រៅទៅដូរទិញ លក់ទំនិញមិនស្ទូវកើត ដល់ទាវក្រអើត អាង
តែកាប់ចាក់ចេញចុះ ៗ មិនចេះធ្វើការងារ មិនឧស្សាហ៍រកស៊ីសោះ នាំ
គ្នាស្រើបស្រួលស្រុស ធ្វើជាចោរលួចទ្រព្យា ៗ មានមេស្រុកជាធំ

ចុះចូលជុំខ្លាចចេស្តា នឹងរិះគិតយ៉ាងណា ស្តាប់បង្គាប់មេស្រុកនោះ ។
បើដល់ពេលវេលា វានាំគ្នាមកចំពោះ ឃ្នាំពាចមនុស្សម្នាងចុះ ផ្តាច់
ជីវិតធ្វើពលិការ ។ បូជាអារក្សព្រៃ សូមជោគជ័យសូមចេស្តា ចេញ
ធ្វើចោរកាលណា ឲ្យមានលាភបានទ្រព្យធន ។ កាលនោះឯកុដុម្ពិក
កុលកេសីប្តីប្រពន្ធ នាំគ្នាចូលដំបន់ ខេត្តកាបីស្រុកចោរនៅ ។
កាលចោរនាំគ្នាចាំ គន់គយឃ្លាំនៅដើមផ្លូវ កុដុម្ពិកដើរចូលទៅ
ចោរចាប់ជាប់ចងម៉ឺម្នា ។ ឯនាងកុលកេសី ឃើញស្វាមីត្រូវទោសា
នាងគិតភ័យតក្កមា ទំលេះតែចូលទៅ ។ យកចិញ្ចៀនមួយនោះ ត្បូង
ក្តិប្រុះមាសឆ្អិនឆ្អៅ ទៅជូនមេស្រុកនៅ ពោលអង្វរសូមទោសប្តី ។
មេស្រុកមិនមានចិត្ត ទឹកករុណាកុលកេសី ទើបស្រែកឃាត់ស្រដី
ប្រាប់ទៅចោរទាំងនោះថា ។ អស់គ្នាយើងកុំចាប់ កុំសម្លាប់ចោរមេណា
ដ្បិតម្ចាស់នេះត្រូវជា ញាតិសាច់យើងទៅលែងទៅ ។ ចោរព្រួចៅ
ហាយប្រាប់ ស្រែកប្រញាប់ថាញាតិជៅ ឲ្យលែងប្តីនាងទៅ ទើប
ស្រាយលែងចេញម៉ឺម្នា ។ រីឯចៅកុដុម្ពិក រួចពីក្តីមកវិន្ទា នឹកគុណ
មេស្រុកជា ស្រាយលែងទោសពុំពិឃាដ ។ ទើបនាងកុលកេសី
នាងវន្ទីក្រាបក្រោមបាទ មេស្រុកសុំអនុញ្ញាត សូមផ្ញើខ្លួនលើមេស្រុក ។
ថាយើងទាំងទ្វេហា សូមលោកជាធម្មជនក ទោះធ្គង់ទោះសុខទុក្ខ ផ្ញើ
ជីវិតលើលោកម្ចាស់ ។ មេស្រុកស្តាប់ហើយថា អ្នកៈទ្វេហាអណាស់

ដ្បិតផុតកំហាស់ ឥតកូនចៅតពង្ស ៗ ឲ្យសូមអ្នកទាំងទ្វេ ជាបុត្រស្នេហ៍ ផ្ញើផ្ទា ក្រែងផុតស្លាប់កាលណា អ្នកលើកខ្មោចស្រោចឆ្អឹងផង ៗ ទោះពាក្យពេចន៍ផ្តាំផ្ញើ ទោះសៅហ្មងទោះខុសត្រូវ ឲ្យអ្នកអត់ទោសផង ផង ទុកស្នើជូនទេត្រា ៗ មេស្រុកហាហៅទៅ ករិយានៅក្នុងគ្រហា ឲ្យរៀបភោជនា យកមកឲ្យកូនបរិភោគ ។ ករិយារៀបរួចបាន ជាសូមទានដំកបលោក ឲ្យចូលមកបរិភោគ ខ្ញុំចង់ស្គាល់មុខកូនផង ៗ កុដុម្ពិកនៅករិយា បណ្តីរគ្នាចូលត្រសង ដល់លុតជង្គង់ផង ៗ ផ្គុំអញ្ជលីលើកហត្ថា ៗ សំពះសួរទាំងទ្វី ទាំងកុដុម្ពិកទូរករិយា សងសួរសង បរោ ហាក់ដូចជាបុត្រខុទ ។ ហើយបរិភោគភោជន ឆ្អល់ឆ្អែតឆ្អន់ហើយចេញចរ មេស្រុកសោកសាទរ រៀបលំនៅទីទំព្រា ៗ ហើយយកខ្ញុំប្រុសស្រី ប្រើប្រក្រតីជាបរិវារ ឲ្យស្រដ័ល្អជា គោក្របីសេះកុះករ ៗ ទាំងនេះព្រោះគេសី ជាតិជាស្រីមានលក្ខណ៍ល្អ ប្រាជ្ញាទ្រព្យមិនក្រ មិនខ្វះបាយពាំថ្ងៃនោះ ៗ

បនកាកគតិ

កុដុម្ពិកនោះណា នូវនាងករិយា សុខសាន្តស្នានស្នោះ ស្នានស្នើហ្វទ័យ ឥតភ័យឥតអោះ ដោយមេស្រុកនោះ អាសូរស្រុកឡាញ់ ៗ នាងកុលកេសី ប្រើខ្ញុំប្រុសស្រី ឲ្យបរឲ្យរចេញ ឲ្យដួរដួញប្រែ ធ្វើស្រែបំណេញ មាសប្រាក់បានពេញ បានពោរពាំងផ្ទះ

ហើយនាងឡើងទៅ បិតាឯមិនៅ លើកដៃសំពះ ថាសូមកូមិទ ទឹងនៅ
ធ្វើផ្ទះ ឲ្យធ្លាយស្រឡះ ស្រឡាញ់កូមិថ្មី ។ ឯធម្មបិតា ស្ដាប់ហើយ
ឆ្លើយថា អើកូនពីសី តាមតែចិត្តចង់ ចំណង់កូនស្រី នាងស្រឡាញ់ដី
ត្រង់ណាយកចុះ ។ នាងកុលកេសី បានស្ដាប់ពាក្យបិ- តាធម៌ដូច្នោះ
ប្រាយប្រាប់ដាក់ច្បាស់ សំពះលាចុះ ទៅមើលកូមិនោះ ទឹងបង់ផ្ទះថ្មី ។
ឯកូមិនោះជា បើអ្នកឯណា ជាខ្ញុំគេក្ដី នៅកូមិនោះណា បានជាសេដ្ឋី
នាងកុលកេសី នាងស្គាល់ដៀងជាក់ ។ ហេតុនាងស្រីថ្លៃ បាន
សាងច្រើនក្រៃ ជាស្រីមានល័ក្ខណ៍ ទឹងបានជាធំ ឧត្តមអនគ្ឃ
អនេកជាអគ្គ ជាឯកនារី ។ ហើយនាងក្រឡាប់ វិលវិញមកក្រាប់
ស្វាមីទៅ កុដុម្ពិកបានស្ដាប់ សាស័ព្ទពាក្យពី នាងប្រាប់ពីទី ពីកូមិ
ថ្មីនោះ ។ អរេកភ័នុបមា ហើយឆ្លើយទៅថា នាងអើយបើច្នោះ
នាងរៀបភោជនា ភោក្តាវចចុះ ទឹងប្រើខ្ញុំប្រុស ឲ្យទៅប្រាប់ជី ។
បាយទឹកភោជនា ចំណីភិសា នោះត្រូវខ្ញុំស្រី រៀបឲ្យក្មៀវធី ធ្វើ
ការលើកដី ឯខ្លួននាងស្រី ជាមេតំនិក ។ ស្រេចហើយកុដុម្ពិក គាត់
តែងធ្វើទី រួចឆាប់ដូចចិត្ត សង់ផ្ទះធំល្អ សឹងថ្មីទឹងឥដ្ឋ បាយអលាប
ក្បិត ជញ្ជាំងជុំវិញ ។ ផ្ទះក្លោះត្រដឹង ហោណាំងទទឹង គ្រែតាំង
រៀបពេញ ល្អល្អះត្រកាល កនហាលជុំវិញ ផើងផ្កាថ្កល់ពេញ ដោយ
ក្បាលសសរ ។ មានផើងដើមផ្កា ខាងត្បូងគ្រឹហា រៀបឥដ្ឋបាយអ

មានដើមផ្កាគ្រប់ ឈើសព្វមិនក្រេ មិនដឹងបើយក៍ បើកប់មិនអស់ ៗ ហើយតែងទឹកស្រះ ថ្កាំងក្រពះ កណ្ដាលផ្ទះការ រៀបថ្មជាភ្នំ ធាត់ធំខ្ពង់ខ្ពស់ ហើយឡើងដាំអស់ ឈើបរិកោក្ដា ៗ គូលែនសីរមាន ខ្នុរទៀបចេកចាន់ បង្កៅពុទ្រា ធូរេនដូងល្មុត មង្ឃុតសេដា ហើយឡើងដាំផ្កា កំពូលភ្នំនោះ ៗ សង់រោងមួយស្រាប់ ទុកជាសម្រាប់ ទៅលេងស្រះនោះ គ្រាន់តែអផ្សុក ជាទុក្ខបាត់សោះ រីឯស្រះនោះ ឯជើងគ្រឹហា ៗ ដាំឈូកសម្រាល ផ្ការីករន្ទាល ពេញក្នុងគង្គា កុមុទុត្បល ផុសផុលសឹងផ្កា មន្ធាមន្ធា ហែបហែលទៅមក ៗ ត្រីច្រើនប្រការ ពាសពេញត្រៀបត្រា សំកាំងសំកក បណ្ដើរកូនមីរ ទៅស៊ីឬសចក ខ្ទះហែលពួនជ្រក ពួនជ្រប់រេក ៗ ឯកើតឡើងរៀប សង់រោងទងរៀប ជំនុំកិច្ចការទទួលភ្ញៀវមក គេយកភស្តុការ មកជូនកាលណា ឲ្យទៅរោងនោះ ៗ ឯលិចផ្ទះធំ ប្រុសស្រីទៀវជុំ។ ផ្ទះបាយចំពោះ របងបីជាន់ ខេត្តខណ្ឌធំស្មោះ ឯទ្វារបួននោះ មានខ្ញុំចាំទ្វារ ៗ រៀបរួចអស់ក្ដី នាងកុលកេសីឡើងទៅក្រាបលា នូវបិតាធម៌ និងធម៌មាតា ជាកូនក្រាបលា ទៅនៅផ្ទះថ្មី ៗ បិតាមាតា ធម៌មានមេត្តា នាងកុលកេសី ហៅគ្នាមកជុំ នូវខ្ញុំប្រុសស្រី ហែកុលកេសី ទៅឡើងគ្រឹហា ៗ នាងនៅផ្ទះថ្មី ពាសាពាសីរត់ចូលមហិមា. ត្បូងកែវប្រាក់មាស ពេញពាសច្រើនជា អនេកគណនារាប់សែនរាប់កោដិ ៗ

អ្នកស្រុកជិតឆ្ងាយ ពួកបោរទាំងឡាយ លែងលួចសោះសោត ខ្ចុបខ្ចាបចុកណា នានមានចំណោទ សឹងខ្ចាបសឹងគោត សឹងចុះចូលជុំ ៗ ឯមនុស្សក្រីក្រ បបួលគ្នាមក សូមៈនាំជាខ្ញុំ ជាម៉ឺនជាពាន់ តាមជាន់ កុះកុំ កុះករជួបជុំ ជួបជិតប្រឡាញ់ ៗ នៅយូរបានប្រាក់ ហូល ព្រៃស្បៀកភាក់ លោះខ្ញុំទៀតវិញ បួនប្រាំដប គៀវគរពោរពេញ រកស៊ីចំណេញ ជំនួញច្រើនពេក ៗ ខ្ញុំខ្លះមិនបេះ គិតជួញរទេះ ដឹក ស្បៃដឹកស្បែក ក្រមួនបន្ទុះ ខ្លះលោះភ្លុនរែក រកតាមចំណែក ចំ-ណេញពលខ្លួន ៗ ខ្លះបេះគ្រាន់បើ លេខហារសារពើ គិតជួញក្រ មួន ក្រវាញយក្ខុក ដោយមុខដោយខ្លួន ខ្លះបេះត្រគួន រែកលក់ ដោយផ្សារ ៗ ខ្លះល្ងទំផុត គិតកាប់ទសផុត លក់បានទិញស្រា ផឹកអស់ប្រាក់កាស ក្រឡូះម្នីម្នា វិលទៅគ្រឹហា ប្រពន្ធជេរម្តាយ ៗ ខ្លះបេះយ៉ាងឯក លែងស្តាយលែងរែក ជួញប្រែស្រុកឆ្ងាយ បាន មាសបានប្រាក់ ទុកដាក់មិនចាយ ហើយនាំខ្វល់ខ្វាយ យកជូននាង ម្ចាស់ ៗ ចូលខ្ញុំកំដរ ច្រើនច្រុះកុះករ ពាលពលច្រើនណាស់ គោ សេះដំរី ក្របីពេញពាស ត្បូងកែវកងក្រាស ឥតឯមានខ្វះ ។ មាស ប្រាក់ច្រើនលន់ អនេកច្រើនពាន់ អនន្តមហិមា ទាំងអស់នោះមិញ គិតកាញ់គណនា ពច់យ៉ាំងត្រូវជា យ៉ាំងបួនកោដិគត់ ៗ ឯខ្ញុំដែល ប្រើ ធ្វើការសារពើ មិនមេះការត់ នាងឲ្យខោអាវ ឈ្នួតខ្ទូវសំពត់ បើ

ខឹងនាងអត់ មិនរាយមិនដេរ ៗ ម្ល៉ោះវែងស្រឡាញ់ ស្មានស្មោះអស់
អញ សរសើរគ្នាន់គ្នេរ ជាអ្នកម្ចាស់ស្រី ប្រណីយើងដែរ ខឹងលោក
មិនដេរ មិនចេះយកខុស ៗ ឯធម៌បិតា យល់បុត្រស្នេហា ទ្រព្យច្រើន
ដូច្នោះ ពោរពេញកាដិយ៉ាំង ទើបតាំងឲ្យឈ្មោះ យកហេតុកោដិ
នោះ មកតាំងនាមា ៗ ឈ្មោះកុលកោដី កុដុម្ពីកសេដ្ឋី ពីថ្ងៃ
នោះណា នាងកុលកេសី ស្រីមានលក្ខណា ពិសិដ្ឋជា នាងតែង
ប្រណិបត្ន៍ ៗ បិតាមាតា ធម៌មានមេត្តា អាសូរនាងក្តាត់ នាង
បានចំណី ភ័ស្តុនាងកាត់ នាងតែងចែកចាត់ ជាភាគបីណា ៗ
មួយភាគនាងទុក នាងជូនរំលែក ទៅធម៌បិតា មួយជូនម្តាយធម៌
រាល់ ៗ វេលា ភាគមួយជូនស្វា – មិនមានប្រតិព័ន្ធ ៗ នាងមានចិន្តា
អស់អញខុសស្រុកហ៍ គោរពប្រណិបត្ន៍ បិតាមាតា ភាតារៀមវ័ន្ត
អស់ទ្រព្យសម្បត្តិ ហូរចូលសព្វថ្ងៃ ៗ មានមួយរាត្រី នាងកុលកេសី
កើតអស្ចារ្យក្រៃ រន្ធត់ក្នុងពោះ ញ័ររស់សរសៃ មានគភ៌បុត្រថ្លៃ
ប្រកបលក្ខណា ៗ ហេតុទេពច្យុត ចុះចាប់ជាបុត្រ កេសីធីតា លង់
លុះចូលចប់ ជាដប់មាសា កើតហេតុអស្ចារ្យ ម្តងទៀតគួរស្ញែង ៗ
ព្រឹកអស់ពេមា ញ័ររស់អង្គា អង្គកាយក្រៃញង ហាក់ដូចអណ្តែត
ក្រសែតអង្គឯង ស្រាលខ្លួនពោងពេង កំរើកចិន្តា ៗ ទើបនាងសម្តព
បុត្ររូបគ្រប់ ពីក្នុងកាយា លួលួះពីសី ប្រែប្រួយក្រ្តា ដូចជួនចន្ទ្រា

សម្បុរល្អល្អន់ ៗ ឯកុលគេសី កុដុម្ពិកសេដ្ឋី ត្រេកអរពេកពន់ ថ្នមបុត្រពុំឆ្ងា ស្នេហាឥតអន់ សេដ្ឋីគិតគន់ បង្គាប់បរិវារ ៗ ឲ្យរើស មេនំ គីលៀងចោមជុំ បីថ្នមព្យាបាល បំរើជ្រួចជ្រៀង ពលរៀង ដោយឆារ ខ្វះធ្វើអាហារ បញ្ចុកបុត្រថ្ងៃ ៗ ផ្តសឹងទឹកអប់ គ្រឿង ទេសឈ្ងុយឈ្ងប់ ជាអបិទ្រៃយ ខ្វះកាន់វិដ្ឋទី សោភីរាត់រៃ បក់ បោយសព្វថ្ងៃ មិនមានហ្មងសៅ ៗ មិនឲ្យរបោម មូសសុចរុយពេម ជាត់ជាយចេញទៅ ពុំឲ្យមានមោះ ឥតលោះឥតក្តៅ បីប្រថ្នមនៅ មិនមានដងធ្នូន់ ៗ រីឯមេស្រុក ជាធមិជនក ស្រឡាញ់ពេកពន់ នាងធមិអយ្យិកា ស្នេហាឥតអន់ លុះយូរដល់ជន្ម ជាតិបាស់ផក ៗ មេ ស្រុកទូរនាង ករិយារំលាង រំលត់ជន្មា កុដុម្ពិកសេដ្ឋី គេសីធីតា លើកសពសង្ការ រួចស្រេចអស់ក្តី ៗ ពីថ្ងៃនោះទៅ អស់ស្រុកក្នុងក្រៅ គោរពខ្លាចសេដ្ឋី កុដុម្ពិកជាធំ ជំនុំការស៊ូ ដម្កល់សេដ្ឋី ជាទីប្រធាន ៗ

## បទព្រហ្មគីតិ

រីកុដុម្ពិកសេដ្ឋី ស្រង់ទីកាសិកស្ថាន សម្រេចពងការបាន ជាស្តេច ត្រាញ់ក្នុងបុរី ៗ ឯករិយានិមល នាងនាងកុលគេសីស្រី ត្រកូលផ្សៃ ជាតិ មានទរលក្ខណ៍លើសលោកា ៗ នាងគិតនាងសន្មត ឲ្យនាម បុត្រីកញ្ញា ហេតុដោយនាងស្នេហា ឲ្យឈ្មោះនាងកុមារី ៗ លុះ ចំរើនធំឡើង ល្អថ្កុំថ្កើងស្រស់ប្រិមប្រិយ ហេតុនាងសាងបារមី ជា

ជននីពោធិសត្វ ៗ ប្រកបនូវនៃលក្ខណ៍ លើសអន័គ្យណាស់ត្រូវខ្នាត
មិនក្លាយកាយនារយាទ ដូចស្រីស្រុកស្រែចំការ ៗ សម្បុរសស្រស់
ស្រិល ដូចពពិលមាសរចនា ព្រះគណ្ឋដូចផលា ផ្ទៃមាតប្រាំងមាស
សោភ័ណ ៗ កន្ត្រាសមសុរាង មូលម៉ដ្ឋម៉ង់ដូចវង់ចន្ទ ភ្នែមាដូចកៅ.
ទ័ណ្ឌ សមនេត្រាយង់ខ្មៅស្រិល ៗ ទន្តាទិព្វទាំងសែ - សិបដូចគេ
ឆ្នៃមហានិល ជិតជិតប្រកិតស្រិល ផ្ចិតខុស្លាសមប្រិមប្រិយ ៗ កា
មាតាំងគូគាប់ ដូចស្រទាប់ឈូកឬណិមី នាសាសមពិសី ស្រង់ស្រួល
ស្រៀបដំខុត្តម ៗ អង្គាគាំងស្រឡះ ឥតអង្កៀសអង្គាសម ចង្កេះ
មូលរៀវកុំ សមល្អស្មើតធើតពេកពិត ៗ គន់ពីព្រះបាទា ដរាបនាដល់
សិរសិដ្ឋ ល្អគ្រប់អាំងបញ្ចពិធ កល្យាណីនិទ្ទិ ៗ ព្រោះនាងសាង
កុងទី ជ:ជននីអង្គគត ហើយនាងបានយកផ្កា ថ្វាយបច្ចេកសម្មា-
ធី ៗ ផលនោះជួយទ្រទ្រង់ ឲ្យល្អអង្គកាយនារី មានចិត្តទិព្វទើបជា
អស្ចារ្យពេកចំឡែកក្រៃ ៗ បពិត្រអើយកាលនោះ ហេតុកម្មគ្រោះកុមារី
បានធ្វើពីអតី-តាតែងតាមពិតពុំឃ្លាត ៗ លុះជន្មបានប្រាំពីរ ឆោម
ស្រស់ស្រិលរូបល្អកាត់ មានស្រីមួយដូជាតិ ជាមេម៉ាយឈ្មោះកាលីៗ
មានកូនស្រីពីរនោះ មួយនាមឈ្មោះចន្ទទី កូនមួយទៀតនោះនៃ
ឈ្មោះចន្ទចិត្តថូស្សា ៗ រីឯមេកាលី មានបងស្រីមួយនាមា ឈ្មោះ
កាលីនិយា រួមខុទរមួយស្មោះស្មាន ៗ កាលីថ្លៃលែងលង់ ពោល

ពោះបន់ពុំកប់អាន សព្វថ្ងៃកាលីមាន ចិត្តទោមនស្សកើតទុក្ខា ៗ

ត្បិតខ្លួនជាមេម៉ាយ ពុំសប្បាយក្នុងចិន្តា ក្រៀមក្រំៗទក រំជញ្ជួង

តែក្នុងចិត្ត ៗ ជាខ្លួនអញមេម៉ាយ ជាចំណាយពាក្យគេពិត នឹកឡើង

ធ្អើនផ្អែតចិត្ត ធ្អិតផ្អែតផ្អល់សល់សែនសោះ ៗ កាលនៅទៀបទី ផ្ទះ

កុដុម្ពិកសេដ្ឋីនោះ កាលីធ្វើជាស្នោះ ដើរទៅមកកេកុដុម្ពិក ៗ បើ

បានសរពើអ្វី ផលចំណីមិនហ៊ានស៊ី យកទៅជូនកុដុម្ពិក តែសព្វថ្ងៃ

មិនដែលខាន ៗ ហេតុស្រីចិត្តបូស្បា ឥតលក្ខណានៅក្នុងប្រាណ

គន់គិតចង់តែបាន យកកុដុម្ពិកជាស្វាមី ៗ ទើបកេមន្តសលសិទ្ធិ

បញ្ចុលចិត្តមហាសេដ្ឋី រកបានទើបកាលី រៀបស្អិតស្អាងអង្គអាត្មា ៗ

លាបព្រៃងលាបក្រមួន ម្សៅប៉ៃតខ្លួនដាត់កក្រោ យកស្នួតសិតកេសា បួង

សំពោងហាក់ក្រមុំ ៗ ស្លៀកពាក់សេវគប្ធ ដណ្តប់ក្តីសឹងជាហ៊ុំ ចិញ្ចៀន

មានត្បូងជុំ ពាក់បញ្ចៀដើរលេងផ្កា ៗ លុះដល់ផ្ទះសេដ្ឋី ហើយកាលី

ឈរកេក គិតធ្វើកលមាយា លួងសេដ្ឋីឲ្យចូលចិត្ត ៗ និយាយឡុក

លលេង ហាក់ដូចក្មេងពាលពេញពិត ដោយសាមេកស្នេហ៍សិទ្ធ ត្រូវ

កុដុម្ពិកទប់ពុំបាន ៗ ស្ពាលស្និទ្ធនឹងកាលី រែងមេត្រីសេរួមប្រាណ

រួមចិត្តស្និទ្ធរួមឋាន សាន្តសោមនស្សពេលរាត្រី ៗ រួមរស់រួមសពាគ្គ

ភ្លេចនឹកនាងកុលកេសី ភ្លេចបុត្រស្ងួនប្រិមប្រិយ ភ្លេចដំណេកទីនិទ្រា

កាលីបានកុដុម្ពិក រួមវេណីជាភរិយា មិនគិតកេរ្តិ៍និន្ទា ដោយវង្វេង

ចិត្តអន្ទពាល ។ ឯនាងកុលកេសី យល់ស្វាមីស្និទ្ធស្នេហ៍ស្មាល ចាប់
ចិត្តជួបគ្រាអាល ទឹងកាលីស្រីឥតលក្ខណ៍ ។ នាងគិតពុំខឹងខាន់ ពុំ
ប្រច័ណ្ឌក្រេងបែកបាក់ នាងធ្វើជាស្មោះស្ម័គ្រ ស្និទ្ធស្នេហាឥតសៅម៉ងៗ
ពេះកាយរែងពប់អាន ស្ម័គ្រស្មោះស្មានស្មើបូនបង កុដុម្ពិកឃើញទំនង
កុលកេសីពុំក្រោធ ទើបប្រើខ្ញុំឲ្យហៅ កាលីទៅលើគ្រឹហា ហើយរៀប
ទីនិទ្រា ឲ្យកាលីនៅសុខសាន្ត ។ ទុកជាភរិយាចុង រៀបបំរុងឲ្យធន-
ធាន ឲ្យខ្ញុំស្រីប្រុសប្រាណ គ្រាន់កាលីប្រើធ្វើការ ។ រទេះសេះដំរី
ឲ្យកាលីតាមចិន្តា កាលចេញទៅណា ខ្ញុំខៀវខ្មៅហែដិតជុំ ។ ហេតុ
កម្មកុលកេសី បានធ្វើពីបុព្វេពិត កម្មនោះតាមដោយជិត ពានថ្មីៗ
បៀតអាត្មា ។ រីឯភរិយាថ្មី ឈ្មោះកាលីចិត្តមិច្ឆា- ទិដ្ឋិចិត្តហ៊ឹង្ក្រ
បៀតបៀននាងភរិយាមុន ។ កុដុម្ពិកជាស្វាមី បានកាលីស្រឡាញ់
លន់ រំជួលចិត្តគិតគន់ គិតស្អប់នាងកុលកេសី ។ ពុំស្និទ្ធពុំស្នេហា
ពុំចរចាពុំរបតី ស្គាលស្នេហ៍តែកាលី ជាភរិយាចុងបណ្តាច់ ។ តាំង
ពីបានកាលី កាឡកណ្ណីជាគូគាប់ ស្នេហ៍ស្និទ្ធកើតអកត្យ កើតចង្រៃ
ក្នងអគ្គា ។ កើតហិនហោចខ្ចប់ខ្ចាយ កើតអន្តរាយអស់ទ្រព្យ ដំរី
សេះគោ គោក្របីសីងស្លាប់ស្លុត ។ ពាសាទូវពាសី ស្លាប់ទៃខ្ទះ
រស់រត់ ធនធានបូនកោដិគត់ បាត់រលោះអស់ធនហោង ។

(មានត)

# រឿងសាមកុក

## កណ្ឌទី ៣៧

ឧកញ៉ាវិបុលរាជសេនា នូ-កន ប្រែរៀបរៀង

(តមក)

> រឿងសាមកុកទុកជាយុទ្ធសាស្ត្រ
> អ្នកវាងវៃឆ្លាស បើបានអាន
> នឹងបេះឧបាយកលបំណាន
> ទាំងមានសន្តានស្នេហាជាតិ ។

ចុនស៊ុនដោយរហ័ស ក៏ជ្រុលខ្លួនរបូតធ្លាក់ចុះ ទើបដកយកក្រប៊ីកាប់បន្ទ្រះត្រូវចុនស៊ុនចំក្បាលរបូតចុះទៅ ដូចគេពុះ ដាច់ភាគកណ្ដាលខ្លួនជា ២ ចំណែកធ្លាក់ស្លាប់ ១ រំពេច រួចជូឡុងក៏បរសេះ គេចស្រូតរត់ទៅដល់ស្ពានទៀនប៉ាន់កៀវ ទទួលឮសំឡេងទាហានប៊ូទ្វីស្រែកហៅមកពីក្រោយ កំឡាំងសេះនឹងកំឡាំងជូឡុងក៏ទន់ចុះ ទទួលក្រឡេកឃើញទៀវហ៊ុយឈរលើស្ពានក៏ស្រែកថា គ្រានេះ ខ្ញុំអស់កំឡាំងណាស់ហើយ ឲ្យអ្នកជួយខ្ញុំផង ៗ ទៀវហ៊ុយក៏ស្រែកថា អ្នកស្រូតចូលស្ពានទៅចុះ ខ្ញុំនឹងទទួលតស៊ូ ៗ ឯជូឡុងក៏ស្រូតចូលស្ពានទៅបង្ហាយផ្ទះ

ប្រហែល ២០០ ស៊ិន (៨ គ.ម.) ជួបនឹងឡៀវពីឈរនៅទីនោះ ជូឡុងចុះពីលើសេះទៅគំនាប់ឡៀវពីហើយអង្គុយយំ អធិប្បាយសេចក្ដីឲ្យឡៀវពីស្ដាប់គ្រប់ប្រការ ហើយថា ខ្ញុំបាទយកបានតែអាតៅ ជាបុត្រលោករុំដាក់នៅក្នុងគ្រោះ កាលខ្ញុំបាទទំលាយចេញមកពីក្នុងចំណោមទ័ពនោះ បានប្រយុទ្ធគ្នានឹងទាហានចូច ស្រាប់តែបានឮសំឡេងអាតៅស្រែកយំម្ដង ៗ ឥឡូវបាត់បូឡាយឹងជាយូរហើយ មិនបានឮសំឡេងយំ សោះនឹងជាអន្តរាយយ៉ាងណាក៏មិនដឹងឡើយ ។

ជូឡុងក៏ដោះគ្រោះចេញ ស្រាយយកសំពត់ដែលរុំអាតៅនៅក្នុងខ្លួនចេញមកលាចេញ ឃើញអាតៅនៅដេកលក់ ក៏សែនទឹកអរពន់ប្រមាណ ហើយក៏និយាយទៅទៀតថា បុណ្យពីបុរាណរបស់លោកខ្លាំងណាស់ បានជាបុត្រលោកមិនមានប៉ះលើសេចក្ដីអន្តរាយ ជូឡុងស្រាយហើយពាអាតៅហុចជូនទៅឡៀវពី ។ ក៏ទទួលយកអាតៅជាបុត្រ ហើយធ្វើជាខឹងទំលាក់អាតៅទៅលើដី ហើយថា ព្រោះតែអាចង្រៃឯង ១ បានជាជូឡុងទាហានឯករបស់អញ ទៀបតែនឹងខូចការដោយសឹកសត្រូវ ។ ជូឡុងឃើញដូច្នោះភ័យណាស់ ក្រោកចូលទៅហើយប្រញាប់ចាប់លើកពរអាតៅឡើងដាក់លើភ្លៅ ហើយលុតជង្គង់ចុះគំនាប់ទៀតថា សូមលោកកុំប្រកាន់ខឹងនឹងបុត្ររបស់លោកឡើយ

ខ្ញុំបាទនេះហើយ ទោះបើទីនស្លាប់ជីវិត ខ្ញុំសុំយកលោហិតក្រាលផែនដី ទុកឲ្យប្រាកដ ជាទីតបស្នងសងគុណលោក ។

ឯប៉ុនផេង លើកទាហានដេញដិតតាមផ្លូវឡើងទៅដល់ស្ពានទៀង ប៉ាន់កៀវ ឃើញទៀវហ៊ុយកាន់លំពែងឈរស្កាត់លើស្ពាន ក្រឡេកទៅឃើញកណ្ដាលព្នាផ្លូវដីហុយទ្រលោមតាមជើងសេះ ដែលទាហានទៀវហ៊ុយព័យឲ្យបោលផុសឡើងពេញក្នុងព្រៃ ក៏សំគាល់ថា មានទាហានពួនបង្កប់នៅជាច្រើន ឯសេះនោះក៏មិនបានឲ្យបះបេញមក ។ ទទួលពោយ៉ិន, លីទៀន, ហែហ៊ួអៀន, អាក់ជិន, ទៀវលៀវ, ទៀវខាប់, ទីងទៅធូ ទាំង ៨ នេះ នាំទាហានលើកតាមមកទាន់ ក្រឡេកឃើញដូច្នោះក៏គិតថា ខុងបេងប្រើកលៗបាយបង្កប់ទាហានទុកនៅទីនោះហើយ ក៏នាំគ្នាឈប់បង្អង់នៅទីនោះទាំងអស់ . ទើបប្រើបំរើឲ្យទៅជំរាបចូចូ ។ ដឹងដូច្នោះ ក៏លើកទ័ពស្រួតមកថែមទៀត ។

ទៀវហ៊ុយក្រឡេកទៅ ឃើញទាហានលើកមកជាច្រើន ឃើញសប្បធនប៉ាំងមកពីក្រោយក៏ដឹងថា ចូចូលើកតាមមកផង ទើបស្រែកគំហកយ៉ាងខ្លាំងថា ខ្ញុំអញឈ្មោះទៀវហ៊ុយ នរណាដែលមានថ្វីដៃខ្លាំងពូកែ ឲ្យចេញមកតស៊ូគ្នាល្បងកម្លាំងមើលចុះ ឲ្យឃើញចាញ់ឈ្នះ ។ ទាហានចូចូឮសំឡេងទៀវហ៊ុយ ក៏ភ័យស្លុតទាំងអស់គ្នា ស្ងាំងកាំងមិនបានចូលច្បាំង ។ ទៀវហ៊ុយក៏ឲ្យទាហានស្រាយមែកឈើពីកន្ទុយ

សេះចេញអស់ ហើយក៏ឲ្យពញក្តារស្ពានទាំងអស់ចេញ រួចនាំពាហានទាំងនោះត្រឡប់ទៅរកទៀវពី ទើបពណ៌នារឿងរ៉ាវឲ្យទៀវពីស្តាប់គ្រប់ប្រការ ៗ ទៀវពីតបថា ខ្លួនឯងនេះមានថ្វីដៃខ្លាំងពូកែក៏ពិតមែន តែជានឹកស្តាយព្រោះធ្វើឧបាយមិនបានរហូត ដោយឯងទៅពញក្តារស្ពានចេញអស់ បើដូចនឹងប្រាប់ហេតុឲ្យចូឆូដឹងថា មនុស្សខាងយើងតិច ឲ្យលើកតាមមកទៀត បើទៅមិនពញស្ពានចេញទេ ចូឆូក៏នឹងសំគាល់ថាបង្កប់មនុស្សទុកក្នុងព្រៃជាច្រើនក៏នឹងញញើតខ្លាច លុះនិយាយហើយក៏នាំពាហានរកចុះផ្លូវ នឹងជម្រង់ទៅកំពង់ហានដិន ។

ឯទៀវលៀវ, ទៀវខាប់, និងខូជូ ឃើញទៀវហ៊ុយរត់ទៅហើយក៏ត្រឡប់ទៅប្រាប់ចូឆូថា ឥឡូវទៀវហ៊ុយពញក្តារស្ពានចេញអស់រត់ទៅ ចូឆូឮដូច្នោះក៏ថា ទៀវហ៊ុយនោះមានតែខ្លួនម្នាក់ឯង គ្មានពាហានទេបានជាពញស្ពានទំលាក់អស់រត់ទៅ ព្រោះខ្លាចយើងលើកទ័ពតាម, ហើយទើបកេណ្ឌពាហានបាន ៣ ពាន់ ឲ្យទៅធ្វើស្ពានជាថ្មីវិញ ៣ សិន (១២០ម.) កំណត់ឲ្យហើយតែក្នុងវេលាថ្ងៃមួយ ចាំនឹងអាលលើកពាហានជួន ៗ លីទៀននិយាយនឹងចូឆូថា ដែលលោកនឹងបន្ទំលើកទ័ពតាមទៀតពីព្រោះនោះ ខ្ញុំបាទគិតក្រែងខ្លាចជាកលឧបាយរបស់ខុងបេង ឯទៀវហ៊ុយនឹងមានគម្រោះប្រាជ្ញាចេះធ្វើឧបាយដល់ប៉ុណ្ណោះមិនមែនទេ សូមឲ្យលោកកុំអាលលើកទ័ពប្រញាប់ទៅឡើយ ។ ចូឆូថា ឧបាយកលតែប៉ុណ្ណោះ

ទ័ពខ្ញាបក្ស័ ពោះបើលើសជាងនេះ ក៏មិនត្រូវគោតខ្លាចដែរ ។ ចូចូក៏ស្រូតលើកទ័ពចូលស្ពានតាមទៅ ។

ឡៅពីបានឮបំឡេងទាហានហោកញ្ជ្រៀវពីខាងក្រោយ ដូចជាទ័ពក្ដុកក្រឡាប់ផែនដី មើលទៅឃើញផង់ធូលីហុយខ្ទរលោមទៅលើអាកាស ក៏និយាយថា យើងទ័ពទៅៈវេលានេះ ក៏នៅមានខ្មាំងនៅខាងមុខ ពីខាងក្រោយក៏មានកងទ័ពលើកគ្រលុកតាមមក តើយើងទ័ពត្រូវគិតយ៉ាងណាទៅអេះ? ទើបប្រើឲ្យជូឡុងត្រៀមពលយោធាទាំមកការពារពីខាងក្រោយ ចាំវាយកងទ័ពចូចូដែលលើកតាមមកនោះ ។

ខណៈនោះ ចូចូនិយាយនឹងទាហានទាំងពួងថា ឡៅពីគ្រានេះ ដូចត្រីទាំងនៅក្នុងសិង, ខ្លាដំបងទាំងនៅក្នុងទ្រុង បើទុកលះបង់ទុកឲ្យយូរគេនឹងតែរួចទៅបាន បីដូចត្រីរួចទៅក្នុងទឹក, ខ្លារួចទៅក្នុងព្រៃ ទាហានយើងទាំងអស់គ្នាចូរជួយខំឃាត សង្កាត់ខំតាមចាប់ខ្លួនឡៅពីឲ្យបានចុះ ។ ខណៈនោះពួកទាហានក៏ខំស្រូតប្រជ្រៀតគ្នាលើកតាមទៅ ។

ឯគួនអ៊ូដែលទៅស្រុកកាំងហែ បានទាហាន ១ ម៉ឺន ចុះទូកលើកគ្រឡប់មកដល់ពាក់កណ្ដាលផ្លូវដឹងដំណឹងថា ឡៅពីបែកទ័ពតែមកដល់ស្ពានទៀវប៉ាទ់កៀវ ក៏ឲ្យទាហានចូលចតទូកត្រង់កំពង់ហាន់ដិន ហើយលើកទាហានឡើងលើគោកមកស្កាត់ទទួលឡៅពី ។ ទទួលឡៅពីកាត់ប្រូតទៅដល់ជួបប្រទះគ្នាត្រង់ភ្នំមួយអន្ទើ ក៏ចួបនឹងកងទ័ពចូចូទៀត

លើកដាប់ដិតដោយពីក្រោយទៀតមកតាមផ្លូវធំ ។ គួនអ៊ូក៏បរសេះជញ្ជ្រាំដេញតាហានឲ្យស្រែកហៅឡើងពីមាត់កំពង់មក ។ ប្អូនឃើញដូច្នោះ ក៏នឹកឃើញដល់ពាក្យលើទៀនហាមមិនឲ្យលើកទ័ពមក ឃើញត្រូវដូចពាក្យថា គឺជាកលឧបាយរបស់ខុងបេងពិត ។ ប្អូនក៏បង្គាប់តា-ហានឲ្យថយក្រឡប់មកវិញ ។ គួនអ៊ូក៏ដេញចូលកយុទ្ធសន្ធិញទៅតាមចម្ងាយផ្លូវប្រហែល ១០០ សិន ( ៤ គ.ម ) ឃើញតាហានបួនថយទៅមិនបានតទល់ គួនអ៊ូក៏បថយត្រឡប់ទៅមុខវិញតាមផ្លូវកាត់ ប្រទះនឹងទៀតពីក៏មានទុំណរណាស់ ទើបនាំទៅចុះទូកហើយសួរថា នាងប៉ី-ហ៊ុយមិនបងថ្លៃខ្ញុំបាទ នៅឯណាក៏មិនឃើញ ។ ទៀតពីក៏អធិប្បាយរឿងតាមដែលបានកកាំងប៉្រាំងនឹងប្អូនទោះឲ្យគួនអ៊ូស្ដាប់ ហើយថានាងប៉ីហ៊ុ-យ៉ិនលោតស្ទាប់ក្នុងអណ្ដូងទឹកទៅហើយ ដូច្នេះយកបានតែអាវគៅមកឲ្យបង ។ គួនអ៊ូបានឮដូច្នោះ ក៏អង្គុយចុះទះទ្រូងយំការទ្រោះអាល័យហើយថា កាលថ្ងៃទៅតាមហែស្ដេចព្រះពជដំណើរចេញទៅប្រពាតព្រៃកាលណោះ ថើបឯកុំឃាត់ហាមខ្ញុំបាទ កាលភាទឹងបានមកលំបាកគោកយ៉ាកយ៉ាំងនេះ ។

ទៀតពីថា គ្រានោះខុនបេងក៏អនាថា រកទ័ពនីដែលនឹងគាំងខុនទីងក្មួមិហានមិនបានឲ្យល្មមជាទីទុកចិត្ត គិតទៅឃើញថា ខុនបេងដូចជាដ្រកជាប់ទ្រូង ក្រែងធ្វើការនោះមិនរហូតបានជាឃាត់ហាមប្អូនដូច្នោះ កាល-

ទៀវពីនិយាយនឹងគូនក្មួយដូច្នោះ ៗ ទទួលទៀវតីលើកកងទ័ពទូកមកដល់ក្រោយខាងលិច ៗ ទៀវពីបានឮសំឡេងហ៊ោកឹកកង បសុតស្មារតី ក្រឡេកទៅឃើញនាយទូកតែងខ្លួនពាក់អាវជូតក្បាលសំពត់ស ក៏សង្កេតស្គាល់បានថាទៀវតី, ទៀវពីឲ្យទាហានចាំងពួនសម្ងំនៅស្ងៀម ៗ លុះទៀវតីមកដល់កំបែតទូកចូលទៅគំនាប់ទៀវពីហើយយំថា ឥឡូវខ្ញុំបាទដឹងថាលោកបានថ្វស់ការនឹងចូចូបែកទ័ពគេមក ខ្ញុំបាទក៏បានរ៉ះរកកេណ្ឌទាហានឲ្យបានលើកមក ប្រាថ្នានឹងជួយលោកមា ៗ

ទៀវពីឮដូច្នោះក៏ត្រេកអរណាស់ ទើបអធិប្បាយរឿងតាំងពីដើមដល់ចប់ប្រាប់ទៀវតីជាក្មួយឲ្យស្តាប់គ្រប់ប្រការ ហើយឲ្យបន្ទយទូកចេញពីមាត់កំពង់ ទទួលក្រឡេកទៅឃើញទូកចម្បាំងទកងបើកក្តោងមកពីទិសឯលិច ៗ ទៀវតីថ្ងៃកក្នុងចិត្តក៏សួរទៀវពីថា ខ្ញុំបាទកេណ្ឌទាហានលើកមកគ្រានេះក៏អស់លើង ស្រុកកាំងហែក៏មានមនុស្សស្តួចស្តើងណាស់ ឥឡូវមានទូកចម្បាំងបើកក្តោងមកជាច្រើន ប្រហែលជាទាហានចូចូទេឬ? បើមិនដូច្នោះក៏មុខជាទាហានជីវយីឲ្យលើកមកធ្វើអន្តរាយជាប្រាកដ តើនឹងគិតយ៉ាងម្តេច លុះទូកចម្បាំងនោះចូលមកជិត ទៀវពីក្រឡេកទៅឃើញខុងបេងអង្គុយខាងក្បាលទូក , ស៊ិនសៀនអង្គុយខាងកន្សៃក៏មានសេចក្តីត្រេកអរណាស់ ទើបឲ្យទាហានស្រែកហៅ ឲ្យចូលមកហើយសួរថា ហេតុម្តេចក៏លោកនៅបន្អែបន្អង់ដូច្នេះ ៗ ខុងបេងគំនាប់ហើយឆ្លើយថា ដែលខ្ញុំបាទពារង

នៅដូច្នេះ ព្រោះខ្ញុំបាទទៅកេណ្ឌមនុស្សមកទៀតបានជាយឺតយូរ ៗ ទៀតពីបានស្តាប់ដូច្នោះក៏ឲ្យបើកក្តោងទូកជិតមក ហើយប្រឹក្សានឹងខុនបេង ដើម្បីនឹងគិតរកឧបាយច្បាំងតនឹងចូឆូទៅ ៗ

ខុនបេងឆ្លើយថា អាណាខែត្រក្បែរមាត់ទឹកដែលនៅជិតស្រុកកាំងហែនោះ មានទ័ពបន្ទាយគូស្នាមក្បោះមាំមួនល្មមនឹងតាំងនៅតស៊ូនឹងចូឆូបាន សុំឲ្យលើកទ័ពទៅតាំងនៅស្រុកហែខៅ មាត់កំពង់ស្រុកកាំងហែចុះ ចំណីត្រីសាច់នឹងស្រូវអង្ករស្បៀងអាហារក៏បរិបូណ៌មិនខ្វះខាត ហើយក៏ប្រាប់ទៀតថា អ្នកចូរស្រូតត្រឡប់ទៅស្រុកកាំងហែឲ្យឆាប់ ដើម្បីនឹងត្រៀមពលទាហានទាំងពួងឲ្យព្រមទុកជួយការពារធ្វើការទៅខាងមុខ ៗ ទៀតគីឆ្លើយថា ដែលនឹងឲ្យត្រឡប់ទៅប្រមូលពលទាហាន ត្រៀមបំរុងការទុកនោះក៏គួរហើយ តែខ្ញុំបាទគិតថា នឹងចង់អញ្ជើញលោកទៅផង ឲ្យជួយចាត់ចែងទាហានទាំងពួង កាលណាស្រេចហើយសឹមត្រឡប់ទៅនៅស្រុកហែខៅតែម្តងចុះ ៗ ខុនបេងយល់ឃើញត្រូវ ទើបឲ្យគួនអ៊ូនាំទាហាន ៥ ពាន់ទៅនៅរក្សាស្រុកហែខៅ ហើយក៏នាំទៀតពីទៅស្រុកកាំងហែជាមួយនឹងទៀតគី ៗ

ឯចូឆូដែលបានទៅប្រទះទ័ពគួនអ៊ូនៅកណ្តាលផ្លូវនោះ ក៏សំគាល់ថាជាកលខុនបេង ទើបមិនអាចនឹងតាមទៀតពីទៅ ក៏នាំពលថយត្រឡប់មកវិញគិតថាទៀតពីគេទៅគ្រាខ្នះ មុខជានឹងស្រូតរូតទៅវាយយកស្រុកកាំង

ឡេងជាប្រាកដ បើឡៅពីបានស្រុកកាំងឡេងហើយក៏ទ័ពតាំងខ្ទង់ជាមាំមួន បាន មុខជាធ្វើការដោយកម្រណាស់ គិតហើយក៏លើកពាហានវិលមកវិញ ទ័ពទៅវាយយកស្រុកកាំងឡេង ។

ខណៈនោះតុងយីដែលនៅក្បាស្រុកគេងជីវ ដឹងថាស្រុកស៊ិនយ៉ុងនោះឡើងដល់ចូចូហើយ លុះដឹងថាចូចូលើកមកដល់ដែនស្រុកគេងជីវ ក៏ទ័ពក្ខាច ឃើញថាទ័ពតស៊ូមិនបាន ក៏នាំអាណាប្រជារាស្ត្រទាំងពួង ចេញមកគំនាប់ចូចូហើយឲ្យអញ្ជើញចូចូចូលទៅក្នុងស្រុក ។ ចូចូក៏ចាត់ចែងរៀបចំអាណាប្រជារាស្ត្រទាំងពួងឲ្យនៅជាសុខតាមប្រក្រតី ហើយពិគ្រោះប្រឹក្សាទ័ពនិងសេនាពាហានថា ឥឡូវនេះឡៅពីទៅតាំងនៅស្រុកកាំងហៃហើយ យូរទៅខាងមុខឃើញថា នាំចិត្តគំនិតមួយគ្នាទ័ពស្រុកតងជី ដូចស្មៅក្រៅញាជ្រូក បើមិនជំរះដកឡើងសព្វចេញទេ ក៏ទ័ពលូតលាស់ដុះឡើងវិញលើសដើម ហើយជាប់ជាពូជតៗគ្នាទៅទៀត ទ័ពគិតប្រការម្តេច ទើបទ័ពកំចាត់ឡៅពីចេញបាន ។

ស៊ុនហ៊ុវឆ្លើយថា ដែលមហាឧបពជ្ជលើកទ័ពមកគ្រានេះ ក៏ឃើញថាជាការធំពន្ទឹកណាស់ ប្រាកដនៅគ្រប់ដំបន់ សូមឲ្យលោកនាំសំបុត្រទៅដល់ស៊ុនគួន បបួលមកដើរលេងក្រៅក្នុងស្រុកកាំងហៃ ហើយចូរគិតគូរបបួលចាប់ឡៅពីឲ្យបាន បើបានឡៅពីហើយទ័ពដែនស្រុកគេងជីវ

(មានត)

## ផ្នែកកំណត់និងប្រវត្តិការណ៍

# បុណ្យផ្កា
# ជួយឧបត្ថម្ភសមណនិស្សិត
# នៅពុទ្ធិកមហាវិទ្យាល័យ ព្រះសីហនុរាជ

គណៈកម្មការបុណ្យ រៀបរៀង

---

កាលពីថ្ងៃសុក្រ ទី ៤ កញ្ញា ១៩៥៩ វេលាម៉ោង ២០ មានការជួបជុំ នៅក្នុងទីបរិវេណនៃពុទ្ធិកមហាវិទ្យាល័យព្រះសីហនុរាជ ដើម្បីធ្វើបុណ្យផ្កាមួយ នៅក្រោមអធិបតីភាពនៃសម្តេចព្រះសង្ឃនាយកទាំងពីរព្រះអង្គ ដោយមានព្រះរាជានុញ្ញាតពីសម្តេចព្រះឧបយុវរាជ ។

បុណ្យផ្កានេះ ដែលបានរៀបចំធ្វើឡើង ដោយអស់លោកអតីតរដ្ឋ-មន្ត្រីក្រសួងធម្មការ និងលោករដ្ឋលេខាធិការក្រសួងធម្មការបច្ចុប្បន្ន និងអស់លោកអ្នកពុទ្ធបរិស័ទទាំងឡាយ បានជ្រាបអំពីព្រឹត្តិការណ៍នៃសមណ-និស្សិត ដែលកំពុងសិក្សាក្នុងពុទ្ធិកមហាវិទ្យាល័យសព្វថ្ងៃ គឺជាព្រឹត្តិ-ការណ៍ដ៏លំបាក ព្រោះសមណនិស្សិតទាំងនេះបានសិក្សាតាំងពីពុទ្ធិក-បឋមសិក្សា រហូតដល់ពុទ្ធិកមធ្យមសិក្សា ៧ ឆ្នាំរួចមកហើយ ក្នុងរយៈកាល ៧ ឆ្នាំនេះ តែងនៅក្នុងការឧបត្ថម្ភនៃមាតាបិតាដែលទាល់ក្រ ។ លុះផុតពីរយៈកាល ៧ ឆ្នាំនេះមក បានត្រូវជ្រើសរើសឲ្យចូលមកសិក្សាក្នុងពុទ្ធិក-មហាវិទ្យាល័យព្រះសីហនុរាជ មានរយៈកាលយ៉ាងតិចត្រឹម ៣ ឆ្នាំទៀត

ទៀត ដើម្បីសិក្សាវិជ្ជាជាន់ខ្ពស់ខាងព្រះពុទ្ធសាសនា និងខាងផ្លូវលោក ។ ឯសមណនិស្សិតទាំងនោះ ទោះបីបានមកសិក្សាក្នុងពុទ្ធិកមហាវិទ្យាល័យ ក៏ពិតមែនហើយ ប៉ុន្តែការឧបត្ថម្ភចំពោះមុខជីវភាព ក៏ត្រូវទៅតែទទួលពី សំណាក់ញាតិញោមដដែល ឯញាតិញោមនៃសមណនិស្សិតទាំងនោះ សុទ្ធតែនៅឯខេត្តក្រៅឆ្ងាយៗ ហើយមិនដែលជាអ្នកសម្បូណ៌ដោយធនធានផង ម្ល៉ោះហើយការឧបត្ថម្ភមិនបានជិតដល់ ថែមទាំងសមណនិស្សិតទាំងនោះ ដែលបានទទួលការសិក្សាខ្ពស់ឡើង ត្រូវបន្ថែមព្យាយាមរបស់ខ្លួន និងពេលវេលារបស់ខ្លួនឲ្យច្រើនឡើងទៀត ដើម្បីឲ្យសមដល់ទម្ងន់នៃការសិក្សានោះ ម្ល៉ោះហើយជីវភាពនៃសមណនិស្សិតដែលបង្គាប់តែប្រព្រឹត្តទៅតាមធម្មតានោះ ត្រឡប់ជាមានដំណើរមិនស្រួលនិងបណ្តាលឲ្យមានការអាក់អួល ។

អស់លោកមន្ត្រីនិងពុទ្ធបរិស័ទទាំងឡាយ បានជ្រាបព្រឹត្តិការណ៍ដូចខាងលើនេះហើយ ក៏មានចិត្តអាណិតអាសូរសមណនិស្សិតទាំងនោះ ទើបរួបរួមគ្នាធ្វើជាបុណ្យផ្កាមួយ ដើម្បីប្រមូលបច្ច័យដែលកើតពីសទ្ធាជ្រះថ្លានៃអស់លោក-អ្នកជាពុទ្ធសាសនិកជន យកទៅជួយឧបត្ថម្ភសមណ-និស្សិតទាំងនោះ ដើម្បីឲ្យមានជីវភាពស្រួលបួលឡើងវិញ ហើយនឹងបានតាំងព្យាយាមសិក្សាតទៅទៀត ។

មុននឹងធ្វើបុណ្យផ្កានោះ ព្រះតេជព្រះគុណព្រះពោធិវង្ស ហួត តាត អគ្គាធិការនៃពុទ្ធិកសិក្សាបានធ្វើចុតហ្មាយ ថ្វាយសម្តេចព្រះឧបយុវរាជជា

ប្រមុខនៃរាជរដ្ឋាភិបាលសូមព្រះរាជទានព្រះរាជានុញ្ញាត ។ សម្តេចព្រះឧបយុវរាជ ទ្រង់ប្រោសព្រះរាជទានព្រះរាជានុញ្ញាត ហើយទ្រង់បានចូលចាប់កុសលក្នុងបុណ្យផ្កានេះ ដោយព្រះរាជទ្រព្យផ្ទាល់ព្រះអង្គ ចំនួន ៥.០០០រៀល ផងទៀត ។

នៅឱកាសបុណ្យផ្កាក្នុងរាត្រីនោះ មានសម្តេចព្រះមហាសុមេធាធិបតី សង្ឃនាយកគណៈមហានិកាយ នឹងសម្តេចព្រះសុធម្មាធិបតីសង្ឃនាយកគណៈធម្មយុត្តិ បាននិមន្តទៅជាអធិបតី ដោយមានព្រះតេជព្រះគុណព្រះពោធិវង្ស អគ្គាធិការនៃពុទ្ធិកសិក្សា នៅគមសម្តេចទាំងពីរព្រះអង្គក្នុងទីនោះផង ។

អស់លោកមន្ត្រីធំ-តូចទាំងឡាយ ក៏បានអញ្ជើញទៅចូលរួមកុសលក្នុងបុណ្យផ្កានោះតាមសទ្ធារៀងខ្លួនក្នុងឋានៈជាពុទ្ធសាសនិកជន ព្រមទាំងអស់លោកជាពុទ្ធបរិស័ទទាំងឡាយ ដែលមាននាមក្នុងប្រក្រាមបុណ្យក្តី មិនមាននាមក្នុងប្រក្រាមបុណ្យក្តី ក៏បានអញ្ជើញទៅចូលចាប់កុសលតាមសទ្ធារៀងខ្លួន ។

ដល់ម៉ោង ២០ គត់ និមន្តសមណនិស្សិត ៤០ រូប ចំរើនព្រះបរិត្តនៅទីគ្រឹះស្ថានព្រះសីហនុ ។

ដល់ម៉ោង ២០-៣០ នាទី និមន្តសម្តេចព្រះមហាសុមេធាធិបតី ប្រទានធម្មទេសនា ដល់ម៉ោង ២១ ទើបចប់ ។

លំដាប់ពីនោះ គណៈកម្មការបានរួបរួមបច្ច័យដែលកើតពីសទ្ធាជ្រះថ្លានៃពុទ្ធបរិស័ទទាំងឡាយ បានចំនួន៥៩.៦២៣៛០០ ។

នៅពេលបន្ទាប់ពីនោះ គណៈកម្មការបានចាត់ចែងឲ្យវាគ្មិនជាតិខ្មែរម្នាក់ឈ្មោះ គ្រូឌុ និយាយរឿងរាមកេរ្តិ៍ជូនមហាជន ស្ដាប់ជាការកំសាន្ត ។ ការនិយាយរឿងរាមកេរ្តិ៍នោះ នាំឲ្យមហាជនពេញចិត្ត ហើយសប្បាយរីករាយណាស់ ឥតមានអ្នកណាម្នាក់ដែលចូលទៅស្ដាប់ហើយធុញទ្រាន់សោះឡើយ ព្រោះអ្នកគ្រូឌុនោះមានសម្លេងពីរោះ ហើយចេះនិយាយប្រកបដោយសំនួនវោហារក្បោះក្បាយ ហើយថែមទាំងចេះបញ្ចេញកាយវិការឲ្យសមទៅតាមទំនងនៃរឿងរ៉ាវនោះផងទៀត រហូតដល់ម៉ោង ២៤ ទើបចប់ដោយសន្តិ ។

កាលក្រោយបុណ្យផ្កានោះមួយថ្ងៃ គណៈកម្មការបុណ្យបានធ្វើសេចក្ដីសំដែងកតញ្ញូតាធម៌ និងឧទ្ទិសកុសលផ្សាយតាមវិទ្យុជាតិ និងចុះក្នុងកាសែតកម្ពុជា ដូចមានតទៅនេះ ៖

កាលពីថ្ងៃសុក្រទី ៤ កញ្ញា ១៩៥៩ នេះ តាំងពីម៉ោង ១៩ ដល់ម៉ោង ២៤ គណៈកម្មការបុណ្យបានចាត់ចែងធ្វើបុណ្យផ្កាមួយ ដើម្បីជួយឧបត្ថម្ភដល់សមណនិស្សិតទាំងឡាយ ដែលកំពុងសិក្សាសព្វថ្ងៃ នៅក្នុងពុទ្ធិកមហាវិទ្យាល័យព្រះសីហនុរាជ ក្រោមអធិបតីភាពនៃសម្ដេចព្រះសង្ឃនាយកទាំងពីរព្រះអង្គ ដូចមានកម្មវិធីបុណ្យដែលបានផ្សាយតាមវិទ្យុជាតិពី

ថៃ្ងមុនស្រោច ។ បុណ្យផ្កានោះ បានទទួលលទ្ធផលគឺបច្ច័យចំនួន ៥៩.២២៣៖០០ ដោយរួបរួមទាំងអស់ ។ បច្ច័យទាំងអស់នេះ គណៈកម្មការបុណ្យ បានប្រគល់ទៅលោកគណនេយ្យករនៃពុទ្ធិកមហាវិទ្យាល័យ ឲ្យយកទៅផ្ញើទុកនៅធនាគារហើយ ឲ្យចាត់ចែងបើកយកកល់ខែ តាមចំនួនដែលមានកំរិតមកជួយឧបត្ថម្ភសមណនិស្សិតទៅ ដកបដល់អស់ចំនួនប្រាក់ខាងលើ ។

គណៈកម្មការបុណ្យ សូមសំដែងដោយគោរពនូវកតញ្ញូតាធម៌យ៉ាងជ្រាលជ្រៅចំពោះសម្តេចព្រះឧបយុវរាជ ជាព្រះបិតាឯករាជ្យជាតិ ដែលទ្រង់បានក្រោសព្រះរាជទាន ព្រះរាជានុញ្ញាតឲ្យចាត់ចែងធ្វើបុណ្យផ្កានេះ ហើយសម្តេចទ្រង់បានចំណាយព្រះរាជទ្រព្យ ចូលចាប់កុសលក្នុងបុណ្យផ្កានេះផងទៀត ។

សូមអរព្រះគុណដ៏ខ្ពង់ខ្ពស់ ចំពោះសម្តេចព្រះសង្ឃនាយកទាំងពីរព្រះអង្គ ដែលមានទឹកព្រះទ័យត្រជាក់ បានលះបង់កិច្ចកន្លុំផ្ទាល់ព្រះអង្គ ហើយនិមន្តទៅជាអធិបតីក្នុងការបុណ្យនោះ មិនតែប៉ុណ្ណោះបានទាំងប្រទានចតុប្បច្ច័យចូលចាប់កុសលក្នុងបុណ្យនោះផងទៀន ។

សូមអរព្រះគុណយ៉ាងជ្រាលជ្រៅ ចំពោះឯកឧត្តមទាំងអស់លោកទាំងឡាយដែលជាអ្នកផ្តើមធ្វើបុណ្យផ្កានេះ ដែលមាននាមចារឹកក្នុងប្រក្រមបុណ្យស្រោច ព្រោះឯកឧត្តមទាំងអស់លោកទាំងឡាយព្រមទាំងពុទ្ធបរិ-

ស័ទ្ធះនោះ បានជ្រាបពីស្ថានការណ៍នៃពុទ្ធិកមហាវិទ្យាល័យសព្វគ្រប់ ទើបបានផ្ដើមធ្វើដោយសេចក្ដីជ្រះថ្លា ហើយបានបរិច្ចាគធនធានវៀនខ្លួន ព្រមទាំងបានដឹកនាំអស់លោកអ្នកទាំងឡាយឯទៀត ឲ្យកើតចិត្តជ្រះថ្លា បានចូលមកជួយអនុមោទនាកុងការបុណ្យនេះ ។

សូមអរព្រះគុណជាអនេក ចំពោះព្រះសង្ឃនិងអស់លោកអ្នកជាពុទ្ធ-បរិស័ទទាំងឡាយ ដែលមិនមាននាមកុងប្រូក្រាមនេះទេ ប៉ុន្តែបានទិមន្ត អញ្ជើញមក ជួយអនុមោទនាកុងបុណ្យផ្កានេះ ដោយបានបរិច្ចាគធនធាន តិច-ច្រើន តាមកម្លាំងសទ្ធាវៀនខ្លួន ។

នៅទីអវសាននេះ គណៈកម្មការបុណ្យសូមទុទ្ទិសផលដែលកើតឡើងអំពីការបុណ្យនេះ ថ្វាយចំពោះព្រះករុណាជាអម្ចាស់ជីវិត សម្ដេចព្រះមហាក្សត្រិយានី នឹងសម្ដេចព្រះឧបយុវរាជ ជាព្រះបិតាឯកពជ្យជាតិ សូមទ្រង់បានប្រកបដោយសុខសួស្ដីសិរីមង្គលគ្រប់ប្រការ នឹងសូមឲ្យមានជន្មាយុយឺតយូរអស់កាលជាអង្វែងតទៅ ។

សូមទុទ្ទិសផលប្រគេនចំពោះសម្ដេចព្រះសង្ឃនាយកទាំងពីរព្រះអង្គ សូមឲ្យបានប្រកបដោយសេចក្ដីសុខសាន្ត កុំបីមានរោគាពាធមកបៀតបៀនព្រះអង្គបានឡើយ ដរាបដល់អវសាន ។

សូមទុទ្ទិផលចំពោះឯកឧត្តម នឹងអស់លោក-អ្នកជាពុទ្ធបរិស័ទទាំងឡាយ សូមឲ្យបានប្រកបដោយសុភមង្គល វិបុលសុខ គ្រប់ទិវារាត្រី អស់កាលជាអង្វែងតទៅ ។

# វចនានុក្រមសំស្រ្កឹត ខ្មែរ

(តមក)

## ព្រះមហាប៉ាង-ខាត់ រៀបរៀង

---

អណ្ឌ នបុំ ពង, ស៊ុត ។ *អណ្ឌក* ក៏មាន ។ –*កដាហ* បុំ. សំបកនៃស៊ុត, (ស្រោមនៃពិភពលោក) ។ –*កោស* បុំ. សំបកនៃស៊ុត, (ស្រោមនៃពិភពលោក) ។ – *គត* គុ. ដែលតាំងនៅក្នុងស៊ុត ។ – *ជ* គុ. ដែលកើតក្នុងស៊ុត; បុំ បក្សី, ត្រី ។ – *ជេត្វរ* បុំ. ក្រុឌ ។ –*ភេទន* នបុំ. កិរិយាបែកនៃស៊ុត ។

អតជិ គុ. ដែលហោត, បុំ. ដំរាលហោត, ត្រឡង ។

អតត្ថាបិវត្តិ គុ. ដែលមានអត្ថពិតមិនមាន ។

អតប្បិបិត គុ. ដែលសន្សំហើយឥឡូវនេះមិនមាន, ដែលមិនផ្ទាប់ ។

អតប្បិយ គុ. ដែលមិនពិត ។

អតទីឲ, សរិ. មិនមែនអ្នកនោះ, មិនមែនរបស់នោះ ។ នបុំ. កិរិយាមិនមែនឈ្មោះ ។ – (*អតទ*) *ហមាណ* គុ. ដែលមិនគួរដល់អ្នកនោះ, ដែលមិនគួរដល់របស់នោះ ។ – *វិទ* (*អតទ្វិទ*) គុ ដែលដឹងឈ្មោះក៏មិនមាន ។ – *វីយវិភាគ្យ* (*អតទ្វីយ–*) គុ. ដែលដឹងនូវព្យាយាមរបស់ខ្លួនឈ្មោះមិនមាន ។

អតន្ទ្រ គុ. ដែលមិនមែនតូច, ដែលប្រមាណបាន ។ បុំ. កាមទេព, កាម ។ – *ពល* គុ. ដែលមានកម្លាំងតិចមិនមាន, ដែលមានកម្លាំងច្រើន ។

(មានត)